# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៩-៣-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/៣៨៤ ស្តីពី ការតែងតាំងឯកឧត្តម ចំនួន ០៧ រូប ជា ទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ងួន ញ៉ិល** អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៥ | ៣៦៤៨ |
| ២៩-៣-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/៣៨៥ ស្តីពី ការតែងតាំងលោកស្រី **អ៊ុង ស៊ាវិទ្ធី** ជា ឧកញ៉ា | ៣៦៤៩ |
| ២៩-៣-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/៣៨៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ ឧកញ៉ា អស់លោក លោកស្រី និងកញ្ញា ចំនួន ៣០៦ រូប | ៣៦៥០ |
| ៣១-៣-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/៣៨៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ប៉ាទ្រិក អូលីវីយេ ម៉ារី ហ្គាល់មីស** (PATRICK OLIVIER MARIE GALMICHE) ជនជាតិបារាំង សញ្ជាតិបារាំង កើតនៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង ដោយប្តូរឈ្មោះជា **ហ្គាល់មីស ប៉ាទ្រិក** ( GALMICHE PATRICK ) | ៣៦៥៥ |
| ៣១-៣-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/៣៨៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់កញ្ញា **ហ្វុង ហ្វុងអ៊ីង** (FENG FENGYING) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តហឺប៉ី សាធារណរដ្ឋប្រជាមានិតចិន | ៣៦៥៦ |
| ៣១-៣-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/៣៨៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក **ចាង ជៀនហ្វា** (ZHANG JIANHUA) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តជៀងស៊ូ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ចាង ជៀន** ( ZHANG JIAN ) | ៣៦៥៧ |
| ៣១-៣-២០១៤ | -ព្រះរាជក្រឹត្យ នស/រកត/០៣១៤/៣៩០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ចាង ហ៊ុយមាន** (ZHANG HUIMIN) ជនជាតិចិន សញ្ជាតិចិន កើតនៅ ខេត្តលៀវនីង សាធារណរដ្ឋប្រជាមានិតចិន | ៣៦៥៨ |

# II. រាជរដ្ឋាភិបាល

## ១. អនុក្រឹត្យ

២៨-៣-២០១៤ -អនុក្រឹត្យលេខ ១៥៣ អនក្រ.បក ស្តីពី ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ៣៦៥៩
០១-៤-២០១៤ -អនុក្រឹត្យលេខ ១៥៧ អនក្រ.បក ស្តីពី ការបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំណុះក្រសួងមហាផ្ទៃ ៣៧៤០
០១-៤-២០១៤ -អនុក្រឹត្យលេខ ១៥៨ អនក្រ.បក ស្តីពី ការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មចំណុះក្រសួងមហាផ្ទៃ ៣៧៤២
០១-៤-២០១៤ -អនុក្រឹត្យលេខ ១៥៩ អនក្រ.បក ស្តីពី ការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធក្របខ័ណ្ឌចាត់តាំងបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ៣៧៤៤
២៤-៣-២០១៤ -អនុក្រឹត្យលេខ ៣២៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៧៤៧
២៤-៣-២០១៤ -អនុក្រឹត្យលេខ ៣៣០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៧៤៨
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៣១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៧៤៩
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៣២ អនក្រ.តត ស្តីពី ការសម្រួលភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៣៧៥០
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៣៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៧៥២
២៥-៣-២០១៤ -អនុក្រឹត្យលេខ ៣៣៤ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិនាយក្រមការនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ៣៧៥៤
២៨-០២-២០១៤ -អនុក្រឹត្យលេខ ៣៣៥ អនក្រ.តត ស្តីពី ការកំណត់សមាសភាពនៃគណៈកម្មាធិការមតិកមនុស្សរស់ ៣៧៥៦
២៨-០២-២០១៤ -អនុក្រឹត្យលេខ ៣៣៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៧៥៨

## ២. សេចក្តីសម្រេច

០២-៤-២០១៤ -សេចក្តីសម្រេចលេខ ៨៦ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៣៧៥៩
០២-៤-២០១៤ -សេចក្តីសម្រេចលេខ ៨៧ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៣៧៦២

## ភ

០២-៤-២០១៤ -សេចក្តីសម្រេចលេខ ៨៨ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិ
ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ
ចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៣៧៦៥

០២-៤-២០១៤ -សេចក្តីសម្រេចលេខ ៨៩ សសរ ស្តីពី ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិ
ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រ
ចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៣៧៦៨

០៤-៤-២០១៤ -សេចក្តីសម្រេចលេខ ៩០ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៣៧៧១

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/៣៥៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៥ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៥
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ ឯកឧត្តមបណ្ឌិត **ខួន ញឹល** ប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង ៖

| | |
|---|---|
| ១- ឯកឧត្តម **គង់ ទិមាន** | ជាទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ខួន ញឹល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។ |
| ២- ឯកឧត្តម **ហេង ហួត** | ជាទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ខួន ញឹល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។ |
| ៣- ឯកឧត្តម **ខួន សេងអេង** | ជាទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ខួន ញឹល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។ |
| ៤- ឯកឧត្តម **ណុច ម៉ង់នី** | ជាទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ខួន ញឹល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។ |
| ៥- ឯកឧត្តម **ព្រាប ហ៊ិន** | ជាទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ខួន ញឹល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។ |
| ៦- ឯកឧត្តម **ឈិម វណ្ណៈ** | ជាទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ខួន ញឹល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ន្ថែមលើមុខងារបច្ចុប្បន្ន។ |
| ៧- ឯកឧត្តម **គីម សុខណាង** | ជាទីប្រឹក្សា ឯកឧត្តមបណ្ឌិត **ខួន ញឹល** អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៥ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ន្ថែមលើមុខងារបច្ចុប្បន្ន។ |

**មាត្រា ២** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសម្រេចតាមព្រះរាជក្រឹត្យនេះ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៧ទល.១៤០៣.៣៥០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤*

ព្រះរាជក្រឹត្យ [illegible] ស.ណ

**សំណៅដែលមានសម្គាល់ចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០១៤

**[illegible]រាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/៣៤៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស គម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា)

**ត្រាស់បង្គាប់**

**តែងតាំង :**

**លោកស្រី អ៊ឹង ស៊ាងរិទ្ធី**

**ជា**

**ឧកញ៉ា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៧.១៤០៣.៣៩១

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៤*

ល្បះ ៤១៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០១៤**
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/៣៨៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម ឡុង ផល
២- លោកជំទាវ ផេង វ៉ាន់ថា
៣- ឯកឧត្តម តាត និមល
៤- ឯកឧត្តម ភីវ វង្សខឿន
៥- ឯកឧត្តម វ៉េង សាម៉េត
៦- ឯកឧត្តម ចាន់ បូរ៉ា
៧- លោកជំទាវ ឡេង ណៅវ៉ាដា
៨- ឯកឧត្តម គង់ ចាន់ថន
៩- លោកជំទាវ ខឿន ស៊ីណា
១០- ឯកឧត្តម សយ សោភ័ណ្ឌ
១១- លោកជំទាវ រុយ សុគន្ធារី
១២- ឯកឧត្តម យុត វុទ្ធី
១៣-ឯកឧត្តម ជា អេងយ៉ុង
១៤- ឯកឧត្តម សួន ងន់លី
១៥- ឯកឧត្តម ចេងច័ន្ទ ពណ្ណារ៉ា
១៦- ឧកញ៉ា លី យុន
១៧- លោក ឡាយ វ៉េងឈុន
១៨- ឯកឧត្តម នាង សុជីវី
១៩- លោកជំទាវ ខ្សែវ ស៊ីម៉េង
២០- លោក អ៊ុន សុភ័ក្រ
២១- លោក ហុក វិសិទ្ធ
២២- លោក ប៊ុន ណារ៉ា
២៣- លោក ងួន ពិសិដ្ឋ

៥១- លោក ស៊ុម ពិសិដ្ឋ
៥២- លោក យ៉ាង វណ្ណា
៥៣- ព្រះមហាភទ្ទបាលោ ផន សុភ័ក្រ
៥៤- លោក គឹម ឆាយ
៥៥- លោក អំ ប៊ុនលី
៥៦- លោក សេក ភក្តី
៥៧- លោក ង៉ែត ច័ន្ទថា
៥៨- លោក ឡុង សុភ័ក្រ
៥៩- លោក រ័ត្ន ស៊ុនលី
៦០- លោក ង៉ែត ងួន
៦១- លោក លី វិន្ទ
៦២- ឧកញ៉ា សួស ផេង
៦៣- វរសេនីយ៍ឯក គួ បូរ៉ា
៦៤- លោក កោះ មករា
៦៥- លោក សែន វ៉ាន់ណាក់
៦៦- លោក កែវ ធី
៦៧- លោក ឆាយ ម៉ាទីណាល់
៦៨- លោក ជុំ សាភន
៦៩- វរសេនីយ៍ត្រី ម៉ែន វាសនា
៧០- លោក យាន ច័ន្ទគីរី
៧១- លោក ងួន វ៉ា
៧២- លោក សេង សុគន្ធ
៧៣- លោក ជា សុខលាភ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២៤- លោក PHAM XUAN SON
២៥- ឧកញ៉ា លី ស៊ីផេត
២៦- កញ្ញា ឆាយ កញ្ចនា
២៧- លោក សុខ បូណា
២៨- វរសេនីយ៍ឯក លន់ រតនា
២៩- វរនារីត្រី ប្រាក់ សុកល
៣០- អនុសេនីយ៍ឯក គុង សុផល
៣១- អនុសេនីយ៍ឯក អ៊ុក ផល្លា
៣២- អនុសេនីយ៍ឯក មុត វលក្ខណ៍
៣៣- វរសេនីយ៍ត្រី ចាន់ រដ្ឋា
៣៤- លោក ស្រេង ចិន្តា
៣៥- វរសេនីយ៍ត្រី សំ សាមាន
៣៦- ឧកញ៉ា ឆាយ ជ្រាយ
៣៧- ឧកញ៉ា ជា ធីឡាយ
៣៨- លោក ញ៉ែម សច្ចៈ
៣៩- វរសេនីយ៍ទោ សេង អ៊ីដេ
៤០- វរសេនីយ៍ត្រី អ៊ុល ឆាយ
៤១- លោក ឆាយ សុខា
៤២- វរសេនីយ៍ឯក តាល់ សុខា
៤៣- លោក NGO VAN DUNG
៤៤- លោក ឆាយ ពិទូរ្យ
៤៥- វរសេនីយ៍ឯក ហេង វណ្ណសក្តិ
៤៦- ឧត្តមសេនីយ៍ត្រី សន កែវ
៤៧- លោក សុខ លី
៤៨- លោក យន សុកល
៤៩- លោក ស៊ិត វណ្ណៈ
៥០- លោក កែវ សំអាត
៧៤- លោក ចាន់ រិទ្ធ
៧៥- លោក ឆាយ បូរ៉ា
៧៦- លោក ឃួន សំអុល
៧៧- លោក វ៉ី ស្ទូរី
៧៨- លោក វណ្ណ ណារ៉ា
៧៩- លោក តាំង ឈឹម
៨០- អនុសេនីយ៍ឯក ឈឿន ប៊ុនធឿន
៨១- វរសេនីយ៍ឯក ឈឹម ច័ន្ទសុង
៨២- វរសេនីយ៍ទោ ហេង សុផន
៨៣- លោក ទូ សុធា
៨៤- លោក មិន សុផេត
៨៥- លោក សៀម សុត្ថារ៉ុធ
៨៦- លោកស្រី ញិល ស្រីហេម
៨៧- លោក ជីម ម៉េងអាន
៨៨- វរសេនីយ៍ឯក យ៉ែម ច័ន្ទឌី
៨៩- លោក ស៊ុន ហុងឡាំ
៩០- លោក នាង ផល្លី
៩១- លោក ផែន ឌីណា
៩២- លោក សុទ្ធ សារឿន
៩៣- លោក នួវ សារ៉ុធ
៩៤- វរសេនីយ៍ត្រី ប៊ុន ចាន់ សុភាព
៩៥- កញ្ញា នុត សុថារី
៩៦- លោក អ៊ិត សុធា
៩៧- លោក ឡុង កេសភិរម្យ
៩៨- លោក ស៊ុយ ប៊ុនហ៊ាន
៩៩- លោក គីន សុវណ្ណធី

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម ខុល ស៊ីថុល
២- ឯកឧត្តម កោ លីឃន
៣- ឯកឧត្តម ទុំ សារុត
៤- ឯកឧត្តម សង់ រីហា
៥- វរសេនីយ៍ទោ លន់ ចាន់ថាតែន
៦- លោក ធូ មណី
៧- លោក យឹម សុជាតិ
៨- លោក ឈុន តិច
៩- លោក ខៃ សុវណ្ណ
១០- វរសេនីយ៍ឯក តាន់ សុផល
១១- លោក វណ្ណ វិរៈស័ក្ត
១២- វរសេនីយ៍ត្រី ស្រេង សុខា

គ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តមបណ្ឌិត វ៉ាន់ វ៉ាម៉ុន
២- ឯកឧត្តម សុខ រចនា
៣- ឯកឧត្តម សុខ ហេង
៩- វរសេនីយ៍ត្រី ម៉ែន សុភក្តិ
១០- លោក កង វ៉ាសនា
១១- វរសេនីយ៍ទោ ឡេង ជ្រិន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤- ឯកឧត្តម ឡេង ប៊ុនឡុង
៥- ឯកឧត្តម គួច ហៃ
៦- ឯកឧត្តម កាន់ ស៊ុយអៀង
៧-ឯកឧត្តម សុខ ផារិទ្ធ
៨- ឯកឧត្តម ខៀវ សុខា
១២- លោក ប៉ោត ប៉ូលិន
១៣-លោក លី សាត់សាយ
១៤-លោក ខេន សុវណ្ណ
១៥- លោក វៃ វ៉ាត

ឃ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈ នារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តមបណ្ឌិត សួន វ៉ានី
២- ឯកឧត្តម តាំង កក់
៣- ឯកឧត្តម អ៊ុនវ៉ាល់ ឡឺវ៉ូ
៤- ឧត្តមសេនីយ៍ទោ គីម និត
៥- ឯកឧត្តម អ៊ុក ស៊ីដែន
៦- ឯកឧត្តម ប៊ុក ច័ន្ទពោភា
៧- ឯកឧត្តម រស់ សុផារិទ្ធ
៨- លោក យៀម គីមសេង
៩- លោកស្រី គីម កន្និថា
១០- លោក ចិត្រ សេរីភ័ក្ត្រ
១១- ឯកឧត្តម ស៊ុន ចាន់ណារិទ្ធ
១២- ឯកឧត្តម YOON TAEK YANG
១៣-ឧត្តមសេនីយ៍ឯក ម៉ារ សំបូរណា
១៤- ឯកឧត្តម សយ អ៊ឹង
១៥- លោក NICOLAI DOROSHENKO
១៦- លោក ឯម កុសល
១៧- លោក ចិត្រ សេរីសុវត្ថិ
១៨- លោក ចិត្រ សេរីសុម្រឹត
១៩- លោក អ៊ឹង វីរៈ
២០- លោក ហ៊ុន សុធី

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម គង់ ចន្ធី
២- ឯកឧត្តម កែវ តារាពង្ស
៣- ឧកញ៉ា តាត សុជាតិ
៤- ឯកឧត្តម ជួន ជីវិន
៥- លោកជំទាវ ញ៉ិល ប៊ុនហ៊ាប
៦- លោកជំទាវ ជួរ វល័ក្ខ
៧- ឯកឧត្តម ឃិន កាតៀវ
៨- ឯកឧត្តម ទិត្យ ណារិទ្ធិ
៩- លោក អ៊ុក រស្មីតារា
១០- ឧត្តមសេនីយ៍ត្រី យឹម ប៊ូគុណ
១១- លោក មាស សុវត្ថារ៉ា
១២- លោក សុខ ពេញណាន
១៣- លោក ឈាង វន្ថា
១៤- លោក យ៉ោក ចយ
១៥- លោក ហ៊ីង ហ៊ាង
១៦- លោក ធាម ដែន
១៧- លោក ឃិន គីមស៊ន
១៨- លោកស្រី សុផុន សុម៉ានីកា
១៩- អនុសេនីយ៍ទោ គីម កូលីដូ
២០- វរសេនីយ៍ទោ កាន់ ចាន់ដារា
២១- វរសេនីយ៍ទោ ម៉ុក សុមុនី
២៩- លោក ឡេ វិចិត្រ
៣០- លោក ម៉ៅ ស៊ីណា
៣១- លោក ហេង សុខហ៊ន
៣២- លោក រ៉េត រ៉ន
៣៣- លោក និត វុឌ្ឍី
៣៤- លោក ឯម ភូរីបុទ្ធិ
៣៥- លោក ហៃ ចាន់ធូ
៣៦- លោក ព្រំ ថុន
៣៧- លោក សំ កុល
៣៨- លោក នូ ផេង
៣៩- លោក សុខ ហេង
៤០- ព្រះសិង្ហមុនីរាជព្រះបាឡាតគលោ មួង ចក្រី
៤១- លោក ម៉ែន ដា
៤២- លោក ដាវ វណ្ណា
៤៣- លោក ចាប ប៊ុណ្ណា
៤៤- លោក ជួប ភារុណ
៤៥- លោក សេង ច័ន្ទសុវណ្ណារ័ត្ន
៤៦- លោក ជួប តារា
៤៧- លោក ជឿន វ៉ាន់នី
៤៨- អនុសេនីយ៍ឯក អួច សេរីវុទ្ធ
៤៩- វរសេនីយ៍ទោ ផាន់ ភូមិរិន្ទ

២២- លោកស្រី ឃាន ផល្លា
២៣- អនុសេនីយ៍ឯក ផាន់ វណ្ណី
២៤- វរសេនីយ៍ឯក វ៉ា វិបុល
២៥- លោក នូវ ដារ៉ា
២៦- លោក ង៉ែត វិបុល
២៧- លោក ង៉ែត វិសាល
២៨- អនុសេនីយ៍ត្រី តិប ខុន
៥០- លោក សុទ្ធ យ៉ាដា
៥១- លោក លី សុភ័ក្រ្ត
៥២- លោក ចាន់ ស៊ាង
៥៣- លោក អ៊ុយ សុផល
៥៤- លោក ពុធ សុខា
៥៥- អនុសេនីយ៍ឯក ចាន់ សំអាន
៥៦- លោក ឆាំង តូង

ច- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- វរសេនីយ៍ទោ វេង ដារិទ្ធ
២- លោក ភោគ វឌ្ឍនា
៣- លោក អ៊ឹម ផល្គុន
៤- លោក ស្រ៊ុន គឹមតេក

ឆ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **និបទិន្ទ** :

១- លោកជំទាវ អ៊ិន របៀប
២- ឯកឧត្តម សំអាត មីស្សី
៣- លោកជំទាវ វ៉ាម៉ុន សុក្រធីតា
៤-ឧត្តមសេនីយ៍ទោ ឡាយ ប៊ុនថន
៥- ឯកឧត្តម មុត ខៀវ
៦- លោក ប៊ុន ថេង
៧- អនុសេនីយ៍ត្រី ប៊ុន ណារិទ្ធ
៨- លោក កែវ សុភា
៩- លោក អ៊ឹង ផេង
១០- លោក HAI OK JEON
១១- វរសេនីយ៍ត្រី យស់ ចំណាន
១២- វរសេនីយ៍ត្រី ម៉ិច សុទ្ធា
១៣- វរសេនីយ៍ឯក មៃ លន
១៤- វរសេនីយ៍ទោ ពិន សុផល
១៥- វរសេនីយ៍ឯក ឡាយ ប៊ុណ្ណារិទ្ធ
១៦- លោក ឃឿន ប៊ុនធឿន
១៧- លោក យិល សុធី
១៨- វេជ្ជបណ្ឌិត ហឿង ថុល
១៩- វេជ្ជបណ្ឌិត លុយ សែន
២០- វេជ្ជបណ្ឌិត ឆៃ សុផារ៉ាត
២១- លោក អេង រតនា
២២- លោក រី ផល្លា
២៣- លោក យ៉ន យុង
២៤- លោក គុជ ប៊ុនធីម
២៥- លោក អ៊ុំ សុវណ្ណារិទ្ធ
២៦- អនុសេនីយ៍ត្រី លាង សុខា
២៧- លោក ទ្រី សុខ
២៨- លោក យឿន ប៊ុនថៃ
៣៦- កញ្ញា វ៉ាន់ សុខរដ្ឋា
៣៧- លោកស្រី ជ្រា ហ្កេកអេង
៣៨- អនុសេនីយ៍ទោ យ៉ៃ ថង
៣៩- លោក ដួង ស៊ីថា
៤០- លោក យ៉ន ឡេងហាក់
៤១- លោកស្រី វ៉ាន់ ចំរើន
៤២- លោកស្រី ខៀវ វិនហ៊ាង
៤៣- លោក សុះ ហ្វាន់ឌី
៤៤- លោក ប៊ុន ហុង
៤៥- លោក ហុង ផល្លា
៤៦- លោក ហុង រាសី
៤៧- លោក ម៉ៃ ឆន
៤៨- លោក ស្រី យ៉ារ៉ែន
៤៩- លោក ពេជ្រ សក្តា
៥០- លោក សុង សុវណ្ណា
៥១- កញ្ញា ទិត្យ វណ្ណថាដែន
៥២- លោកស្រី អឿន ស៊ីសត្ថា
៥៣- លោក តាន់ វីរៈ
៥៤- លោក សួន ថាវ៉ាសនា
៥៥- អនុសេនីយ៍ត្រី យឿន សុភារៈ
៥៦- លោក ឡឹប សាហ៊ី
៥៧- លោក ជិន សុខា
៥៨- លោក ប៊ិច សោមសាខន
៥៩- លោកស្រី HYUN SOOK JUNG
៦០- វរសេនីយ៍ត្រី សម ចាន់រិទ្ធ
៦១- លោក ហួត បូរី
៦២- លោក អាន សំណាង
៦៣- លោកស្រី ថាយ សេងហាម



២៩- លោក ជួន សុផុន
៣០- លោកស្រី អ៊ុក ធួន
៣១- លោក សោម តាប់
៣២- លោក វ៉ាន់ សុត
៣៣- លោក កង សារិន
៣៤- លោក ម៉ៅ សេរីវឌ្ឍនា
៣៥- ព្រះគ្រូ បាន សុផាន
៦៤- លោក សុខ ផានិត
៦៥- លោក វ៉ាន់ ម៉ៅ
៦៦- លោក ថាយ ធា
៦៧- លោក ខឹម ចាន់ពិសី
៦៨- វរសេនីយ៍ត្រី អន សុភារ៉ា
៦៩- លោក ឡៅ ប៊ុនឡត

ជ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- ឯកឧត្តមបណ្ឌិត ឡេង ប៊ុនតេង
២- ឯកឧត្តម ងួន វិទូ
៣- លោក ខៀវ សារឿន
៤- លោក កង កោសល្យ
៥- លោក លីវ ម៉ូរិទ្ធ
៦- លោក រស់ វុទ្ធា
៧- លោក ម៉ែន សិទ្ធី
៨- លោក ជា ចិត្រា
៩- លោក និល ប៊ុនធឿន
១០- លោក សារី ពិសិដ្ឋ
១១- លោក អ៊ុំ ពិសិដ្ឋ
១២- វរសេនីយ៍ទោ ហុង គីមលាង
១៣- លោក គង់ សម្បត្តិ
១៤- លោក ជីវ លី
១៥- លោក ស្រ៊ាន ម៉ាច
១៦- លោកតា ស៊ឹម អ៊ុន

ឈ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោក អ៊ុយ ទិត្យ
២- វរសេនីយ៍ទោ គង់ ភិរុណ
៣- លោកស្រី ស្តើង ផល្លា
៤- លោក ប្រាក់ សារុន
៥- លោក ពេជ្រ ស៊ីននារ៉ាត់
៦- លោក ស៊ឹម ស៊ីថាន
៧- លោក គង់ រិទ្ធី
៨- លោក ជា សិដ្ឋជ័យ
៩- លោក ឆុន ណាត
១០- លោក អ៊ា ភក្តី
១១- លោក អឿន ណុក

ញ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១- លោក ឱក សុខុម
២- លោក ឆាយ គុង
៣- លោក យាយ សយ
៤- លោក យាយ មាលា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩ស.១៤០៣.៣៩៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤

លេខ: ៤៣១ ស.ណ
សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើម ដើម្បីជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/៣៧៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ប៉ាទ្រីក អូលីវីយេ ម៉ារី ហ្គាល់មីស** (PATRICK, OLIVIER, MARIE GALMICHE) ជនជាតិបារាំង សញ្ជាតិបារាំង កើតថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៤៧ នៅទីក្រុងប៉ារីស សាធារណរដ្ឋបារាំង ដោយប្តូរឈ្មោះជា **ហ្គាល់មីស ប៉ាទ្រីក** (GALMICHE PATRICK)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤. ២០១៤. ៣៩៣

លេខ: ៤០៩ ស.ណ

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤

**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/៣៩៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់កញ្ញា **ហ្វុង ហ្វុងអ៊ីង** (FENG FENGYING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៩ នៅខេត្តហឺប៉ី សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤

លេខ: ៤១៣ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/៣៤៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ចាង ជៀនហួរ** (ZHANG JIANHUA) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៥៥ នៅខេត្តជៀងស៊ូ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ចាង ជៀន** (ZHANG JIAN)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៣៣.១៤០៣.៣៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤

លេខ: ៤១១ ស.ណ

**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៣១៤/៣៩០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ចាង ហ៊ុយមាន** (ZHANG HUIMIN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៦៩ នៅខេត្តលៀវនីង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៤

លេខៈ ៤១៤ ស.ណ
**សំណៅចំលងចេញពីច្បាប់ដើមដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធ្វើឲ្យមានឯកភាពនីយកម្មនៃប្រព័ន្ធអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់នូវការទទួលស្គាល់លើលទ្ធផលសិក្សាដែលបានបញ្ចប់តាមកម្រិតគុណវុឌ្ឍិនីមួយៗ ប្រកបដោយសង្គតិភាពជាតិ
- បង្កើតច្រកបត់បែន ដែលបង្កភាពងាយស្រួលដល់អ្នកសិក្សាក្នុងការផ្លាស់ប្តូររវាងផ្នែកឧត្តមសិក្សា និងផ្នែកបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងរវាង ផ្នែកទាំងពីរជាមួយនឹងទីផ្សារការងារ តាមរយៈការផ្តល់នូវមូលដ្ឋានសម្រាប់ការទទួលស្គាល់ការសិក្សាដែលមានពីមុន រួមមានការផ្ទេរក្រេឌីត និងការទទួលស្គាល់លើបទពិសោធ និងសមត្ថភាពបច្ចុប្បន្ន
- ផ្តល់ភាពបត់បែនទៅតាមគោលបំណងផ្សេងៗគ្នានៃការអប់រំ និងការបណ្តុះបណ្តាល
- លើកទឹកចិត្តដល់ការធ្វើវឌ្ឍនកម្មចំណេះដឹងនិងជំនាញ តាមរយៈការអប់រំ និងការបណ្តុះបណ្តាល ដោយកែលម្អឱ្យមានភាពច្បាស់លាស់នូវការជ្រើសរើសគុណវុឌ្ឍិ ការកំណត់ផលសម្រេច និងលើកកម្ពស់ការសិក្សាពេញមួយជីវិត
- ជំរុញការផ្តល់គុណភាពលើការបណ្តុះបណ្តាលឧត្តមសិក្សា បច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈគុណវុឌ្ឍិ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គល ទីកន្លែងការងារ និងវិជ្ជាជីវៈ រួមចំណែកជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ
- លើកកម្ពស់ការទទួលស្គាល់គុណវុឌ្ឍិ ដែលចេញនៅក្នុងព្រះរាជាណាចក្រកម្ពុជា កម្រិតជាតិ និងអន្តរជាតិ និង
- សម្រួលដល់ការចល័តកម្លាំងពលកម្មនៅក្នុងតំបន់។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើគ្រប់ទម្រង់នៃឧត្តមសិក្សា និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

ខ្លឹមសារទាំងស្រុងនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

គ្រប់គ្រឹះស្ថានសិក្សាដែលកំពុងដំណើរការបណ្តុះបណ្តាលបច្ចុប្បន្ន មានរយៈពេលមួយ (០១)ឆ្នាំ ដើម្បីកែលម្អការអប់រំ និងការបណ្តុះបណ្តាលរបស់ខ្លួន ឱ្យស្របតាមលក្ខខណ្ឌដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

គ្រឹះស្ថានសិក្សាដែលទើបចាប់ផ្តើមបើកដំណើរការបណ្តុះបណ្តាល ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ មុននឹងដំណើរការបណ្តុះបណ្តាល។

**មាត្រា ៦.-**

ការគ្រប់គ្រងលើការអនុវត្ត និងអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យអប់រំ និងស្ថាប័នទទួលស្គាល់គុណភាពអប់រំ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល រដ្ឋមន្ត្រីគ្រប់ក្រសួងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## មាតិកា


ទំព័រ

១. សេចក្តីផ្តើម................................ ០១

២. ធាតុរបស់ ក.គ.ជ.ក................................ ០២

  ២.១ កម្រិតគុណវុឌ្ឍិ................................ ០២

  ២.២ ក្រេឌីត................................ ០៣

  ២.៣ លទ្ធផលសិក្សា................................ ០៦

  ២.៤ ប្រកសិក្សា................................ ០៧

៣. លក្ខណៈនិងលទ្ធផលនៃការសិក្សារំពឹងទុកក្នុងគុណវុឌ្ឍិនីមួយៗ................................ ០៨

  ៣.១ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ................................ ០៨

- វិញ្ញាបនបត្រវិជ្ជាជីវៈ................................ ០៨
- សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១................................ ១០
- សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២................................ ១២
- សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣................................ ១៥
- សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស................................ ១៨
- បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ................................ ២១
- បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស................................ ២៤
- បណ្ឌិតបច្ចេកវិទ្យា/ឯកទេស................................ ២៩

  ៣.២ ការអប់រំឧត្តមសិក្សា................................ ៣២

- ការរំពឹងទុកកម្រិតចូលរៀន( សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ )................................ ៣២
- បរិញ្ញាបត្ររង................................ ៣៣
- បរិញ្ញាបត្រ................................ ៣៦
- បរិញ្ញាបត្រជាន់ខ្ពស់................................ ៣៩
- សញ្ញាបត្របណ្ឌិត................................ ៤៤

៤. ការគ្រប់គ្រងនិងចេញគុណវុឌ្ឍិ................................ ៤៧

  ៤.១ ការគ្រប់គ្រងនិងអភិវឌ្ឍ................................ ៤៧

  ៤.២ ភាពខុសគ្នារវាងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនិងការអប់រំឧត្តមសិក្សា................................

៤.៣ ការប្រើឈ្មោះជំនាញសិក្សា ........ ៤៨

៤.៤ ការផ្តល់សញ្ញាបត្រកម្រិតបណ្ឌិត ........ ៤៩

៤.៥ ទម្រង់ស្នើសម្រាប់គុណវុឌ្ឍិ ........ ៤៩

៥. បញ្ហានិងទំនាក់ទំនង ........ ៥០

៥.១ ទំនាក់ទំនងរវាងការអប់រំឧត្តមសិក្សានិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ........ ៥០

៥.២ ការទទួលស្គាល់ការសិក្សាពីមុនមក ........ ៥១

៥.៣ ការរំពឹងទុកស្តីពីការចូលសិក្សាក្រោយមធ្យមសិក្សា ........ ៥២

៥.៤ ទំនាក់ទំនងរវាងតម្រូវការស្រាវជ្រាវនិងវិជ្ជាជីវៈនៅក្នុងឧត្តមសិក្សា ........ ៥២

៥.៥ កម្មវិធីអប់រំនិងបណ្តុះបណ្តាលនិងកម្រិតគុណវុឌ្ឍិទទួលបានដែលផ្តល់ដោយសមាគមវិជ្ជាជីវៈ ........ ៥៣

៥.៦ កម្រិតបញ្ចប់មធ្យមឬពាក់កណ្តាលនៃកម្មវិធីអប់រំនិងបណ្តុះបណ្តាលរយៈពេលវែង ........ ៥៤

៥.៧ សមមូលភាពនៃគុណវុឌ្ឍិក្នុងកម្រិតអន្តរជាតិ ........ ៥៥

៥.៨ ការអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិទៅលើគ្រឹះស្ថានអន្តរជាតិ ........ ៥៥

៥.៩ ការផ្ទៀងផ្ទាត់ស្តង់ដា ........ ៥៦

៥.១០ ការផ្ទៀងផ្ទាត់សង្គតិភាពជាមួយក្របខ័ណ្ឌគុណវុឌ្ឍិ ........ ៥៧

ឧបសម្ព័ន្ធ ........ ៥៩

១. តារាងពណ៌នាសង្ខេបគុណវុឌ្ឍិនីមួយៗ ........ ៥៩

២. សទ្ទានុក្រម ........ ៧៣

# ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (ក.គ.ជ.ក)

## ១. សេចក្ដីផ្ដើម

ប្រព័ន្ធធានាគុណភាពអប់រំនៅក្នុងព្រះរាជាណាចក្រកម្ពុជារៀបចំឡើង ដើម្បីធ្វើឲ្យការអប់រំនិងការបណ្ដុះបណ្ដាលមានគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិនិងមានការទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងសហគមន៍សិក្សានិងវិជ្ជាជីវៈអន្តរជាតិ។ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា(ក.គ.ជ.ក)ជាធាតុសំខាន់ចាំបាច់មួយនៅក្នុងប្រព័ន្ធធានានិងទទួលស្គាល់គុណភាពអប់រំដែលធានាឲ្យមានសង្គតិភាពនៃការអប់រំនិងការបណ្ដុះបណ្ដាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ក.គ.ជ.ក ជាឧបករណ៍ថ្នាក់ជាតិសម្រាប់ធ្វើការអភិវឌ្ឍនិងធ្វើចំណាត់ថ្នាក់នៃគុណវុឌ្ឍិស្របតាមលក្ខណវិនិច្ឆ័យនៃកម្រិតសិក្សាដែលបានសម្រេច ហើយក៏ជាគោលនយោបាយនិងយុទ្ធសាស្ត្រមួយក្នុងការធានាបាននូវគុណភាពអប់រំនិងបណ្ដុះបណ្ដាលដែលធ្វើឲ្យលទ្ធផលសិក្សាមានលក្ខណៈស្តង់ដាច្បាស់លាស់ព្រមទាំងមានការទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងសហគមន៍ជាតិនិងអន្តរជាតិ។

ក.គ.ជ.ក បង្កើតឲ្យមានសមមូលភាពច្បាស់លាស់នៃស្តង់ដាគុណវុឌ្ឍិជាតិជាមួយនឹងស្តង់ដាគុណវុឌ្ឍិក្នុងតំបន់។ ក.គ.ជ.ក នឹងផ្ដល់នូវចំណុចប្រៀបធៀបជាក់លាក់នៅក្នុងស្តង់ដានៃការអប់រំនិងការបណ្ដុះបណ្ដាលសម្រាប់គ្រឹះស្ថានសិក្សា ក្នុងការធ្វើផែនការនិងដំណើរការស្វ័យត្រួតពិនិត្យសម្រាប់មន្ត្រីត្រួតពិនិត្យពីខាងក្រៅដែលពាក់ព័ន្ធក្នុងដំណើរការទទួលស្គាល់គុណភាពអប់រំលើកម្មវិធីបណ្ដុះបណ្ដាលនិងលើគ្រឹះស្ថានសិក្សាទាំងមូល និងជួយដល់និយោជកក្នុងការស្វែងយល់ពីជំនាញនិងសមត្ថភាពរបស់និស្សិតដែលបានបញ្ចប់ការសិក្សាមុននឹងជ្រើសរើសយកមកបម្រើការងារ។

ក.គ.ជ.ក ផ្ដល់នូវការយល់ដឹងលើក្របខ័ណ្ឌរួមមួយដែលមានសង្គតិភាពជាតិ ព្រមទាំងមានភាពអាចបត់បែនសម្រាប់គ្រប់គុណវុឌ្ឍិនៅក្នុងការអប់រំនិងការបណ្ដុះបណ្ដាល។ ក្របខ័ណ្ឌគុណវុឌ្ឍិនេះផ្ដល់នូវលក្ខណៈរួមនិងភាពផ្សេងពីគ្នាសំខាន់ៗមួយចំនួននៃទាំងវិស័យពីរគឺ ការអប់រំឧត្តមសិក្សា និងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈដែលចាំបាច់និងយល់ដឹងជាមុន។ ភាពខុសគ្នា និងទំនាក់ទំនងមួយចំនួនរវាងវិស័យទាំងពីរនេះមានបញ្ជាក់នៅក្នុងផ្នែកទី៤.១។ ឯលទ្ធផលសិក្សាសម្រាប់កម្រិតនីមួយៗនៃវិស័យទាំងពីរមានបរិយាយក្នុងផ្នែកទី៣។

គោលបំណងនៃការបង្កើតក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាមានដូចតទៅ៖

- ផ្ដល់នូវការទទួលស្គាល់លើលទ្ធផលសិក្សាដែលបានបញ្ចប់តាមកម្រិតគុណវុឌ្ឍិនីមួយៗប្រកបដោយសង្គតិភាពជាតិ។
- ជួយបង្កើតច្រកអាចបត់បែនបាន ដែលបង្កភាពងាយស្រួលដល់អ្នកសិក្សាក្នុងការផ្លាស់ប្ដូររវាងវិស័យអប់រំឧត្តមសិក្សានិងអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ និងរវាងវិស័យទាំងពីរជាមួយនឹងទីផ្សារការងារតាមរយៈការផ្ដល់នូវមូលដ្ឋានសម្រាប់ការទទួលស្គាល់ការ[illegible]

មានពីមុនរួមមានការផ្ទេរក្រេឌីតនិងការទទួលស្គាល់លើបទពិសោធនិងសមត្ថភាពបច្ចុប្បន្ន។

- ផ្តល់ភាពបត់បែនទៅតាមគោលបំណងផ្សេងៗគ្នានៃការអប់រំនិងការបណ្តុះបណ្តាល។
- លើកទឹកចិត្តឲ្យមានការធ្វើវឌ្ឍនកម្មចំណេះដឹង ជំនាញតាមរយៈការអប់រំនិងការបណ្តុះបណ្តាល ដោយកែលម្អឲ្យមានភាពច្បាស់លាស់នូវការជ្រើសរើសគុណវុឌ្ឍិ ការកំណត់ផលសម្រេច និងការរួមចំណែកក្នុងការសិក្សាពេញមួយជីវិត។
- ជំរុញការផ្តល់គុណភាពអប់រំនិងការបណ្តុះបណ្តាលឧត្តមសិក្សា បច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈគុណវុឌ្ឍិដែលឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គល ទីកន្លែងការងារនិងវិជ្ជាជីវៈ ដែលរួមចំណែកជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។
- លើកកម្ពស់ការទទួលស្គាល់គុណវុឌ្ឍិដែលចេញនៅក្នុងព្រះរាជាណាចក្រកម្ពុជាកម្រិតជាតិនិងអន្តរជាតិ។
- សម្រួលដល់ចលភាពកម្លាំងពលកម្មនៅក្នុងតំបន់។

## ២. ធាតុរបស់ ក.គ.ជ.ក

ធាតុគោលរបស់គុណវុឌ្ឍិដែលកំណត់ក្នុង ក.គ.ជ.ក មាន៤គឺ៖ កម្រិត ក្រេឌីត លទ្ធផលសិក្សា និងច្រកសិក្សា។

កម្រិត៖ កម្រិតជាលេខលំដាប់ដែលភ្ជាប់ទៅនឹងឈ្មោះគុណវុឌ្ឍិ ដើម្បីរៀបរាប់ពីតម្រូវការនៃបញ្ញាដែលកើនឡើងនិងភាពស្មុគស្មាញនៃលទ្ធផលសិក្សានៅក្នុងគុណវុឌ្ឍិនីមួយៗ។

ក្រេឌីត៖ ឯកតាឬតម្លៃដែលយកជាខ្នាតសម្រាប់វាស់វែងនិងពិពណ៌នាពីទំហំការងារឬបរិមាណនៃការសិក្សាដែលរំពឹងទុកសម្រាប់កម្រិតនីមួយៗឬសម្រាប់មុខវិជ្ជាសិក្សា ឯកតាសិក្សា ឬសមាសភាគដទៃទៀតនៃកម្មវិធីអប់រំនិងបណ្តុះបណ្តាល។

លទ្ធផលសិក្សា៖ ជាសេចក្តីថ្លែងនូវអ្វីដែលអ្នកសិក្សាចេះ យល់ និងអាចធ្វើបាន ក្រោយបញ្ចប់ការសិក្សា តាមរយៈលក្ខណវិនិច្ឆ័យស្តង់ដារការងារផ្អែកលើចំណេះដឹង ជំនាញ អាកប្បកិរិយា និងសមត្ថភាព។

ច្រកសិក្សា៖ ច្រកអាចបត់បែនបានដែលបង្កភាពងាយស្រួលដល់អ្នកសិក្សាក្នុងការផ្លាស់ប្តូររវាងវិស័យអប់រំឧត្តមសិក្សា និងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការបន្តការសិក្សាកម្រិតគុណវុឌ្ឍិខ្ពស់បន្ថែមទៀត តាមរយៈការទទួលស្គាល់ការសិក្សាដែលមានពីមុនរួមមានការផ្ទេរក្រេឌីតនិងការទទួលស្គាល់លើបទពិសោធនិងសមត្ថភាពបច្ចុប្បន្ន។

### ២.១ កម្រិតគុណវុឌ្ឍិ

កម្រិតគុណវុឌ្ឍិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមាន៨។ ចំពោះគុណវុឌ្ឍិបួនកម្រិតដំបូងដែលអាចទទួលបានជាវិញ្ញាបនបត្រវិជ្ជាជីវៈ និងសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង ៣ ត្រូវបានផ្តល់តម្លៃស្មើគ្នាទៅនឹងការអប់រំមធ្យមសិក្សា។ ចំណែកឯបួនគុណវុឌ្ឍិបន្តពីនេះ ត្រូវចាត់ទុកជាគុណវុឌ្ឍិនៃការសិក្សាក្រោយមធ្យមសិក្សា។

កម្រិតចូលទៅការអប់រំឧត្តមសិក្សា គឺការបញ្ចប់ដោយជោគជ័យនៅមធ្យមសិក្សាទុតិយភូមិ។ ក្របខ័ណ្ឌអប់រំឧត្តមសិក្សាមាន៤កម្រិតគុណវុឌ្ឍិ ដែលកម្រិតខ្ពស់បំផុតគឺ សញ្ញាបត្រកម្រិតបណ្ឌិត។ សញ្ញាបត្រកិត្តិយសមិនរាប់បញ្ចូលទៅក្នុងក្របខ័ណ្ឌនេះទេ ប៉ុន្តែមានផ្តល់ជាគោលការណ៍ណែនាំសម្រាប់ការផ្តល់សញ្ញាបត្រនិងគោរម្យងារកិត្តិយស ដោយផ្អែកទៅលើអនុសញ្ញាអន្តរជាតិនិងអនុក្រឹត្យលេខ ១៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការបណ្តុះបណ្តាលកម្រិតបណ្ឌិត។

ការបញ្ចប់ការសិក្សាដោយជោគជ័យនៅកម្រិតគុណវុឌ្ឍិណាមួយ មិនបញ្ជាក់ពីលក្ខណសម្បត្តិចាំបាច់របស់បុគ្គលដើម្បីចូលសិក្សាបន្តនៅកម្រិតគុណវុឌ្ឍិបន្ទាប់ឡើយ។ លក្ខខណ្ឌចូលឬបន្តការសិក្សាអាចនឹងរៀបចំឡើងដោយផ្អែកទៅលើសំណុំសមត្ថភាពនៃគុណវុឌ្ឍិដែលមានឬនិទ្ទេស(ចំណាត់ថ្នាក់) ឬលក្ខណវិនិច្ឆ័យផ្សេងទៀត ដើម្បីធានាថាបេក្ខជនមានឱកាសក្នុងការចាប់យកការសិក្សាកម្រិតខ្ពស់បន្ទាប់ដើម្បីទទួលបានគុណវុឌ្ឍិខ្ពស់ជាង។

កម្រិតគុណវុឌ្ឍិសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ការអប់រំឧត្តមសិក្សា និងទំនាក់ទំនងរវាងវិស័យទាំងពីរមានបង្ហាញជារចនាសម្ព័ន្ធដូចខាងក្រោម៖

រចនាសម្ព័ន្ធក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (ក.គ.ជ.ក)

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ការអប់រំឧត្តមសិក្សា |
|---|---|---|
| ៨ | បណ្ឌិតបច្ចេកវិទ្យា /ឯកទេស | បណ្ឌិត |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា /ឯកទេស | បរិញ្ញាបត្រជាន់ខ្ពស់ |
| ៦ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | បរិញ្ញាបត្រ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស | បរិញ្ញាបត្ររង |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | |
| ៣ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | |
| ២ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | |

## ២.២ ក្រេឌីត

- ជាគោលការណ៍ ការកំណត់ចំនួនក្រេឌីតក្នុងក្របខ័ណ្ឌគុណវុឌ្ឍិនេះ គឺ ១៥ម៉ោង

សម្រាប់ការបង្រៀនក្នុងកម្រិតធម្មតា៣០ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការសិក្សាប្រតិបត្តិ និងចំនួន៤៥ម៉ោងស្មើនឹង១ក្រេឌីតសម្រាប់ការអនុវត្តជាក់ស្តែង។ ចំពោះនិស្សិតសិក្សាពេញម៉ោងនៅកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រក្នុងរយៈពេល១ឆមាស ត្រូវសិក្សាយ៉ាងតិចចំនួន១៥ក្រេឌីតនិងយ៉ាងតិចចំនួន៣០ក្រេឌីតក្នុងរយៈពេលមួយឆ្នាំសិក្សា (សម្រាប់ព័ត៌មានលម្អិត សូមមើលសេចក្តីសម្រេចលេខ០៤/០៤គ.ទ.ក.សសរ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការអនុវត្តកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីតនិងការផ្ទេរក្រេឌីត)។

កម្មវិធីបណ្តុះបណ្តាលដែលប្រើឈ្មោះគុណវុឌ្ឍិដូចឬប្រហាក់ប្រហែលគ្នា អាចប្រើរយៈពេល (និងចំនួនក្រេឌីតដែលត្រូវបែងចែក)ខុសគ្នាសម្រាប់កម្មវិធីបណ្តុះបណ្តាលទាំងនោះ។ ឧទាហរណ៍កម្មវិធីបណ្តុះបណ្តាលសម្រាប់កម្រិតបរិញ្ញាបត្រអាចមានរយៈពេល៤ឆ្នាំ ៥ឆ្នាំ ឬ ៦ឆ្នាំ អាស្រ័យទៅតាមលទ្ធផលសិក្សាដែលបានរំពឹងទុក។

កម្មវិធីបណ្តុះបណ្តាលក្រោយមធ្យមសិក្សា រាប់បញ្ចូលទាំងការចុះអនុវត្តផ្ទាល់នៅការដ្ឋាន (កន្លែងការងារ)ឬការចុះកម្មសិក្សាដែលអាចនឹងត្រូវកំណត់ជាចំនួនក្រេឌីត។ ប៉ុន្តែចំនួនក្រេឌីតដែលបានបែងចែកត្រូវតែត្រឹមត្រូវឬសមស្របទៅតាមលទ្ធផលសិក្សារបស់និស្សិតដែលរំពឹងទុកពីបទពិសោធនោះ។

នៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គុណវុឌ្ឍិកំណត់ឡើងដើម្បីបញ្ជាក់អំពីការទទួលបាននូវសមត្ថភាពច្បាស់លាស់តាមតម្រូវការការងារ ពិសេសគុណវុឌ្ឍិវិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ ៣ និងសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស ជាគុណវុឌ្ឍិផ្អែកលើសមត្ថភាព។ ប៉ុន្តែទោះជាយ៉ាងណាក៏មានរយៈពេលកំណត់ជាមធ្យមសម្រាប់ អ្នកសិក្សាក្នុងការអភិវឌ្ឍសមត្ថភាពទាំងនោះដោយអាស្រ័យទៅតាមពេលវេលាតម្រូវ។ តម្រូវការចំនួនក្រេឌីតគឺអាស្រ័យទៅតាមរយៈពេលនិងបទពិសោធ ដែលនិស្សិតទទួលយកនៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន។ សម្រាប់កម្មវិធីអប់រំនិងបណ្តុះបណ្តាលកម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ ត្រូវមានចំនួនក្រេឌីតសរុបយ៉ាងតិច៣០ក្រេឌីត សម្រាប់គុណវុឌ្ឍិនីមួយៗ។ ប៉ុន្តែអាចប្រើយន្តការសម្រាប់ការវាយតម្លៃសមត្ថភាពដែលមានស្រាប់តាមរយៈបទពិសោធនៅកន្លែងការងារ រយៈពេលដែលនិស្សិតត្រូវសិក្សាអាចនឹងត្រូវកាត់បន្ថយ តាមរយៈការវាយតម្លៃជាផ្លូវការលើការទទួលស្គាល់ការសិក្សាដែលមានពីមុននិងសមត្ថភាពបច្ចុប្បន្ន។

នៅកម្រិតគុណវុឌ្ឍិក្រោយមធ្យមសិក្សា តម្រូវឲ្យមានចំនួនក្រេឌីតសរុបយ៉ាងតិច៣០ក្រេឌីតសម្រាប់កម្មវិធីបណ្តុះបណ្តាលកម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស(កម្រិតគុណវុឌ្ឍិ៥) បូកបន្ថែមចំនួន៣០ក្រេឌីត(ចំនួនក្រេឌីតអប្បបរមាសរុប៦០ក្រេឌីត)សម្រាប់កម្មវិធីបណ្តុះបណ្តាលកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រនិសញ្ញាបត្រវិស្វករ(កម្រិតគុណវុឌ្ឍិ៦) ត្រូវបូកបន្ថែមចំនួន៦០ក្រេឌីតទៀតសរុបចំនួនក្រេឌីតអប្បបរមា១២០ក្រេឌីត។ គុណវុឌ្ឍិសម្រាប់កម្មវិធីបណ្តុះបណ្តាលពិសេស អាចតម្រូវឲ្យមានចំនួនក្រេឌីតបន្ថែមច្រើនជាងចំនួនក្រេឌីតអប្បបរមាដែលបានកំណត់។ ចំពោះគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស ដែលមាននៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវសិក្សានៅកម្រិតគុណវុឌ្ឍិបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស រយៈពេល២ឆ្នាំ តាមរយៈមុខវិជ្ជាសិក្សាក្នុងថ្នាក់[illegible] និងការសិក្សាស្រាវជ្រាវសរសេរគម្រោងដែលមានក្រេឌីតអប្បរមាសរុប៤៥ក្រេឌីត។

ចំពោះកម្រិតគុណវុឌ្ឍិបណ្ឌិតបច្ចេកវិទ្យា/ឯកទេស ដែលមាននៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាលទ្ធផលនៃការសិក្សាដែលរួមបញ្ចូលទាំងស្វ័យអភិវឌ្ឍនិងអនុវត្តទូលំទូលាយទាំងចំណេះដឹងទ្រឹស្តីវិជ្ជាជីវៈនិងជំនាញក្នុងវិស័យផ្សេងៗ និង/ឬឯកទេសកម្រិតខ្ពស់បន្ថែមពីគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ តាមរយៈការសិក្សា ការស្រាវជ្រាវផ្ទាល់ខ្លួន និងការសរសេរនិក្ខេបបទ។ គុណវុឌ្ឍិបណ្ឌិតបច្ចេកវិទ្យា/ឯកទេសត្រូវសិក្សាយ៉ាងហោចណាស់៣ឆ្នាំ ហើយក្រេឌីតដែលកំណត់អប្បបរមាសរុប ៥៤ក្រេឌីតដើម្បីស៊ីគ្នាទៅនឹងការពិពណ៌នាគុណវុឌ្ឍិកម្រិត៨។

នៅក្នុងការអប់រំឧត្តមសិក្សា ការតម្រូវឲ្យមានចំនួនក្រេឌីតអប្បបរមាសរុប៦០ក្រេឌីត (ឬ២ឆ្នាំសិក្សា)សម្រាប់គុណវុឌ្ឍិបរិញ្ញាបត្ររង (គុណវុឌ្ឍិកម្រិត៥)និងចំនួនក្រេឌីតអប្បបរមាសរុប១២០ក្រេឌីតសម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រដែលមានកម្មវិធីបណ្តុះបណ្តាល៤ឆ្នាំ ១៤០ក្រេឌីតសម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រដែលមានកម្មវិធីបណ្តុះបណ្តាល៥ឆ្នាំនិង១៦០ក្រេឌីតសម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រដែលមានកម្មវិធីបណ្តុះ-បណ្តាល៦ឆ្នាំ (កម្រិតគុណវុឌ្ឍិ៦)។

នៅកម្រិតគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ ត្រូវសិក្សាបន្ថែមពីគុណវុឌ្ឍិបរិញ្ញាបត្រចំនួន៣៩ក្រេឌីតបូកនឹងការសរសេរគម្រោងមួយ (ចំនួនក្រេឌីតសរុប៤៥ក្រេឌីត សម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ដែលមានកម្មវិធីបណ្តុះបណ្តាល២ឆ្នាំនិង៥៧ក្រេឌីតសម្រាប់គុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ដែលមានកម្មវិធីបណ្តុះបណ្តាល៣ឆ្នាំ)។ ប្រសិនបើនិស្សិតចង់បន្តការសិក្សាពីគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់ទៅគុណវុឌ្ឍិបណ្ឌិតមានជម្រើសពីរដែលតម្រូវឲ្យមានចំនួនមុខវិជ្ជាសិក្សាក្នុងថ្នាក់(course work)ផ្សេងគ្នា។ ជម្រើសទីមួយតម្រូវឲ្យមានចំនួនក្រេឌីតសរុបយ៉ាងតិច១២ក្រេឌីត - សិក្សាបន្ថែមពីគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់បូកនឹងនិក្ខេបបទនិងជម្រើសទីពីរតម្រូវឲ្យមានចំនួនក្រេឌីតសរុបយ៉ាងតិច៥៤ក្រេឌីតបូកនឹងនិក្ខេបបទ។ តម្រូវការផ្សេងគ្នាក្នុងការស្រាវជ្រាវនិងការសរសេរនិក្ខេបបទបានថ្លឹងថ្លែងឬទូទាត់សម្រាប់តម្រូវការសិក្សាចំនួនមុខវិជ្ជាក្នុងថ្នាក់ផ្សេងគ្នាហើយជម្រើសទាំងពីរនេះស្ថិតនៅក្នុងកម្រិតគុណវុឌ្ឍិដូចគ្នា។

**តារាងចំនួនក្រេឌីតអប្បបរមាដែលជាការតម្រូវសម្រាប់គុណវុឌ្ឍិនីមួយៗ**

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ការអប់រំឧត្តមសិក្សា | ចំនួនក្រេឌីតអប្បបរមា |
|---|---|---|---|
| ៨ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | បណ្ឌិត | ៥៤ |
| ៧ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | បរិញ្ញាបត្រជាន់ខ្ពស់ | ៤៥ |
| ៦ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ | បរិញ្ញាបត្រ | ១២០ |
| ៥ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស | បរិញ្ញាបត្ររង | ៦០ |
| ៤ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ | | |

| | | | |
|---|---|---|---|
| ៣ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ | | ៣០ |
| ២ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ | | ៣០ |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | | ៣០ |

## ២.៣ លទ្ធផលសិក្សា

លទ្ធផលសិក្សារំពឹងទុករបស់និស្សិតកំណត់ដោយសំណុំសមត្ថភាពធំៗពីរ គឺសមត្ថភាពមូលដ្ឋាន និងសមត្ថភាពស្នូលដោយចែកចេញជា៥ផ្នែកធំៗដែលអាចអនុវត្តបានគ្រប់កម្មវិធីបណ្តុះបណ្តាលទាំងអស់ក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយឡែកក្នុងវិស័យអប់រំឧត្តមសិក្សាត្រូវបានចែកចេញជា៤ផ្នែកធំៗនិងផ្នែកជំនាញចិត្តចលនាដែលទាក់ទងតែទៅនឹងកម្មវិធីបណ្តុះបណ្តាលមួយចំនួន។

ផ្នែកទាំង៥នោះគឺ៖

**១. ចំណេះដឹង**

សមត្ថភាពចងចាំ យល់ដឹង និងបកស្រាយព័ត៌មាន រួមមាន៖

- ចំណេះដឹងពីហេតុការណ៍ជាក់លាក់
- ចំណេះដឹងខាងគំនិត (ទស្សនាទាន) គោលការណ៍និងទ្រឹស្តី
- ចំណេះដឹងពីទម្រង់ការឬនីតិក្រម ឬរបៀបរបបការងារ។

**២. ជំនាញក្នុងការគិត(ចំណេះដឹងវិភាគ)៖**

- សមត្ថភាពអនុវត្តការយល់ដឹងផ្នែកទស្សនាទាន គោលការណ៍ ទ្រឹស្តី និងទម្រង់ការនៅក្នុងការគិត វិភាគ និងការប៉ិនប្រសប់ឬច្នៃប្រឌិតក្នុងការដោះស្រាយបញ្ហាទាំងនៅពេលគេប្រាប់ឲ្យធ្វើនិងនៅពេលជួបប្រទះស្ថានការណ៍ថ្មីដែលមិនគ្រោងទុកជាមុន។

**៣. ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ**

សមត្ថភាព រួមមាន៖

- ទទួលខុសត្រូវក្នុងការសិក្សារបស់ខ្លួននិងបន្តអភិវឌ្ឍបុគ្គលិកលក្ខណៈនិងមុខរបរ
- ធ្វើការជាក្រុមប្រកបដោយប្រសិទ្ធភាពនិងប្រើប្រាស់ភាពជាអ្នកដឹកនាំបានត្រឹមត្រូវ
- ដើរតួប្រកបដោយភាពជឿទុកចិត្តបានក្នុងទំនាក់ទំនងបុគ្គលនិងការងារ
- ប្រកាន់ខ្ជាប់នូវក្រមសីលធម៌ខ្ពស់ក្នុងបុគ្គលភាពនិងវេទិកាសាធារណៈ។

**៤. ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង**

សមត្ថភាព រួមមាន៖

- ធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពក្នុងទម្រង់និយាយនិងសរសេរ
- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង

- ប្រើបច្ចេកទេសគណិតវិទ្យាមូលដ្ឋាននិងស្ថិតិវិទ្យា។

៥. ជំនាញចិត្តចលនា

- សមត្ថភាពប្រតិបត្តិជំនាញមួយឬច្រើនដោយងាយនិងជាស្វ័យប្រវត្តិប្រើទាំងរូបសាស្ត្រនិងបញ្ញាញាណ
- សមត្ថភាពប្រតិបត្តិជំនាញផ្សេងៗរួមបញ្ចូលគ្នាទៅតាមលំដាប់លំដោយនៃការងារប្រកបដោយសង្គតិភាព
- សមត្ថភាពបង្កើតជាថ្មីនូវជំនាញប្រកបដោយសមាមាត្រភាពយ៉ាងត្រឹមត្រូវនិងជាក់លាក់ ហើយជារឿយៗអាចប្រតិបត្តិការងារដែលប្រគល់ឲ្យដោយឯកកជ្ឈភាព
- ប្រតិបត្តិជំនាញភាគច្រើនអាស្រ័យទៅនឹងការសិក្សាឬការណែនាំច្រើនជាងការពិនិត្យសង្កេត។

ជំនាញចិត្តចលនាទាក់ទងទៅនឹងភាពស្ទាត់ជំនាញខាងហត្ថកម្ម(ធ្វើដោយដៃ), ដែលអនុវត្តភាគច្រើនទៅលើកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ចំពោះការអប់រំឧត្តមសិក្សា អនុវត្តតែទៅ លើកម្មវិធីបណ្តុះបណ្តាលមួយចំនួនប៉ុណ្ណោះ។ ជំនាញចិត្តចលនាមានសារៈសំខាន់ខ្លាំងបំផុតនៅក្នុងអាជីព និងមុខរបរបច្ចេកទេសនិងក្នុងជំនាញមួយចំនួននៅក្នុងការអប់រំឧត្តមសិក្សាទូទៅ។ ឧទាហរណ៍ ធុរជន ការីបរិក្ខារកិច្ច (អ្នកបញ្ជាឧបករណ៍ បរិក្ខាសំខាន់ៗ) ពេទ្យវះកាត់ វិចិត្រករ ឬតន្ត្រីករ ចាំបាច់ត្រូវមានជំនាញចិត្តចលនាកម្រិតខ្ពស់។

ដោយសារជំនាញខាងចិត្តចលនាទាំងនោះ ភាគច្រើនប្រើតែនៅក្នុងជំនាញមួយចំនួននិងមានលក្ខណៈប្រែប្រួលយ៉ាងទូលំទូលាយ លទ្ធផលសិក្សាពឹងទុកសម្រាប់កម្រិតគុណវុឌ្ឍិនីមួយៗ មិនមានពិពណ៌នានៅក្នុងវិស័យអប់រំឧត្តមសិក្សានៃក្របខ័ណ្ឌគុណវុឌ្ឍិឡើយ ថ្វីបើជំនាញចិត្តចលនាទាំងនោះមានរៀបរាប់នៅក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ទោះជាយ៉ាងនេះក្តី គ្រឹះស្ថានណាដែលមានកម្មវិធីបណ្តុះបណ្តាលទាក់ទងនឹងជំនាញចិត្តចលនា គួរតែពិពណ៌នាឲ្យបានច្បាស់លាស់ពីជំនាញនេះនៅក្នុងស្តង់ដានៃលទ្ធផលសិក្សា ហើយវិធីសាស្ត្រនៃការបង្រៀននិងការវាយតម្លៃការសិក្សាគួរតែដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលនិងមុខវិជ្ជាជំនាញ។

## ២.៤ ច្រកសិក្សា

ក.គ.ជ.ក គូសបញ្ជាក់ពីចំណុចត្រួតគ្នានិងការដាក់បញ្ចូលគ្នានៃប្រភេទនិងកម្រិតគុណវុឌ្ឍិផ្សេងគ្នាដែលធ្វើឡើងតាមរយៈវិធានស្តីពីការសន្សំ(ឬការបូកបណ្តាក់) ការផ្ទេរក្រេឌីត ការទទួលស្គាល់ការសិក្សាដែលមានពីមុន យន្តការដែលទាក់ទងនឹងការបំពេញលក្ខខណ្ឌចូលសិក្សាបន្តទៅកម្រិតបណ្តុះបណ្តាលខ្ពស់បន្ទាប់ និងការប្រើប្រាស់វិញ្ញាបនបត្រ និងសញ្ញាបត្រ។

ដោយមានការតភ្ជាប់រវាងគុណវុឌ្ឍិនីមួយៗ ក.គ.ជ.ក ធ្វើឲ្យមានភាពងាយស្រួលក្នុងដំណើរការសិក្សា និងជួយចង្អុលបង្ហាញនិស្សិតពីឱកាសនិងច្រកសិក្សា ដើម្បីបន្តអភិវឌ្ឍការសិក្សារបស់ខ្លួន។ ក.គ.ជ.ក បង្កើតនូវច្រកសិក្សាដែលមានជម្រើសផ្សេងៗគ្នា ជាមួយនឹងច្រកចូលនិងច្រកចេញដែលទទួលស្គាល់លើស្នាដៃឬការសម្រេចបានរបស់បុគ្គលដែលរឹតតែធ្វើឲ្យមានឱកាសចូលសិក្សានិងកាត់បន្ថយពេលវេលា

តាមរយៈការទទួលស្គាល់ការសិក្សាពីមុនមករួមមានការសិក្សាក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងក្រៅឬមិនផ្លូវការ។

ក្របសិក្សានៃ ក.គ.ជ.ក ធ្វើឲ្យមានការសិក្សាពេញមួយជីវិត ព្រោះការផ្តល់ឱកាសឲ្យអ្នកដែលមានចំណេះដឹងនិងជំនាញដែលទទួលបានពីបទពិសោធនិងស្វ័យសិក្សា ត្រូវបានវាយតម្លៃនិងផ្តល់ឱកាសឲ្យទទួលបាននូវគុណវុឌ្ឍិខ្ពស់ទោះជាគេពុំមានគុណវុឌ្ឍិជាមូលដ្ឋានក៏ដោយ។

## ៣. លក្ខណៈនិងលទ្ធផលនៃការសិក្សារំពឹងទុកក្នុងកម្រិតគុណវុឌ្ឍិនីមួយៗ

### ៣.១ ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺផ្តោតលើការពង្រឹងសមត្ថភាពដោយផ្អែកលើលក្ខណវិនិច្ឆ័យដែលមានចែងនៅក្នុងកម្មវិធីបណ្តុះបណ្តាលឬវគ្គសិក្សាដែលមានការទទួលស្គាល់។ គុណវុឌ្ឍិដែលមាននៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺផ្អែកទៅលើសមត្ថភាពដែលបានកំណត់នៅក្នុងកញ្ចប់ឯកសារសិក្សាផ្អែកលើសមត្ថភាពឬកញ្ចប់ឯកសារតេស្តបញ្ជាក់សមត្ថភាពដែលបានអនុម័តឲ្យប្រើប្រាស់ជាផ្លូវការ។

## វិញ្ញាបនបត្រវិជ្ជាជីវៈ

### ក. លក្ខណៈនៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលនេះតម្រូវឲ្យអ្នកសិក្សាអនុវត្តជាក់ស្តែងច្រើនជាងធ្វើបទបង្ហាញនៅក្នុងថ្នាក់រៀនរហូតទាល់តែមានសមត្ថភាពឆ្លើយតបទៅនឹងលក្ខខណ្ឌដែលបានកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាល។ កម្មវិធីបណ្តុះបណ្តាលនេះ តម្រូវឲ្យសិស្សសិក្សាពេញម៉ោងដែលមានរយៈពេល៤ខែឬ៦ខែស្របតាមតម្រូវការជាក់ស្តែងនៃកម្មវិធីបណ្តុះបណ្តាល។

### ខ. លក្ខណៈរបស់បុគ្គលដែលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលបាននូវគុណវុឌ្ឍិកម្រិតនេះត្រូវមាន៖

- ចំណេះដឹងគ្រប់គ្រាន់ក្នុងការអនុវត្តនីតិវិធីនិងបទប្បញ្ញត្តិដែលកំណត់ក្នុងកិច្ចការមុខរបរ
- សមត្ថភាពក្នុងការអនុវត្តកិច្ចការស្របតាមនីតិវិធីឬការណែនាំផ្ទាល់
- សមត្ថភាពបំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវ
- សមត្ថភាពយល់ដឹងដែលឆ្លើយតបតាមការណែនាំនិងនីតិវិធីមូលដ្ឋាន
- សមត្ថភាពក្នុងការប្រមូលព័ត៌មានតាមរយៈផ្ទាល់មាត់និងរបាយការណ៍ជាសំណេរ
- សមត្ថភាពក្នុងការអនុវត្តនីតិវិធីងាយៗ។

បុគ្គលទទួលបាននូវគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- អនុវត្តនីតិវិធី បទប្បញ្ញត្តិ និងប្រើជំនាញរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ
- ធ្វើការជាមួយសហការី និងបំពេញសកម្មភាពការងារដែលកំណត់នៅក្នុងសកម្មភាពមុខងារវិជ្ជាជីវៈ
- ទទួលនិងអនុវត្តតាមការណែនាំរបស់អ្នកគ្រប់គ្រងជាប្រចាំ។

## គ. លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានចំណេះដឹងដែលទាក់ទងទៅនឹងបរិបទការងារអាជីព ដូចជាការអនុវត្តនីតិវិធី បទប្បញ្ញត្តិ និងគោលគំនិតកម្រិតមូលដ្ឋាន។

**ជំនាញក្នុងការគិត៖**

- ប្រើចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាលនិងបទពិសោធការងារតាមលំដាប់លំដោយ។ ចំណេះដឹងទាំងនេះទាក់ទងទៅនឹងសេរីភាពក្នុងការសម្រេចចិត្តរបស់សិស្ស ប៉ុន្តែត្រូវមានសមត្ថភាពអនុវត្តតាមការណែនាំផ្ទាល់របស់អ្នកគ្រប់គ្រង។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- បំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវស្របតាមការណែនាំឬស្របតាមស្តង់ដានីតិវិធីក្នុងបរិបទការងារដែលបានកំណត់។
- មានការទទួលខុសត្រូវចំពោះបរិមាណនិងគុណភាពនៃទិន្នផលរបស់ខ្លួន ប៉ុន្តែមិនមែនជាការទទួលខុសត្រូវលើទិន្នផលរបស់អ្នកដទៃទេ។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- អាចយល់និងឆ្លើយតបទៅនឹងការណែនាំដែលទាក់ទងនឹងកិច្ចការអាជីព
- អាចធ្វើការទាក់ទងតាមរយៈផ្ទាល់មាត់និងសំណេរធម្មតាក្នុងកម្រិតមូលដ្ឋាន ដូចជាការសរសេររបាយការណ៍លើការងារនិងកិច្ចការដែលខ្លួនបានបំពេញដែលជាទម្រង់របាយការណ៍ធម្មតា។

**ជំនាញចិត្តចលនា៖**

- មានជំនាញមូលដ្ឋានក្នុងការប្រើប្រាស់ឧបករណ៍ស្តង់ដាក្នុងកិច្ចការអាជីព ហើយអាចប្រើជំនាញទាំងនេះក្នុងការអនុវត្តនីតិវិធីតាមស្តង់ដា។

## ឃ. ច្រកសិក្សាឬច្រកធ្វើតេស្តដើម្បីទទួលបានគុណវុឌ្ឍិ

**បេក្ខជនទទួលគុណវុឌ្ឍិនេះតាមរយៈ៖**

- ឆ្លងកាត់វគ្គបណ្តុះបណ្តាលរយៈពេលចាប់ពី៤-៦ខែ ដែលមានការទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវហើយប្រឡងសម្រេចបាននូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារសិក្សាផ្អែកលើសមត្ថភាព
- មានវិញ្ញាបនបត្រវិជ្ជាជីវៈតាមរយៈវគ្គបណ្តុះបណ្តាលដែលមិនមានការទទួលស្គាល់ ហើយដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកា ហើយប្រឡងសម្រេចបាននូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារតេស្តសមត្ថភាពដែលបានអនុម័ត

- មានលិខិតបញ្ជាក់ពីប្រធានក្រុមហ៊ុនឬអ្នកគ្រប់គ្រង ថាបានបំពេញការងាររយៈពេល១ឆ្នាំយ៉ាងតិច ហើយត្រូវដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកា ហើយប្រឡងសម្រេចបាននូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារតេស្តសមត្ថភាពដែលបានអនុម័ត
- មានចំណេះដឹងក្នុងការអាន ការសរសេរ និងលេខនព្វន្តស្របទៅនឹងស្តង់ដាកម្រិតមូលដ្ឋាន ហើយសន្សំសម្រេចរាល់ផ្នែកសមត្ថភាព ដែលកំណត់ក្នុងកញ្ចប់ឯកសាសិក្សាផ្អែកលើសមត្ថភាពកម្រិត១ តាមរយៈការបណ្តុះបណ្តាល ឬធ្វើការងារ។

## សញ្ញាបត្រចេ្ចកទេសនិងវិជ្ជាជីវៈ១

### ក. លក្ខណៈនៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលនេះ តម្រូវឲ្យអ្នកសិក្សាអនុវត្តជាក់ស្តែងច្រើនជាងធ្វើបទបង្ហាញនៅក្នុងថ្នាក់រៀនរហូតទាល់តែមានសមត្ថភាពឆ្លើយតបទៅនឹងលក្ខខណ្ឌដែលបានកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាល។ វគ្គនេះតម្រូវឲ្យសិស្សសិក្សារយៈពេល១ឆ្នាំពេញម៉ោងឬតម្លៃស្មើ។

### ខ. លក្ខណៈនៃបុគ្គលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលបានគុណវុឌ្ឍិនេះត្រូវមាន៖

- ចំណេះដឹងបន្ទាប់ពីកម្រិតមូលដ្ឋានក្នុងការអនុវត្តនីតិវិធីនិងបទប្បញ្ញត្តិត្រឹមត្រូវតាមការកំណត់ក្នុងកិច្ចការអាជីព
- អនុវត្តកិច្ចការប្រចាំថ្ងៃតាមនីតិវិធីស្តង់ដាឬក្រោមការណែនាំផ្ទាល់
- សមត្ថភាពបំពេញកិច្ចការប្រកបដោយចរិតទទួលខុសត្រូវ
- សមត្ថភាពយល់ដឹងនិងឆ្លើយតបទៅនឹងការណែនាំនិងនីតិវិធី
- សមត្ថភាពទំនាក់ទំនងព័ត៌មានតាមរយៈផ្ទាល់មាត់ធម្មតានិងរបាយការណ៍ជាសំណេរស្របតាមស្តង់ដា
- សមត្ថភាពជំនាញហត្ថកម្មលើកិច្ចការងាយៗតាមនីតិវិធីកំណត់។

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- ប្រើចំណេះដឹងតាមនីតិវិធីនិងបទប្បញ្ញត្តិ ព្រមទាំងជំនាញហត្ថកម្មប្រកបដោយលក្ខណៈទទួលខុសត្រូវជាក់លាក់
- ចូលរួមសហការនិងបំពេញសកម្មភាពការងារដែលកំណត់ក្នុងកិច្ចការអាជីព
- ទទួលយកនិងអនុវត្តតាមការណែនាំរបស់អ្នកគ្រប់គ្រងក្នុងករណីចាំបាច់
- មានចំណេះដឹងពីវិស័យផ្សេងៗមួយចំនួនក្នុងកម្រិតកំណត់
- មានជំនាញមូលដ្ឋានក្នុងការអនុវត្តជាក់ស្តែងដូចជាការប្រើប្រាស់ឧបករណ៍ពាក់ព័ន្ធមួយចំនួនដែលសមស្រប

- ប្រតិបត្តិកិច្ចការតាមលំដាប់លំដោយនៃការងារទៅតាមទិសដៅដែលបានកំណត់
- ចេះទទួលនិងនាំសារឬព័ត៌មាន។

## គ. លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានចំណេះដឹងលើកម្រិតមូលដ្ឋានទាក់ទងនឹងកិច្ចការអាជីពដែលកំណត់ក្នុងបរិបទការងារ រួមមានការអនុវត្តនីតិវិធី បទប្បញ្ញត្តិមូលដ្ឋាន និងគោលគំនិតខ្លះៗដែលទទួលបានពីការណែនាំនិងការសិក្សា។

**ជំនាញក្នុងការគិត៖**

- អាចប្រើចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាលនិងបទពិសោធការងារក្នុងកិច្ចការដែលមានរចនាសម្ព័ន្ធនិងលំដាប់លំដោយ។ ចំណេះដឹងទាំងនេះទាក់ទងទៅនឹងសេរីភាពក្នុងការសម្រេចចិត្តរបស់បេក្ខជនប៉ុន្តែត្រូវមានសមត្ថភាពឆ្លើយតបតាមការណែនាំផ្ទាល់របស់អ្នកគ្រប់គ្រង។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- អាចបំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវក្រោមការណែនាំឬស្របតាមស្តង់ដានិងនីតិវិធីក្នុងបរិបទការងារដែលបានកំណត់។
- មានការទទួលខុសត្រូវចំពោះបរិមាណនិងគុណភាពនៃលទ្ធផលរបស់ខ្លួន ប៉ុន្តែមិនមែនជាការទទួលខុសត្រូវលើលទ្ធផលរបស់អ្នកដទៃទេ។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- អាចយល់និងឆ្លើយតបទៅនឹងការណែនាំស្តីពីកិច្ចការមុខរបរ
- អាចទាក់ទងតាមរយៈផ្ទាល់មាត់និងសំណេរធម្មតាដែលរួមមានការសរសេររបាយការណ៍ធម្មតាលើកិច្ចការដែលបេក្ខជនបានបំពេញដូចជាការបំពេញទម្រង់របាយការណ៍ធម្មតា។

**ជំនាញចិត្តចលនា៖**

- មានជំនាញខ្ពស់ជាងកម្រិត១ក្នុងការប្រើប្រាស់ឧបករណ៍ជាស្តង់ដាសម្រាប់កិច្ចការអាជីពនិងអាចប្រើជំនាញទាំងនេះក្នុងការអនុវត្តតាមនីតិវិធីដែលមានស្តង់ដាសមស្រប។

## ឃ. ច្រកសិក្សាឬច្រកធ្វើតេស្តដើម្បីទទួលបានគុណវុឌ្ឍិ

បេក្ខជនទទួលគុណវុឌ្ឍិនេះតាមរយៈ៖

- ឆ្លងកាត់វគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំ ដែលមានការទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវ ហើយប្រឡងសម្រេចបាននូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារសិក្សាផ្អែកលើសមត្ថភាព
- មានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ឬវិញ្ញាបនបត្រសមមូល (វគ្គអប់រំមិនផ្លូវការបណ្តុះបណ្តាលរយៈ

ពេល១ឆ្នាំដែលមិនបានទទួលស្គាល់និងចុះបញ្ជិកា)  ហើយដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកា ហើយប្រឡងសម្រេចនូវសមត្ថភាពដែលកំណត់ក្នុងឯកសារតេស្តសមត្ថភាពដែលបានអនុម័ត

- មានវិញ្ញាបនបត្រវិជ្ជាជីវៈ  រួមទាំងបទពិសោធការងាររយៈពេល១ឆ្នាំយ៉ាងតិចនិងបានបញ្ចប់មធ្យមសិក្សាបឋមភូមិឬបានឆ្លងកាត់វគ្គស្ពានចម្លង អាចដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកា ហើយប្រឡងសម្រេចនូវរាល់សមត្ថភាពដែលបានកំណត់ក្នុងកញ្ចប់ឯកសារតេស្តបានអនុម័ត។

រយៈពេលដើម្បីទទួលបានគុណវុឌ្ឍិនេះខុសគ្នាយោងទៅតាមលក្ខខណ្ឌនិងកត្តាដែលទាក់ទងទៅនឹងវិស័យការងារនិងឧស្សាហកម្មណាមួយ។ រចនាសម្ព័ន្ធនៃការបណ្តុះបណ្តាលកម្រិតនេះគឺផ្តល់ឲ្យនិស្សិតនូវជំនាញទូលំទូលាយលើការងារក្នុងវិស័យឧស្សាហកម្មធំៗនិងខុសៗគ្នា។ ដូច្នេះការសិក្សាមានរយៈពេលវែងជាងកម្រិតគុណវុឌ្ឍិដទៃដែលផ្តោតលើជំនាញទីកន្លែងការងារជាក់ស្តែង។

**ឧទាហរណ៍នៃលក្ខខណ្ឌទទួលបានគុណវុឌ្ឍិ៖**

- ការបណ្តុះបណ្តាលផ្អែកលើការងារនិងការវាយតម្លៃសមត្ថភាព
- ការអប់រំ ការបណ្តុះបណ្តាលក្នុងគ្រឹះស្ថាន និងការវាយតម្លៃសមត្ថភាព
- ការអប់រំ  ការបណ្តុះបណ្តាលខ្លះក្នុងគ្រឹះស្ថាន និងការវាយតម្លៃ/បណ្តុះបណ្តាលផ្អែកលើការងារខ្លះ និងការវាយតម្លៃសមត្ថភាព
- ការទទួលស្គាល់ការសិក្សាដែលមានពីមុនឬសមត្ថភាពបច្ចុប្បន្ន
- ការទទួលស្គាល់ការសិក្សាដែលមានពីមុនគួបផ្សំនឹងការបណ្តុះបណ្តាលបន្ថែមយោងតាមតម្រូវការ
- បូកបញ្ចូលវគ្គសិក្សានិងកម្មវិធីបណ្តុះបណ្តាលផ្សេងៗ។

## សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២

### ក. លក្ខណៈនៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលនេះទាក់ទងនឹងកិច្ចការបណ្តុះបណ្តាល រួមមានសកម្មភាពអនុវត្តក្នុងរោងជាងឬបន្ទប់ពិសោធន៍និងការធ្វើបទបង្ហាញក្នុងថ្នាក់រហូតទទួលបានសមត្ថភាពដែលកំណត់ក្នុងកម្មវិធី។  បេក្ខជនដែលបានបញ្ចប់សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២   តម្រូវឲ្យមានការសិក្សារយៈពេលពេញម៉ោង១ឆ្នាំឬតម្លៃស្មើ។

### ខ. លក្ខណៈនៃបុគ្គលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលបានគុណវុឌ្ឍិនេះត្រូវមាន៖

- ចំណេះដឹងលើកិច្ចការប្រតិបត្តិដោយអនុវត្តតាមស្តង់ដាសមស្របនិងគោលគំនិតជាមូលដ្ឋានមួយចំនួនដែលបានកំណត់ក្នុងកិច្ចការអាជីព
- សមត្ថភាពអនុវត្តចំណេះដឹងនិងនីតិវិធីស្របតាមស្តង់ដាក្នុងស្ថានភាពលំនឹងមួយក្នុងការដោះស្រាយ

បញ្ហាដែលអាចគិតទុកមុន

- សមត្ថភាពបំពេញកិច្ចការមិនប្រក្រតីមួយចំនួននិងអនុវត្តនីតិវិធីស្របតាមស្តង់ដាក្នុងការដោះស្រាយបញ្ហាប្រកបដោយចរិតទទួលខុសត្រូវ
- សមត្ថភាពទទួលខុសត្រូវខ្លួនឯងឬជាមួយអ្នកដទៃចំពោះគុណភាពនិងបរិមាណនៃទិន្នផល
- សមត្ថភាពយល់ បកស្រាយ ផ្តល់ព័ត៌មានដែលបានរកឃើញ និងវិភាគទិន្នន័យទាក់ទងនឹងកិច្ចការអាជីពតាមរយៈគណិតវិទ្យានិងស្ថិតិ
- ការប្រើប្រាស់ឧបករណ៍ សម្ភារ និងបច្ចេកទេសប្រកបដោយសុវត្ថិភាពនិងទទួលខុសត្រូវ
- ស្នាដៃវិសេសក្នុងការប្រតិបត្តិសកម្មភាព វិធីសាស្ត្រ នីតិវិធីក្នុងកាលៈទេសៈដែលការសម្រេចចិត្តក្នុងការជ្រើសរើសឧបករណ៍ សេវាកម្ម ឬវិធានការក្នុងពេលកំណត់
- ចំណេះដឹងនិងសមត្ថភាពដែលមានលក្ខណៈស្មុគស្មាញនិងស៊ីជម្រៅក្នុងការផ្ទេរជំនាញ
- ចំណេះដឹងដល់សង្គម ផ្តល់ប្រឹក្សាបច្ចេកទេស ភាពជាអ្នកដឹកនាំក្នុងការដោះស្រាយបញ្ហាក្នុងបរិបទខុសៗគ្នាដែលមានលក្ខណៈស្មុគស្មាញ
- ការអនុវត្តដូចជាការទទួលខុសត្រូវមួយចំនួនចំពោះអ្នកដទៃ ការធ្វើការជាក្រុមឬដឹកនាំសម្រប-សម្រួលក្នុងក្រុម។

**បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖**

- អនុវត្តចំណេះដឹងនិងជំនាញប្រកបដោយការទទួលខុសត្រូវជាក់លាក់តាមរយៈនីតិវិធីស្របតាមស្តង់ដាក្នុងការដោះស្រាយបញ្ហាដែលអាចដឹងមុន
- បង្ហាញការអភិវឌ្ឍនៃការយល់ដឹងលើគោលការណ៍និងគំនិតទាក់ទងទៅនឹងកិច្ចការអាជីពនិងធ្វើការផ្លាស់ប្តូរតាមនីតិវិធីក្នុងស្ថានភាពប្រែប្រួល
- ធ្វើការជាមួយអ្នកដទៃនិងទទួលខុសត្រូវចំពោះគុណភាពនិងបរិមាណការងារជាឯកត្តបុគ្គលនិងក្រុមការងារ
- ទទួលខុសត្រូវនិងអនុវត្តការងារប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព
- មានចំណេះដឹងមូលដ្ឋានក្នុងការប្រតិបត្តិការងារក្នុងលំដាប់មួយដែលជឿនលឿន
- ចេះអនុវត្តជំនាញដែលបានកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាល
- ចេះរកដំណោះស្រាយបញ្ហាដែលអាចដឹងមុនមួយចំនួន
- ចេះប្រតិបត្តិកិច្ចការក្នុងស្ថានភាពមួយដែលមានជម្រើសនិងមានដែនកំណត់
- ចេះវាយតម្លៃនិងប្រមូលព័ត៌មានពីប្រភពផ្សេងៗ
- ទទួលខុសត្រូវចំពោះទិន្នផលការងារនិងសិក្សារបស់ខ្លួន។

## គ. លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានចំណេះដឹងលើកិច្ចការមុខរបរ ការអនុវត្តស្តង់ដា និងនីតិវិធី រួមមានការយល់ដឹងមូលដ្ឋានទ្រឹស្តីសំខាន់ៗ។ អាចអនុវត្តចំណេះដឹងនេះស្របទៅតាមបម្រែបម្រួលនៃបរិបទ

**ជំនាញក្នុងការគិត៖**

- អាចយល់ពីបញ្ហានិងបរិបទក្នុងការរកដំណោះស្រាយបញ្ហា។ ជំនាញនេះទាក់ទិននឹងការយល់និងសមត្ថភាពក្នុងការពិចារណាដើម្បីរកនីតិវិធីដែលឆ្លើយតបទៅនឹងកិច្ចការឬបញ្ហា ប៉ុន្តែមិនចាំបាច់អភិវឌ្ឍគំនិតឬដំណោះស្រាយថ្មីទេ។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- បំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវក្រោមការណែនាំបន្តិចបន្តួចនិងទទួលខុសត្រូវខ្លួនឯងចំពោះទិន្នផល
- អាចធ្វើការសហការជាមួយអ្នកដទៃនិងចែករំលែកការទទួលខុសត្រូវចំពោះការជឿទុកចិត្តគុណភាពនិងបរិមាណនៃទិន្នផល។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- អាចបកស្រាយ ពន្យល់ និងផ្ទេរព័ត៌មាន ដែលទាក់ទងទៅនឹងកិច្ចការអាជីពដូចជាសេចក្តីណែនាំដើម្បីកែប្រែនីតិវិធីស្របតាមស្តង់ដា
- អាចផ្សព្វផ្សាយព័ត៌មានដែលទាក់ទងទៅនឹងកិច្ចការច្បាស់លាស់
- អាចវិភាគទិន្នន័យដោយប្រើគណិតវិទ្យានិងស្ថិតិសាមញ្ញៗព្រមទាំងអាចបកស្រាយទិន្នន័យ។

**ជំនាញចិត្តចលនា៖**

- ប្រើប្រាស់ឧបករណ៍ស្តង់ដា សម្ភារ និងនីតិវិធីប្រកបដោយសុវត្ថិភាព
- អាចប្រើប្រាស់ឧបករណ៍តាមវិធីដែលបានមកពីការបណ្តុះបណ្តាលនិងបទពិសោធការងារ។

## ឃ. ច្រកសិក្សាឬច្រកធ្វើតេស្តដើម្បីទទួលបានគុណវុឌ្ឍិ

**បេក្ខជនទទួលបានគុណវុឌ្ឍិនេះតាមរយៈ៖**

- បានបញ្ចប់ឆ្នាំទី២នៃកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ដែលបានទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវ ហើយប្រឡងសម្រេចនូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារសិក្សាផ្អែកលើសមត្ថភាពដែលបានអនុម័តរួច
- មានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ឬសញ្ញាបត្រសមមូល វគ្គមិនបានទទួលស្គាល់និងចុះបញ្ជិកា ហើយដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកាហើយប្រឡងសម្រេចនូវសមត្ថភាពដែលកំណត់ក្នុងឯកសារតេស្តសមត្ថភាពដែលបានអនុម័ត
- មានគុណវុឌ្ឍិសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ វគ្គដែលទទួលស្គាល់ រួមទាំងបទពិសោធការងាររយៈពេល២ឆ្នាំលើមុខជំនាញដដែល ហើយដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកា ហើយប្រឡងសម្រេចនូវសមត្ថភាពដែលកំណត់ក្នុងឯកសារតេស្តសមត្ថភាពដែលបានអនុម័ត។

រយៈពេលក្នុងការទទួលបានគុណវុឌ្ឍិនេះខុសគ្នា យោងទៅតាមលក្ខខណ្ឌក្នុងវិស័យការងារនិងឧស្សាហកម្មណាមួយ។ រយៈពេលអាចត្រូវបានកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាលដែលជាផ្នែកមួយនៃសមាសភាគយុទ្ធសាស្ត្រសិក្សានៃកម្មវិធីបណ្តុះបណ្តាលឬកំណត់នៅក្នុងពាក្យសុំការទទួលស្គាល់ប៉ុន្តែមិនត្រូវប្រើសម្រាប់កំណត់កម្រិតគុណវុឌ្ឍិនោះទេ។

ឧទាហរណ៍នៃលក្ខខណ្ឌទទួលបានគុណវុឌ្ឍិ៖

- ការបណ្តុះបណ្តាលផ្អែកលើការងារនិងការវាយតម្លៃសមត្ថភាព
- ការអប់រំ ការបណ្តុះបណ្តាលក្នុងគ្រឹះស្ថាន និងការវាយតម្លៃសមត្ថភាព
- ការអប់រំ ការបណ្តុះបណ្តាលខ្លះក្នុងគ្រឹះស្ថាន និងការវាយតម្លៃ/បណ្តុះបណ្តាលផ្អែកលើការងារខ្លះ និងការវាយតម្លៃសមត្ថភាព
- ការទទួលស្គាល់ការសិក្សាដែលមានពីមុនឬសមត្ថភាពបច្ចុប្បន្ន
- ការទទួលស្គាល់ការសិក្សាដែលមានពីមុនគួបផ្សំនឹងការបណ្តុះបណ្តាលបន្ថែមតាមតម្រូវការ
- បូកបញ្ចូលវគ្គសិក្សានិងកម្មវិធីបណ្តុះបណ្តាលផ្សេងៗ។

## សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣

### ក. លក្ខណៈនៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលនេះទាក់ទងនឹងកិច្ចការបណ្តុះបណ្តាល រួមមានសកម្មភាពក្នុងរោងជាងឬបន្ទប់ពិសោធន៍និងការធ្វើបទបង្ហាញក្នុងថ្នាក់រហូតដល់បេក្ខជនទទួលបានសមត្ថភាពដែលកំណត់ក្នុងកម្មវិធី។ ចំពោះបេក្ខជនដែលបានបញ្ចប់គុណវុឌ្ឍិកម្រិត៤ តម្រូវឲ្យសិក្សានិងធ្វើការពេញម៉ោងរយៈពេល១ឆ្នាំឬសមមូលបន្ទាប់ពីទទួលបានគុណវុឌ្ឍិកម្រិត៣ គុណវុឌ្ឍិនេះមានតម្លៃស្មើនឹង៣០ក្រេឌីតយ៉ាងតិច។

### ខ. លក្ខណៈនៃបុគ្គលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលបានគុណវុឌ្ឍិនេះត្រូវមាន៖

- ចំណេះដឹងទូលំទូលាយលើកិច្ចការនិងការអនុវត្តនីតិវិធីដែលទាក់ទងនឹងអាជីពរួមមានការយល់ដឹងពីទ្រឹស្តីសំខាន់ៗ
- សមត្ថភាពជ្រើសរើសនិងសំយោគនូវដំណើរការ សម្ភារ ឧបករណ៍ផ្សេងៗ ដែលស្របតាមបរិបទការងារនិងបញ្ហាដែលអាចដឹងមុន
- ស្វ័យអភិវឌ្ឍសមត្ថភាពក្នុងការដឹកនាំខ្លួនឯង ឆ្លើយតបទៅនឹងកិច្ចការខុសៗគ្នាប្រកបដោយការទទួលខុសត្រូវខ្លួនឯងយ៉ាងពេញលេញនិងទទួលខុសត្រូវចំពោះទិន្នផលរបស់អ្នកដទៃ
- សមត្ថភាពស្វែងរក បកស្រាយ និងប្រើប្រាស់ព័ត៌មានជាក្រាភិច ជាលេខ និងសំណេរនិងការប្រើព័ត៌មានដើម្បីបង្កើតការណែនាំ ព្រមទាំងការធ្វើបទបង្ហាញច្បាស់លាស់និងងាយយល់
- មានសមត្ថភាពរកដំណោះស្រាយបញ្ហា
- សមត្ថភាពប្រើប្រាស់ឧបករណ៍ដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញក្រោមការណែនាំ

- ចំណេះដឹងនិងសមត្ថភាព ដែលមានលក្ខណៈស្មុគស្មាញនិងស៊ីជម្រៅក្នុងការផ្ទេរជំនាញនិងចំណេះដឹងពីមុខរបរមួយទៅមុខរបរមួយទៀតក្នុងបរិស្ថានការងារថ្មី ផ្តល់ប្រឹក្សាបច្ចេកទេស ភាពជាអ្នកដឹកនាំក្នុងការដោះស្រាយបញ្ហាក្នុងបរិបទខុសៗគ្នាដែលមានលក្ខណៈស្មុគស្មាញ។

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- ចេះប្រើចំណេះដឹងនិងជំនាញក្នុងការជ្រើសរើសយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាក្នុងការងារដើម្បីបង្កើនសុវត្ថិភាព ទិន្នផល និងគុណភាព
- យល់ដឹងពីនីតិវិធីដែលផ្អែកលើគោលការណ៍និងបទប្បញ្ញត្តិសំខាន់ៗ ចេះជ្រើសរើសនីតិវិធីស្របតាមកាលៈទេសៈនិងសភាពការណ៍
- មានសមត្ថភាពធ្វើការជាក្រុម រួមចំណែកទទួលខុសត្រូវចំពោះគុណភាពនិងបរិមាណនៃទិន្នផលរបស់ក្រុមនិងជួយគាំទ្រដើម្បីបង្កើនប្រសិទ្ធភាព
- មានចំណេះដឹងខាងទ្រឹស្តី
- អនុវត្តជំនាញដែលបានអភិវឌ្ឍ
- អនុវត្តនីតិវិធីដោយប្រើជំនាញដែលបានអភិវឌ្ឍនិងតាមសមត្ថភាពផ្ទាល់ខ្លួន
- អនុវត្តជំនាញយ៉ាងទូលំទូលាយទាក់ទងនឹងសកម្មភាពដូចជាការងារប្រចាំថ្ងៃ វិធីសាស្ត្រ និងនីតិវិធីដែលតម្រូវឲ្យមានការជ្រើសរើសឧបករណ៍ សេវាកម្ម ឬវិធានការក្នុងពេលវេលាមួយកំណត់
- បកស្រាយព័ត៌មានដោយប្រើសមត្ថភាពផ្ទាល់ខ្លួន
- ការទទួលខុសត្រូវចំពោះអ្នកដទៃ។

## គ. លទ្ធផលសិក្សា

### ចំណេះដឹង៖

- មានចំណេះដឹងទូលំទូលាយលើកិច្ចការអាជីពនិងដំណើរការនិងអាចប្រើចំណេះដឹងអនុវត្តការងារប្រចាំថ្ងៃនិងការងារថ្មីដែលមិនធ្លាប់ជួបប្រទះ។ ចំណេះដឹងនេះមានដូចជាគោលគំនិតមូលដ្ឋាននិងទ្រឹស្តីក្នុងការអនុវត្តការងារទាំងអស់នេះ។

### ជំនាញក្នុងការគិត៖

- អាចរកដំណោះស្រាយចំពោះបញ្ហាផ្សេងៗក្នុងស្ថានភាពដែលធ្លាប់ជួបប្រទះនិងមិនដែលជួបប្រទះ អាចសំយោគជំនាញ បច្ចេកទេស សម្ភារៈ និងឧបករណ៍ ដើម្បីអនុវត្តកិច្ចការជួបប្រទះរាល់ថ្ងៃនិងមិនដែលជួបប្រទះមួយចំនួន។

### ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖

- ទទួលខុសត្រូវចំពោះភារកិច្ចក្នុងកន្លែងការងារ ដឹកនាំខ្លួនឯងក្នុងការអនុវត្តការងារប្រកបដោយការយកចិត្តទុកដាក់និងស្របតាមការកំណត់ក្នុងភារកិច្ច
- ទទួលខុសត្រូវចំពោះគុណភាពនិងបរិមាណការងាររបស់ខ្លួន ផ្តល់ភាពជាអ្នកដឹកនាំនិងការសម្រេច

ចិត្តនិងទទួលខុសត្រូវចំពោះលទ្ធផលរបស់អ្នកដទៃ

- មានការទទួលខុសត្រូវនិងផ្តើមគំនិតដើម្បីបង្កើនជំនាញអាជីពរបស់ខ្លួន។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- អាចស្វែងយល់បកស្រាយព័ត៌មានពាក់ព័ន្ធ និងប្រើព័ត៌មាននេះក្នុងដំណើរការការងារ ដើម្បីបង្កើនប្រសិទ្ធផលនិងសុវត្ថិភាព។ ព័ត៌មាននេះមានដូចជា ក្រាភិច លេខ និងសំណេរ
- អាចប្រមូលព័ត៌មាននិងធ្វើបទបង្ហាញយ៉ាងច្បាស់លាស់តាមរយៈ ក្រាភិច សំណេរ និងផ្ទាល់មាត់។

**ជំនាញចិត្តចលនា៖**

- ចេះបញ្ជាដំណើរការឧបករណ៍ ដែលមានលក្ខណៈបច្ចេកទេសស្មុគស្មាញនិងប្រតិបត្តិកិច្ចការជួបប្រទះប្រចាំថ្ងៃនិងមិនដែលជួបប្រទះមួយចំនួន។ ជំនាញនេះមានដូចជាសមត្ថភាពក្នុងការជ្រើសរើសប្រើប្រាស់ និងតម្រូវឧបករណ៍ បរិក្ខារ និងសម្ភាររួមទាំងដំណើរការស្របតាមកិច្ចការផ្សេងៗគ្នា។

## ឃ. ច្រកសិក្សាឬច្រកធ្វើតេស្តដើម្បីទទួលបានគុណវុឌ្ឍិ

**បេក្ខជនទទួលគុណវុឌ្ឍិនេះតាមរយៈ៖**

- បានបញ្ចប់ឆ្នាំទី៣ កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ដែលបានទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវ ហើយប្រឡងសម្រេចនូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារសិក្សាផ្អែកលើសមត្ថភាពដែលបានអនុម័តរួច
- មានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ វគ្គមិនបានទទួលស្គាល់និងចុះបញ្ជិកា ហើយដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកា ហើយប្រឡងសម្រេចនូវសមត្ថភាពដែលកំណត់ក្នុងឯកសារតេស្តសមត្ថភាពដែលបានអនុម័តនឹងទទួលបាននូវគុណវុឌ្ឍិជាតិកម្រិតនេះ
- មានគុណវុឌ្ឍិសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ២ វគ្គដែលទទួលស្គាល់ រួមទាំងបទពិសោធការងាររយៈពេល២ឆ្នាំលើមុខជំនាញដដែល ហើយដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកា ហើយប្រឡងសម្រេចនូវសមត្ថភាពដែលកំណត់ក្នុងឯកសារតេស្តសមត្ថភាពដែលបានអនុម័ត។

រយៈពេលក្នុងការទទួលបានគុណវុឌ្ឍិខុសគ្នា ដោយយោងទៅតាមតម្រូវការរបស់ឧស្សាហកម្មឬការងារណាមួយ។ រយៈពេលអាចត្រូវបានកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាលដែលជាផ្នែកមួយនៃសមាសភាគយុទ្ធសាស្ត្រសិក្សានៃកម្មវិធីបណ្តុះបណ្តាលឬកំណត់នៅក្នុងពាក្យសុំការទទួលស្គាល់ ប៉ុន្តែមិនត្រូវប្រើសម្រាប់កំណត់កម្រិតគុណវុឌ្ឍិនោះទេ។

**ឧទាហរណ៍នៃលក្ខខណ្ឌទទួលបានគុណវុឌ្ឍិ៖**

- ការបណ្តុះបណ្តាលផ្អែកលើការងារនិងការវាយតម្លៃសមត្ថភាព
- ការអប់រំ ការបណ្តុះបណ្តាលក្នុងគ្រឹះស្ថាន និងការវាយតម្លៃសមត្ថភាព

- ការអប់រំ ការបណ្តុះបណ្តាលខ្លះក្នុងគ្រឹះស្ថាន និងការវាយតម្លៃ/បណ្តុះបណ្តាលផ្អែកលើការងារខ្លះ និងការវាយតម្លៃសមត្ថភាព
- ការទទួលស្គាល់ចំណេះដឹងមុនចូលរៀន
- ការទទួលស្គាល់ការសិក្សាដែលមានពីមុនគួបផ្សំនឹងការបណ្តុះបណ្តាលបន្ថែមតាមតម្រូវការ
- បូកបញ្ចូលវគ្គសិក្សានិងកម្មវិធីបណ្តុះបណ្តាលផ្សេងៗ។

## សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស

### ក. លក្ខណៈនៃកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលរួមមានការបណ្តុះបណ្តាលបច្ចេកទេសជាក់ស្តែង ដូចជាធ្វើបទបង្ហាញក្នុងថ្នាក់ អនុវត្តក្នុងរោងជាង បន្ទប់ពិសោធន៍ កម្មសិក្សា និងបទពិសោធការងារ រហូតទាល់តែបេក្ខជនទទួលបាន សមត្ថភាពដែលបានកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាល។ បេក្ខជនដែលបានបញ្ចប់ការសិក្សាគុណវុឌ្ឍិ កម្រិត៤ឬកម្រិតមធ្យមសិក្សាទុតិយភូមិ តម្រូវឲ្យសិក្សានិងអនុវត្តការងារពេញម៉ោងរយៈពេល២ឆ្នាំឬ សមមូលដែលមានចំនួនក្រេឌីតតម្រូវឲ្យសិក្សាយ៉ាងតិច៦០ក្រេឌីតឬច្រើនជាងគុណវុឌ្ឍិកម្រិត៤ ចំនួន ៣០ក្រេឌីត។

### ខ. លក្ខណៈនៃបុគ្គលដែលទទួលគុណវុឌ្ឍិ

**បុគ្គលទទួលបានគុណវុឌ្ឍិនេះត្រូវមាន៖**

- ចំណេះដឹងទូលំទូលាយទាក់ទងនឹងអាជីព ឧស្សាហកម្ម និងទ្រឹស្តីពាក់ព័ន្ធនឹងការងារ ព្រមទាំង បច្ចេកវិទ្យាថ្មីក្នុងអាជីពរបស់ខ្លួន
- សមត្ថភាពអនុវត្តចំណេះដឹងក្នុងបរិបទផ្សេងៗ ចេះផ្ទេរ និងប្រើចំណេះដឹងក្នុងការដោះស្រាយបញ្ហា
- សមត្ថភាពដឹកនាំខ្លួនឯង ភាពជាអ្នកដឹកនាំក្នុងក្រុមការងារ និងគណនេយ្យភាព ព្រមទាំងការ ទទួលខុសត្រូវក្នុងការអភិវឌ្ឍជំនាញ
- សមត្ថភាពប្រើស្ថិតិ គណិតវិទ្យាក្នុងការវិភាគ ដោះស្រាយបញ្ហា សំយោគ និងធ្វើបទបង្ហាញ ព័ត៌មានតាមរបៀបផ្សេងៗ
- ជំនាញស្មុគស្មាញនិងការប្រែប្រួលទៅតាមកិច្ចការដែលស្មុគស្មាញនិងថ្មីៗ ហើយប្រើប្រាស់ឧបករណ៍ បរិក្ខារទំនើបៗ និងមានលក្ខណៈបច្ចេកទេសខ្ពស់
- សមត្ថភាពចូលរួមផ្តល់វិភាគទានចំពោះការអភិវឌ្ឍផែនការថវិកាឬយុទ្ធសាស្ត្រពាក់ព័ន្ធនឹងគណនេយ្យ-ភាព ការទទួលខុសត្រូវលើខ្លួនឯងនិងអ្នកដទៃក្នុងការសម្រេចលទ្ធផល
- ចំណេះដឹងទូលំទូលាយក្នុងការវិភាគវិនិច្ឆ័យគម្រោងផែនការ ការប្រតិបត្តិ ការវាយតម្លៃបច្ចេកទេស និងការគ្រប់គ្រងដូចជាការបង្កើតលក្ខណវិនិច្ឆ័យឬការអនុវត្ត ឬចំណេះដឹងឬនីតិវិធី ការអនុវត្តដូច ជាការវិនិច្ឆ័យលើផែនការគម្រោងការបច្ចេកទេសឬភាពជាអ្នកដឹកនាំពាក់ព័ន្ធនឹងផលិតផល សេវា-កម្ម ឬគោលការណ៍ ឬនីតិវិធី។

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- ប្រើចំណេះដឹងដ៏ទូលំទូលាយក្នុងមុខរបររបស់ខ្លួន ដូចជាគោលការណ៍ទ្រឹស្តីពាក់ព័ន្ធនឹងដំណើរការ និងទិន្នផល។ ចំណេះដឹងនេះ រួមមានការអនុវត្តនិងការប្រែប្រួលនៃជំនាញស្របទៅតាមបច្ចេកវិទ្យាថ្មីនិងកែតម្រូវដំណើរការការងារ
- ប្រើចំណេះដឹងនិងជំនាញដូចជាលេខនិងស្ថិតិ ដើម្បីវិភាគដំណោះស្រាយដោយប្រើគំនិតថ្មីនិងផ្ទេរចំណេះដឹងក្នុងស្ថានភាពការងារថ្មីៗ
- បង្ហាញពីភាពជាអ្នកដឹកនាំក្នុងការដឹកនាំក្រុមការងារដោយមានប្រសិទ្ធភាពនិងដោយការទទួលខុសត្រូវខ្ពស់ចំពោះគុណភាព សង្គតិភាពនៃដំណើរការការងារនិងទិន្នផល
- ផ្ទេរព័ត៌មានដ៏ស្មុគស្មាញបានត្រឹមត្រូវច្បាស់លាស់និងទាន់ពេលវេលា
- ប្រើប្រាស់ឧបករណ៍បច្ចេកទេសមានលក្ខណៈស្មុគស្មាញប្រកបដោយការប៉ិនប្រសប់ខ្ពស់ ត្រឹមត្រូវតាមស្តង់ដាសុវត្ថិភាព ព្រមទាំងផ្តល់ការណែនាំដោយមានប្រសិទ្ធភាពចំពោះអ្នករួមការងារក្នុងកិច្ចការស្រដៀងគ្នា
- យល់ពីជំនាញច្បាស់លាស់ ចេះវិភាគ វិនិច្ឆ័យ រៀបចំ និងប្រតិបត្តិកិច្ចការពាក់ព័ន្ធនឹងមុខងារគ្រប់គ្រងនិងបច្ចេកទេស
- អនុវត្តគោលការណ៍និងបច្ចេកទេសសំខាន់ៗក្នុងបរិបទដែលប្រែប្រួលមិនអាចទស្សទាយទុកមុន
- បង្កើតគំនិតតាមរយៈការវិភាគព័ត៌មាននិងគោលគំនិតប្រកបដោយអរូបិយ
- បង្ហាញនូវសមត្ថភាពបច្ចេកទេស ច្នៃប្រឌិត ឬជំនាញប្រកបដោយប្រឌិតញាណ
- បង្ហាញពីគណនេយ្យភាពយ៉ាងទូលំទូលាយចំពោះទិន្នផលផ្ទាល់ខ្លួននិងលទ្ធផលជាក្រុម។

## គ. លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានចំណេះដឹងទូលំទូលាយក្នុងលក្ខខណ្ឌបច្ចេកទេសនិងដំណើរការឧស្សាហកម្ម មានដូចជាចំណេះដឹងអាចប្រែប្រួលទៅតាមបច្ចេកវិទ្យាថ្មីៗ
- យល់ដឹងច្បាស់លាស់ពីនីតិវិធី គោលការណ៍ និងទ្រឹស្តីពាក់ព័ន្ធនឹងឧស្សាហកម្ម។

**ជំនាញក្នុងការគិត៖**

- ចេះអនុវត្តចំណេះដឹងក្នុងស្ថានភាពស្មុគស្មាញនិងវិភាគព័ត៌មានពីប្រភពផ្សេងៗ ដើម្បីធ្វើផែនការនិងអនុវត្តដំណោះស្រាយផែនការប្រកបដោយគំនិតច្នៃប្រឌិត
- អាចផ្ទេរនិងសម្របសម្រួលចំណេះដឹងតាមបរិបទការងារ។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- អាចដឹកនាំនិងណែនាំសកម្មភាពការងារជាក្រុម។ ទទួលខុសត្រូវចំពោះទិន្នផលការងារខ្លួនឯងនិងអ្នកដទៃក្នុងការងារ

- ចេះផ្តើមគំនិតពង្រីកចំណេះដឹងបច្ចេកទេសនិងអាជីពអ្នកដទៃទៀត ព្រមទាំងអាចគាំទ្រការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនិងអ្នករួមការងារដទៃទៀត។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- អាចប្រើវិធីស្ថិតិនិងលេខក្នុងការរៀបចំវាយតម្លៃនិងរបាយការណ៍លើសកម្មភាពការងារ ព្រមទាំងរិះរកដំណើរការថ្មីដែលស្របទៅនឹងស្ថានភាពការងារ
- ចេះសំយោគព័ត៌មានជាក្រាភិច លេខ សំណេរ ផ្ទាល់មាត់ និងធ្វើបទបង្ហាញការសន្និដ្ឋានដោយត្រឹមត្រូវនិងច្បាស់លាស់។

**ជំនាញចិត្តចលនា៖**

- មានជំនាញក្នុងការប្រើប្រាស់ឧបករណ៍បច្ចេកទេសទំនើបពាក់ព័ន្ធនឹងឧស្សាហកម្មនិងធ្វើការវិនិច្ឆ័យត្រឹមត្រូវតាមលក្ខខណ្ឌការងារផ្សេងៗគ្នា
- អាចប្រើជំនាញនេះស្របតាមបច្ចេកវិទ្យានិងការប្រើប្រាស់ថ្មី។

## ឃ. ច្រកសិក្សាដើម្បីទទួលបានគុណវុឌ្ឍិ

បេក្ខជនទូទៅត្រូវរៀនចប់មធ្យមសិក្សាទុតិយភូមិ(ប្រឡងធ្លាក់ថ្នាក់ទី១២) សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣(កម្រិត៤) វិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឬ សញ្ញាបត្រដែលមានតម្លៃស្មើ។ ចំពោះបេក្ខជនដែលមានវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានតម្រូវឲ្យមានការផ្ទេរក្រេឌីត។

**បេក្ខជនទទួលបានគុណវុឌ្ឍិនេះតាមរយៈ៖**

- បានបញ្ចប់វគ្គសិក្សារយៈពេល២ឆ្នាំ កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស ដែលបានទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវ ហើយប្រឡងសម្រេចនូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ ឯកសារសិក្សាផ្អែកលើសមត្ថភាពដែលបានអនុម័តរួច
- មានសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេសសិក្សារយៈពេល២ឆ្នាំ (វគ្គមិនបានទទួលស្គាល់) ហើយដាក់ពាក្យធ្វើតេស្តបញ្ជាក់សមត្ថភាពនៅមជ្ឈមណ្ឌលធ្វើតេស្តដែលបានទទួលស្គាល់និងចុះបញ្ជិកាហើយប្រឡងសម្រេចនូវសមត្ថភាពដែលកំណត់ក្នុងឯកសារតេស្តសមត្ថភាពដែលបានអនុម័ត
- អ្នកទទួលបាននូវគុណវុឌ្ឍិសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣ ហើយមានបទពិសោធការងាររយៈពេល៣ឆ្នាំយ៉ាងតិចលើមុខជំនាញដដែល អនុញ្ញាតឲ្យធ្វើតេស្តចូលរៀនកម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស ដែលបានទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវ តាមរយៈការទទួលស្គាល់ការសិក្សាពីមុន។ ប្រការនេះបេក្ខជនត្រូវសិក្សាតែក្រេឌីតដែលនៅសល់ប៉ុណ្ណោះ ហើយប្រឡងសម្រេចនូវសមត្ថភាព ដែលកំណត់ក្នុងឯកសារតេស្តសមត្ថភាពដែលបានអនុម័ត។

រយៈពេលដើម្បីទទួលបានគុណវុឌ្ឍិនេះខុសគ្នាយោងទៅតាមលក្ខខណ្ឌនិងកត្តាដែលទាក់ទងទៅនឹងវិស័យការងារក្នុងឧស្សាហកម្មណាមួយ។ រយៈពេលបណ្តុះបណ្តាលនេះអាចបញ្ចូលក្នុងការដាក់ពាក្យសុំ

ការទទួលស្គាល់ ប៉ុន្តែមិនត្រូវបានប្រើប្រាស់ ដើម្បីកំណត់កម្រិតគុណវុឌ្ឍិ។ បេក្ខជនដែលបំពេញលក្ខខណ្ឌ សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស អាចបន្តការសិក្សាគុណវុឌ្ឍិបរិញ្ញាបត្រ បច្ចេកវិទ្យា/ឯកទេស(កម្រិត៦)។

បេក្ខជនមានបំណងបន្តការសិក្សាឧត្តមសិក្សាត្រូវ៖

- បំពេញលក្ខខណ្ឌដែលកំណត់ដោយសាកលវិទ្យាល័យឬគ្រឹះស្ថានឧត្តមសិក្សាដែលមានការទទួលស្គាល់គុណភាពអប់រំ
- ការទទួលស្គាល់ការសិក្សាដែលមានពីមុន ដូចជាការផ្ទេរក្រេឌីត។

ឧទាហរណ៍នៃការទទួលបានគុណវុឌ្ឍិមាន៖

- ការបណ្តុះបណ្តាលផ្អែកលើការងារនិងការវាយតម្លៃសមត្ថភាព
- ការអប់រំនិងបណ្តុះបណ្តាលក្នុងគ្រឹះស្ថាន និងការវាយតម្លៃសមត្ថភាព
- ការអប់រំនិងបណ្តុះបណ្តាលផ្អែកលើផ្នែកខ្លះនៃគ្រឹះស្ថាននិងការវាយតម្លៃ/បណ្តុះបណ្តាលផ្អែកលើផ្នែកខ្លះនៃការងារនិងការវាយតម្លៃសមត្ថភាព
- ការទទួលស្គាល់ការសិក្សាដែលមានពីមុន
- ការទទួលស្គាល់ការសិក្សាដែលមានពីមុននិងការបណ្តុះបណ្តាលបន្ថែមតាមតម្រូវការបូកបន្ថែមវគ្គ និងកម្មវិធីបណ្តុះបណ្តាលខ្លីៗ។

## បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ

### ក. លក្ខណៈកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ គឺមានលក្ខណៈជាប្រព័ន្ធ និងជាការបង្ហាញបន្តបន្ទាប់នូវចំណេះដឹង គំនិត គោលការណ៍ ទស្សនៈ សំខាន់ជាងគេគឺវិធីសាស្ត្រស្រាវជ្រាវនិងបច្ចេកទេសដោះស្រាយបញ្ហាទៅលើប្រធានបទចម្បងៗដែលបានទទួលស្គាល់។ ក្នុងកម្រិតនេះសំខាន់ គឺអភិវឌ្ឍជំនាញទ្រឹស្តីទូទៅ ដើម្បីដំណើរការសិក្សាស្រាវជ្រាវឲ្យស៊ីជម្រៅវាយតម្លៃព័ត៌មានថ្មីៗ គោលគំនិត ទស្សនៈ និងកស្តុតាងនានាដែលចេញពីប្រភពទូទៅក្នុងប្រធានបទចម្បងៗនៃកម្រិតបរិញ្ញាបត្រ។ បេក្ខជនត្រូវសិក្សាយ៉ាងតិច១២០ក្រេឌីតនៅក្រោយមធ្យមសិក្សាដែលមានរយៈពេល៤ឆ្នាំឬសមមូល។

កម្មវិធីបរិញ្ញាបត្រមច្ចេកវិទ្យា/ឯកទេស ត្រូវបានរៀបចំឡើងដើម្បីអភិវឌ្ឍចំណេះដឹងក្នុងវិស័យឧស្សាហកម្ម និងជំនាញអាជីពដោយមានការវិភាគយ៉ាងស៊ីជម្រៅនៃការអភិវឌ្ឍនិងស្រាវជ្រាវថ្មីៗ និងអាចយកចំណេះដឹង និងជំនាញទៅបណ្តុះបណ្តាលអ្នកដទៃក្នុងវិស័យរបស់ខ្លួន។ បេក្ខជនត្រូវមានចំណេះដឹងនិងទ្រឹស្តីទាក់ទងនឹង វិស័យសិក្សាផ្សេងៗ។

បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ គឺជាគុណវុឌ្ឍិមូលដ្ឋានសម្រាប់ការអប់រំបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ លើបច្ចេកវិទ្យា ការគ្រប់គ្រង និងវិជ្ជាជីវៈអាជីព ហើយការសិក្សាជួយអភិវឌ្ឍចំណេះដឹង និងជំនាញលើវិស័យទាក់ទងនឹងអភិវឌ្ឍចំណេះដឹងនិងជំនាញក្នុងការអនុវត្តយុទ្ធសាស្ត្រអប់រំ...

តម្រូវឲ្យមានការសិក្សានិងបទពិសោធខ្ពស់ក្នុងស្ថានភាពបណ្តុះបណ្តាលជាក់ស្តែង។ កម្មវិធីត្រូវបញ្ចូលជំនាញនិងចំណេះដឹងចាំបាច់ក្នុងការអនុវត្តវិស័យជំនួញនិងអាជីព ដើម្បីក្លាយជាគ្រូនិងបណ្តុះបណ្តាលដែលមានប្រសិទ្ធភាពនិងចំណេះដឹងទ្រឹស្តីការអនុវត្តជាក់ស្តែងនិងស្រាវជ្រាវ ដើម្បីបន្តការសិក្សាថែមទៀត។

ខ. លក្ខណៈនៃបុគ្គលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវមាន៖

- ចំណេះដឹងស៊ីជម្រៅផ្នែកឧស្សាហកម្មនិងអាជីពឬវិជ្ជាជីវៈពាក់ព័ន្ធ
- ចំណេះដឹងច្បាស់លាស់ពាក់ព័ន្ធនឹងការធ្វើផែនការនិងដំណើរការនៃកម្មវិធីអប់រំសម្រាប់និស្សិតតាមជំនាញរបស់ខ្លួន
- សមត្ថភាពក្នុងការប្រើចំណេះដឹងក្នុងការដោះស្រាយបញ្ហាស្មុគស្មាញក្នុងវិស័យឧស្សាហកម្មនិងស្ថានភាពបង្រៀននិងរៀនក្នុងបរិបទផ្សេងៗគ្នា
- ភាពជាអ្នកដឹកនាំដែលមានប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់ចំពោះទិន្នផលផ្ទាល់ខ្លួននិងជាក្រុម
- សមត្ថភាពយល់ វិភាគ និងធ្វើបទបង្ហាញទិន្នន័យ ជាក្រាភិច លេខ និងសំណេរយ៉ាងពិស្តារ ដូចជាសម្ភារសម្រាប់បង្រៀន
- ចំណេះដឹងគ្រឹះលើមុខវិជ្ជាមួយឬច្រើន ដូចជា វប្បធម៌ សង្គម បច្ចេកទេស និងវិទ្យាសាស្ត្រ
- អភិវឌ្ឍនៃជំនាញសិក្សានិងគុណភាពចាំបាច់ដើម្បីអនុវត្តការងារ
- សមត្ថភាពយល់និងវាយតម្លៃព័ត៌មានពីប្រភពផ្សេងៗ
- អភិវឌ្ឍជំនាញទូទៅដែលទាក់ទងនឹងបរិបទការងារនិងសមត្ថភាពដឹកនាំខ្លួនឯងនិងរៀនពេញមួយជីវិត។

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- មានការគោរពខ្ពស់ពីនិស្សិតរួមថ្នាក់ និយោជិត និងតំណាងឧស្សាហកម្ម។ មានចំណេះដឹងនិងជំនាញរបស់ខ្លួនចំណេះដឹងពាក់ព័ន្ធនឹងទ្រឹស្តីក្នុងអាជីព ឧស្សាហកម្ម និងវិជ្ជាជីវៈ
- យល់ច្បាស់ពីជំនាញរបស់ខ្លួននិងចេះពិចារណា ដោយចេះស្រាវស្រាវរកដំណោះស្រាយបញ្ហាក្នុងវិជ្ជាជីវៈនិងការសិក្សា
- មានការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍចំណេះដឹងនិងរៀនសូត្ររបស់អ្នកដទៃនិងខ្លួនឯង តាមរយៈសកម្មភាពសិក្សានិងអនុវត្តផ្ទាល់
- ផ្តើមគំនិតកែតម្រូវចំណេះដឹងនិងជំនាញរបស់ខ្លួនស្របតាមបរិបទខុសៗគ្នា តម្រូវតាមសេចក្តីត្រូវការរបស់អ្នកសិក្សា ជួយគាំទ្រ និងលើកទឹកចិត្តអ្នកដទៃឲ្យខិតខំរៀនសូត្រ
- ប្រមូលព័ត៌មានស្មុគស្មាញតាមរបៀបផ្សេងៗនិងអាចធ្វើបទបង្ហាញព័ត៌មាននោះតាមរបៀបត្រឹមត្រូវច្បាស់លាស់ដល់ទស្សនិកជនខុសៗគ្នា។

គ. លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានចំណេះដឹងស៊ីជម្រៅផ្នែកឧស្សាហកម្មនិងជំនាញមុខរបរ គួបផ្សំដោយចំណេះដឹងទូទៅ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ស្រូបយកចំណេះដឹងថ្មី។ ចំណេះដឹងនេះរួមមាន ចំណេះដឹងផ្នែកទ្រឹស្តី ដែលពាក់ព័ន្ធបច្ចេកទេសថ្មី។ មានចំណេះស៊ីជម្រៅផ្នែកទ្រឹស្តីនិងដំណើរការទាក់ទងនឹងការរៀន និងការបង្រៀន។

**ជំនាញក្នុងការគិត៖**

- ចេះស្រាវជ្រាវនិងវិភាគស៊ីជម្រៅបញ្ហាស្មុគស្មាញទាក់ទងនឹងការរៀននិងការបង្រៀននិងផែនការយុទ្ធសាស្ត្រសម្រាប់ការអនុវត្តក្នុងបរិបទផ្សេងៗ
- ចេះធ្វើផែនការនិងអនុវត្តកម្មវិធីអប់រំប្រកបដោយការពិចារណាលើតម្រូវការរបស់សិស្សម្នាក់ៗ ចេះវាយតម្លៃនិងបង្កើនគុណភាពនៃកម្មវិធីបណ្តុះបណ្តាលបន្ទាប់ពីការវាយតម្លៃការសិក្សារបស់និស្សិត និងកម្មវិធី
- ចេះប្រើនីតិវិធីប្រចាំថ្ងៃបានត្រឹមត្រូវប៉ុន្តែត្រូវចេះស្វែងយល់ពីស្ថានភាពដែលត្រូវការដំណោះស្រាយដោយប្រើគំនិតថ្មី ការអនុវត្តជាក់ស្តែង និងទ្រឹស្តី។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- ចេះវិភាគនិងសម្របសម្រួលដោះស្រាយបញ្ហាជាក្រុម ក្នុងនាមជាអ្នកដឹកនាំឬសមាជិកនៃក្រុម
- អាចដឹកនាំក្រុមក្នុងស្ថានភាពមិនជាក់លាក់តម្រូវឲ្យមានដំណោះស្រាយដោយប្រើគំនិតថ្មី
- ផ្តើមគំនិតក្នុងការរាវរកបញ្ហាដែលតម្រូវឲ្យដោះស្រាយជាបុគ្គលឬជាក្រុម
- ទទួលខុសត្រូវចំពោះការសិក្សាផ្ទាល់ខ្លួនចេះរាវរកនិងប្រើមធ្យោបាយក្នុងការស្រាវជ្រាវរកព័ត៌មានថ្មីឬរបៀបក្នុងការវិភាគទិន្នន័យនៃកិច្ចការ
- ដោះស្រាយបញ្ហាវិជ្ជាជីវៈនិងក្រមសីលធម៌ទាក់ទងនឹងតម្លៃនៃក្រមវិជ្ជាជីវៈ។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- អាចប្រើព័ត៌មានជាស្ថិតិ លេខ និងសំណៅស្មុគស្មាញ និងចេះវិភាគបរិបទអប់រំនិងការងារ
- ទំនាក់ទំនងដោយប្រសិទ្ធភាព ដោយសំណេរនិងផ្ទាល់មាត់ ធ្វើបទបង្ហាញស្របតាមបញ្ហានិងតម្រូវការទស្សនិកជន
- អាចអភិវឌ្ឍនិងធ្វើបទបង្ហាញត្រឹមត្រូវច្បាស់លាស់ដើម្បីដឹកនាំនិងការរៀនសូត្រពីអ្នកដទៃ។

**ជំនាញចិត្តចលនា៖**

- លទ្ធផលការសិក្សាក្នុងគុណវុឌ្ឍិនេះមានកម្រិតខ្ពស់ជាងគុណវុឌ្ឍិកម្រិត៥ (សញ្ញាបត្រជាន់ខ្ពស់

បច្ចេកទេស/ឯកទេស) ដោយបន្ថែមនូវជំនាញដែលតម្រូវឲ្យមានការអនុវត្តកម្មវិធីបណ្តុះបណ្តាលដោយប្រសិទ្ធភាព។ មានន័យថាបេក្ខជនមិនគ្រាន់តែមានជំនាញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសមត្ថភាពអាចធ្វើបទបង្ហាញដល់អ្នកដទៃ ហើយមានការយល់ដឹងនូវរបៀបអភិវឌ្ឍនិងកែលម្អជំនាញនេះទៀតផង។

### ឃ. ច្រកសិក្សាដើម្បីទទួលបានគុណវុឌ្ឍិ

**បេក្ខជនទទួលបានគុណវុឌ្ឍិនេះតាមរយៈ៖**

- បានបញ្ចប់វគ្គសិក្សារយៈពេល៤ឆ្នាំយ៉ាងតិច កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករដែលបានទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវ ហើយប្រឡងសម្រេចនូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារបណ្តុះបណ្តាលដែលបានអនុម័ត
- មានសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស /សញ្ញាបត្រវិស្វករវគ្គមិនបានទទួលស្គាល់ មានសិទ្ធិធ្វើតេស្តចូលរៀនវគ្គសិក្សាកម្រិតបរិញ្ញាបត្រ/វិស្វករឆ្នាំទី៣ដែលបានទទួលស្គាល់ និងចុះបញ្ជិកាត្រឹមត្រូវ ហើយប្រឡងសម្រេចនូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារបណ្តុះបណ្តាលដែលបានអនុម័ត
- អ្នកទទួលបាននូវគុណវុឌ្ឍិសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស អាចបន្តការសិក្សាទៅឆ្នាំទី៣នៃកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស /សញ្ញាបត្រវិស្វករ ដែលបានទទួលស្គាល់ ហើយប្រឡងសម្រេចនូវរាល់សមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារបណ្តុះបណ្តាលដែលបានអនុម័ត
- អ្នកទទួលបាននូវគុណវុឌ្ឍិសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស ដែលបានទទួលស្គាល់ ហើយមានបទពិសោធការងាររយៈពេល២ឆ្នាំយ៉ាងតិច លើមុខជំនាញដដែល អនុញ្ញាតឲ្យធ្វើតេស្តចូលរៀនកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស /សញ្ញាបត្រវិស្វករ ដែលមានការទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវ តាមរយៈការទទួលស្គាល់ការសិក្សាពីមុន។ ប្រការនេះ បេក្ខជនត្រូវសិក្សាតែក្រេឌីតដែលនៅសល់ប៉ុណ្ណោះ ហើយប្រឡងសម្រេចនូវសមត្ថភាពដែលកំណត់ក្នុងកញ្ចប់ឯកសារបណ្តុះបណ្តាលដែលបានអនុម័ត។

## បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស

### ក. លក្ខណៈកម្មវិធីបណ្តុះបណ្តាល

កម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសដែលផ្តោតលើការបណ្តុះបណ្តាលជំនាញឯកទេសវិជ្ជាជីវៈត្រូវបញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលនូវកិច្ចការសិក្សាកម្រិតខ្ពស់និងការសរសេរគម្រោងជាលក្ខណៈឯកភាជ្យដោយយកចំណេះដឹងដែលបានសិក្សាមកដោះស្រាយបញ្ហានានានៅក្នុងវិស័យវិជ្ជាជីវៈរៀងៗខ្លួន។

បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស ដែលមាននៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាលទ្ធផលសិក្សាដែលរួមបញ្ចូលនូវការសិក្សាពីវិស័យឬទស្សនៈចម្បងៗ ដែលពាក់ព័ន្ធនឹងការអនុវត្តវិជ្ជាជីវៈទាំងផ្នែកទ្រឹស្តីនិងជំនាញក្នុងបរិបទទូទៅ ដោយឆ្លងតាមការសិក្សាលើមុខវិជ្ជាសិក្សាក្នុងថ្នាក់និងការងារស្រាវជ្រាវសរសេរគម្រោងក្នុងកម្រិតស៊ីជម្រៅនិងយល់ដឹងខ្ពស់។

បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសជាទូទៅ ត្រូវបំពេញការសិក្សាបន្តពីកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វកររយៈពេលយ៉ាងតិចពី២ឬ៣ឆ្នាំសម្រាប់ការសិក្សាពេញម៉ោង ហើយរហូតដល់៦ឬ៨ឆ្នាំសម្រាប់ការសិក្សាមិនពេញម៉ោងនិងមានចំនួនក្រេឌីតសរុបយ៉ាងតិច៤៥-៥៧ក្រេឌីត។

ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសអាចធ្វើឡើងតាមរបៀបបីយ៉ាងដូចខាងក្រោម៖

**បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសតាមរយៈការសិក្សាលើមុខវិជ្ជា៖**

ការបណ្តុះបណ្តាលធ្វើឡើងតាមរយៈការសិក្សាលើមុខវិជ្ជាទាំងអស់ដោយផ្អែកលើការប្រឡងជាសំណេរនិង/ឬការប្រឡងផ្ទាល់មាត់ដើម្បីបញ្ចប់ការសិក្សា។ កម្មវិធីបណ្តុះបណ្តាលនេះតម្រូវឲ្យនិស្សិតសិក្សាក្នុងថ្នាក់ផងនិងអាចសិក្សាជាក្រុមតូចៗផងលើមុខវិជ្ជាទាំងអស់ ហើយអាចតម្រូវឲ្យមានការធ្វើគម្រោងការស្រាវជ្រាវលើមុខវិជ្ជាណាមួយ។ បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសប្រភេទនេះ ត្រូវបានបង្កើតឡើងសម្រាប់បេក្ខជនដែលមានជាមូលដ្ឋាននូវគុណវុឌ្ឍិនិងបទពិសោធទាក់ទងនឹងមុខវិជ្ជាវិជ្ជាជីវៈផ្ទាល់ឬបទពិសោធវិជ្ជាជីវៈពាក់ព័ន្ធ។

កម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស តាមរយៈការសិក្សាលើមុខវិជ្ជាតម្រូវឲ្យនិស្សិតសិក្សាលើមុខវិជ្ជាយ៉ាងតិចចំនួន៣៩ក្រេឌីតនៃចំនួនក្រេឌីតសរុប និងចំនួន៦ក្រេឌីតលើគម្រោងស្រាវជ្រាវឬ៤៥ក្រេឌីតចំពោះនិស្សិតដែលពុំមានធ្វើគម្រោងស្រាវជ្រាវ។

**បរិញ្ញាបត្រជាន់ខ្ពស់ច្ចេកវិទ្យា/ឯកទេសតាមរយៈការសិក្សាលើមុខវិជ្ជានិងស្រាវជ្រាវ៖**

កម្មវិធីបណ្តុះបណ្តាលនេះ ធ្វើឡើងតាមរយៈការសិក្សាលើមុខវិជ្ជាតម្រូវនិងការធ្វើរបាយការណ៍ស្រាវជ្រាវ ហើយការបញ្ចប់ការសិក្សាត្រូវផ្អែកលើការប្រឡងជាសំណេរនិង/ឬការប្រឡងផ្ទាល់មាត់និងលទ្ធផលនៃរបាយការណ៍ស្រាវជ្រាវ។ បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសតាមរយៈកិច្ចការសិក្សានិងស្រាវជ្រាវ ជាធម្មតាមានរយៈពេលសិក្សាចន្លោះពី៣-៤ឆមាសរៀបចំឡើងដោយភ្ជាប់គ្នារវាងកម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសនិងបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស។

កម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស តាមរយៈការសិក្សាលើមុខវិជ្ជានិងស្រាវជ្រាវ តម្រូវឲ្យនិស្សិតសិក្សាលើមុខវិជ្ជាយ៉ាងតិចចំនួន៣៣ក្រេឌីត នៃចំនួនក្រេឌីតសរុបនិងចំនួន១២ក្រេឌីតលើរបាយការណ៍ស្រាវជ្រាវ។

**បរិញ្ញាបត្រជាន់ខ្ពស់ច្ចេកវិទ្យា/ឯកទេសតាមរយៈការស្រាវជ្រាវ៖**

កម្មវិធីបណ្តុះបណ្តាលនេះ ធ្វើឡើងដោយផ្តោតលើការស្រាវជ្រាវជាចម្បង ហើយការបញ្ចប់ការសិក្សាត្រូវផ្អែកលើនិក្ខេបបទនៃការស្រាវជ្រាវ។ កម្មវិធីបណ្តុះបណ្តាលនេះតម្រូវឲ្យនិស្សិតសិក្សា

តែលើមុខវិជ្ជាមូលដ្ឋានចាំបាច់មួយចំនួនដូចជាវិធីសាស្ត្រស្រាវជ្រាវជាដើម ហើយពុំតម្រូវឲ្យនិស្សិតសិក្សាក្នុងថ្នាក់ ប្រឡង ឬធ្វើកិច្ចការផ្សេងៗឡើយ។ ការវាយតម្លៃការរីកចម្រើនរបស់និស្សិតធ្វើឡើងតាមរយៈសាស្ត្រាចារ្យណែនាំដែលជាអ្នកត្រួតពិនិត្យនិងណែនាំនិស្សិតតាំងពីដើមដល់ចប់។ ហើយការវាយតម្លៃជ្រើសរើសបេក្ខជនចូលរៀន ជាទូទៅត្រូវផ្តោតលើការវាយតម្លៃលើសមិទ្ធិផលសារណាដែលបានធ្វើកន្លងមកក្នុងការបញ្ចប់កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសឬបទពិសោធនៃការធ្វើការស្រាវជ្រាវដែលមានតម្លៃស្មើ។

កម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស តាមរយៈការស្រាវជ្រាវត្រូវមាន១២ក្រេឌីតលើមុខវិជ្ជាដែលទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវ ដើម្បីសរសេរនិក្ខេបបទឬមុខវិជ្ជាផ្សេងៗ អាស្រ័យតាមតម្រូវការនៃគ្រឹះស្ថានឧត្តមសិក្សានិងយ៉ាងតិច៣៣ក្រេឌីត លើនិក្ខេបបទ។

## ខ. លក្ខណៈនៃបុគ្គលដែលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវមាន៖

- ការយល់ដឹងបែបស៊ីជម្រៅលើទ្រឹស្តី ការស្រាវជ្រាវ និងការអភិវឌ្ឍថ្មីៗសំខាន់ៗនៃវិស័យមុខជំនាញឬវិជ្ជាជីវៈនិងវិបាកផ្សេងៗដែលចេញពីការរីកចម្រើនទាំងនោះ សំដៅរក្សាបាននូវចំណេះដឹងក្នុងវិស័យដែលខ្លួនសិក្សា
- ការយល់ដឹងនិងសមត្ថភាពក្នុងការប្រើប្រាស់វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវនិងការសាកសួរដែលមានលក្ខណៈជាក់លាក់នៅក្នុងវិស័យសិក្សាឬការប្រតិបត្តិវិជ្ជាជីវៈ ហើយប្រើវិធីសាស្ត្រទាំងនោះក្នុងការបំពេញការសិក្សាស្រាវជ្រាវចាំបាច់នានាឬក្នុងការធ្វើគម្រោងក្នុងជំនាញវិជ្ជាជីវៈរបស់ខ្លួន
- សមត្ថភាពធ្វើសំយោគនិងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍថ្មីៗក្នុងវិស័យជំនាញវិជ្ជាជីវៈរបស់ខ្លួនក្នុងការវិភាគអភិវឌ្ឍនិងពិសោធសម្មតិកម្ម និងលើកជាដំណោះស្រាយលើបញ្ហានានាដែលទាក់ទងទៅនឹងទ្រឹស្តីនិងការអនុវត្ត
- សមត្ថភាពក្នុងកម្រិតនេះ វាពាក់ព័ន្ធទៅនឹងស្វ័យអភិវឌ្ឍនិងការអនុវត្តនូវចំណេះដឹង បញ្ញាញាណនិងជំនាញក្នុងវិស័យផ្សេងៗនិង/ឬឯកទេសកម្រិតខ្ពស់នៅក្នុងបរិបទទូទៅនិងឯកទេស
- ការងារក្នុងកម្រិតនេះ គឺអនុលោមទៅនឹងការធ្វើផែនការការងារទូទៅ ផែនការថវិកាឬយុទ្ធសាស្ត្រហើយទទួលខុសត្រូវយ៉ាងសំខាន់ចំពោះរចនាសម្ព័ន្ធការងារទូទៅ ការងារគ្រប់គ្រងរួមទាំងមុខងារនិងលទ្ធផលការងាររបស់អ្នកដទៃដែលពាក់ព័ន្ធ
- មានការវិនិច្ឆ័យប្រកបដោយសុក្រឹតភាពនិងកម្រិតខ្ពស់លើផែនការ ការរៀបចំគម្រោងប្លង់ ដំណើរការគ្រោងការបច្ចេកទេសឬការងារគ្រប់គ្រង
- សមត្ថភាពបង្ហាញពីលទ្ធផលនៃការសិក្សានិងស្រាវជ្រាវកម្រិតខ្ពស់ តាមរយៈការបោះពុម្ពជាឯកសារផ្សព្វផ្សាយជូនដល់សហគមន៍អ្នកសិក្សាអ្នកជំនាញការនិងអ្នកពាក់ព័ន្ធនានា។

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- ឆ្លើយតបយ៉ាងទៀងទាត់ទៅនឹងភាពស្មុគស្មាញក្នុងការសិក្សានិងបញ្ហាដែលទាក់ទងជំនាញដោយផ្តល់នូវដំណោះស្រាយបញ្ហាប្រកបដោយគំនិតច្នៃប្រឌិត ការវិនិច្ឆ័យត្រឹមត្រូវ ហើយប្រើប្រាស់នូវជំនាញទាំងនេះតាមការចាំបាច់ក្នុងការដោះស្រាយបញ្ហា ក្នុងករណីពុំមានទិន្នន័យឬព័ត៌មានគ្រប់គ្រាន់
- សម្រេចចិត្តដោយមានភាពឯករាជ្យក្នុងការប្រឈមមុខនិងដោះស្រាយបញ្ហាដែលអាចដឹងមុន និងបញ្ហាកើតឡើងដោយចៃដន្យ ហើយសហការជាមួយអ្នកដទៃនិងផ្តល់ភាពជាអ្នកដឹកនាំតាមការចាំបាច់
- ប្រតិបត្តិតាមនិងជួយជំរុញអ្នកដទៃឲ្យយកសីលធម៌និងសុភនិច្ឆ័យទៅដោះស្រាយបញ្ហាជម្លោះដែលលំបាកនិងស្មុគស្មាញ
- មានការទទួលខុសត្រូវខ្ពស់ដោយមានភាពម្ចាស់ការលើការសិក្សានិងភាពជាអ្នកដឹកនាំដែលជាឱកាស ដើម្បីជួយជំរុញការអភិវឌ្ឍផ្នែកវិជ្ជាជីវៈដល់អ្នកដទៃផ្សេងទៀត។

គ. លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានចំណេះដឹង ការយល់ដឹងច្បាស់លាស់លើចំណុចសំខាន់នៃមុខវិជ្ជានិងការអប់រំ ដែលរួមមានទស្សនាទាន គោលការណ៍ ទ្រឹស្តី និងការប្រតិបត្តិថ្មីៗដែលទាក់ទងដំណើរការនៃការសិក្សានិងការអនុវត្តក្នុងជំនាញវិជ្ជាជីវៈ
- មានការយល់ដឹងល្អិតល្អន់លើផ្នែកមួយឬច្រើនដែលស្មុគស្មាញក្នុងជំនាញឯកទេសរបស់ខ្លួនពាក់ព័ន្ធនឹងទ្រឹស្តីការស្រាវជ្រាវនិងការអនុវត្តជាក់ស្តែង
- យល់ពីរបៀបដែលចំណេះដឹងថ្មីៗ ត្រូវបានអភិវឌ្ឍនិងដាក់ឲ្យប្រើប្រាស់និងផលប៉ះពាល់នៃការស្រាវជ្រាវថ្មីៗទៅលើចំណេះដឹងក្នុងជំនាញរបស់ខ្លួនក៏ដូចជាលើការប្រតិបត្តិជំនាញវិជ្ជាជីវៈ
- យល់ដឹងពីវិធានថ្មីៗនៅក្នុងតំបន់និងអន្តរជាតិដែលអាចមានឥទ្ធិពលលើជំនាញវិជ្ជាជីវៈដែលទាក់ទងនឹងហេតុផលស្តីពីការផ្លាស់ប្តូរក្នុងការអនុវត្តវិធានទាំងនេះនាពេលអនាគត។

**ជំនាញក្នុងការគិត៖**

- យកចំណេះដឹងទាំងទ្រឹស្តីនិងការអនុវត្តទៅដោះស្រាយបញ្ហាថ្មីប្លែកនិងមិនអាចព្រាងទុកនៅក្នុងការសិក្សានិងជំនាញវិជ្ជាជីវៈនិងចេះបង្កើតដំណោះស្រាយចំពោះបញ្ហានិងព្រឹត្តិការណ៍ផ្សេងៗប្រកបដោយគំនិតច្នៃប្រឌិត
- មានលទ្ធភាពធ្វើការវិនិច្ឆ័យប្រកបដោយហេតុផលច្បាស់លាស់និងអាចទុកចិត្តបាន ក្នុងស្ថានភាពដែលព័ត៌មានពុំមានភាពគ្រប់គ្រាន់និងច្បាស់លាស់
- ធ្វើសំយោគនិងប្រើប្រាស់ឯកសារសិក្សាដែលបោះពុម្ពផ្សព្វផ្សាយឬរបាយការណ៍វិជ្ជាជីវៈផ្សេងៗហើយបង្កើតនូវគំនិតថ្មីៗដ៏មានសារៈសំខាន់និងបូកបញ្ចូលគំនិតទាំងនោះបង្កើតជាចំណេះដឹងថ្មីៗបន្ថែមទៀត

- ប្រើបច្ចេកទេសស្រាវជ្រាវទូទៅនិងបច្ចេកទេសស្រាវជ្រាវជំនាញឯកទេស ក្នុងការវិភាគប្រកបដោយប្រឌិតញាណលើបញ្ហាស្មុគស្មាញទាំងឡាយ ហើយអាចទាញយកនូវសេចក្តីសន្និដ្ឋាននិងលើកជាសំណើទាក់ទងនឹងវិស័យអប់រំនិងវិជ្ជាជីវៈរបស់ខ្លួន
- រៀបចំគម្រោងនិងអនុវត្តគម្រោងខ្នាតធំឬការស្រាវជ្រាវដែលជាផ្នែកមួយនៃការសិក្សាដោយឯករាជ្យតាមរយៈការយកចំណេះដឹងទាំងទ្រឹស្តី ការអនុវត្ត និងបច្ចេកទេសស្រាវជ្រាវមកប្រើប្រាស់ ដើម្បីបង្កើតនូវសេចក្តីសន្និដ្ឋានសំខាន់ៗបន្ថែមលើចំណេះដឹងនិងការអនុវត្តវិជ្ជាជីវៈដែលមានហើយ។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- ផ្តួចផ្តើមគំនិតក្នុងការស្វែងរកនិងដោះស្រាយប្រកបដោយគំនិតច្នៃប្រឌិតនូវបញ្ហានិងស្ថានភាពស្មុគស្មាញកើតមានក្នុងបរិបទនៃការសិក្សានិងវិជ្ជាជីវៈរបស់ខ្លួន។ នៅពេលដែលមានតម្រូវការព័ត៌មាននិងជំនាញបន្ថែម និស្សិតមានលទ្ធភាពចាត់វិធានការស្វែងរកព័ត៌មាននិងអនុវត្តនូវជំនាញបន្ថែមដោយឯករាជ្យ
- ទទួលខុសត្រូវយ៉ាងពេញទំហឹងចំពោះការងាររបស់ខ្លួននិងសហប្រតិបត្តិការជាមួយសមាជិកដទៃទៀត ដើម្បីដោះស្រាយគ្រប់ស្ថានការណ៍និងបញ្ហាទាំងឡាយប្រតិបត្តិនូវជំនាញភាពជាអ្នកដឹកនាំរបស់ខ្លួនទាំងជាផ្លូវការនិងមិនផ្លូវការតាមការចាំបាច់។ ចំពោះការងារជាក្រុម អាចបញ្ចេញនូវសកម្មភាពក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រុមទាំងមូល
- ដោះស្រាយយ៉ាងជាប់លាប់និងហ្មត់ចត់នូវបញ្ហាស្មុគស្មាញ ដែលទាក់ទងនឹងអកិសមាចារនៅក្នុងរង្វង់ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួន។ មានលទ្ធភាពធ្វើការវិនិច្ឆ័យបានយ៉ាងត្រឹមត្រូវនិងមានសុពលភាព ដោយឈរលើគោលការណ៍និងគុណតម្លៃសង្គមជាមូលដ្ឋាន ចំពោះបញ្ហាដែលកើតមានឡើងហើយមិនអាចដោះស្រាយតាមរយៈក្រមសីលធម៌ឬបទបញ្ញាដែលមាន
- ផ្តួចផ្តើមស្នើសុំឲ្យពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មលើក្រមសីលធម៌ដែលមិនសមស្របក្នុងការអនុវត្តក្នុងសង្គម។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- ប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពនិងសមរម្យជាមួយក្រុមអ្នកពាក់ព័ន្ធនានានៅក្នុងជំនាញវិជ្ជាជីវៈរបស់ខ្លួនក៏ដូចជាក្នុងសហគមន៍ទាំងមូលតាមរយៈរបាយការណ៍និងបទបង្ហាញទាំងជាផ្លូវការនិងមិនផ្លូវការនិងតាមរយៈការបោះពុម្ពផ្សាយដែលមានលក្ខណៈអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចជានិក្ខេបបទឬរបាយការណ៍នៃគម្រោងស្រាវជ្រាវ
- គណនា ស្រង់ស្ថិតិទិន្នន័យ និងប្រើប្រាស់បានយ៉ាងទូលំទូលាយនូវបច្ចេកវិទ្យាព័ត៌មានវិទ្យា និងទំនាក់ទំនងដើម្បីអង្កេតបញ្ហាទាំងឡាយដែលកើតមានឡើង អាចបង្ហាញនូវសេចក្តីសន្និដ្ឋាននិងសំណូមពររបស់ខ្លួនជូនអ្នកដែលពាក់ព័ន្ធ។

យុ: ... អ្នកសិក្សាដើម្បីទទួលបានគុណវុឌ្ឍិ

... ទទួលបានគុណវុឌ្ឍិនេះតាមរយៈ៖

- មានគុណវុឌ្ឍិបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករដែលបានទទួលស្គាល់ ហើយឆ្លងកាត់ការសិក្សារយៈពេល២ឆ្នាំកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសដែលបានទទួលស្គាល់ និងចុះបញ្ជិកាត្រឹមត្រូវហើយសម្រេចបាននូវសមត្ថភាព/ក្រេឌីត ដែលកំណត់ក្នុងកម្រិតគុណវុឌ្ឍិនោះតាមរយៈកិច្ចការសិក្សាការងារសរសេរគម្រោង និងការងារស្រាវជ្រាវរួមបញ្ចូលគ្នា
- អ្នកដែលមានគុណវុឌ្ឍិបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស/សញ្ញាបត្រវិស្វករ ដែលបានទទួលស្គាល់ ហើយមានបទពិសោធការងាររយៈពេល២ឆ្នាំ លើជំនាញពាក់ព័ន្ធនឹងអនុញ្ញាតឲ្យធ្វើតេស្តចូលរៀនកម្រិតបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស ដែលបានទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវតាមរយៈការធ្វើតេស្តទទួលស្គាល់ការសិក្សាពីមុន/សមត្ថភាពបច្ចុប្បន្ន ដែលរៀបចំឡើងដោយស្ថាប័នទទួលបន្ទុក។ ប្រការនេះបេក្ខជនត្រូវសិក្សាតែក្រេឌីតដែលនៅសល់ប៉ុណ្ណោះ ហើយប្រឡងសម្រេចនូវសមត្ថភាពដែលកំណត់ក្នុងឯកសារបណ្តុះបណ្តាលដែលបានអនុម័ត។

## បណ្ឌិតបច្ចេកវិទ្យា/ឯកទេស

### ក. លក្ខណៈកម្មវិធីបណ្តុះបណ្តាល

កម្មវិធីកម្រិតបណ្ឌិតបច្ចេកវិទ្យា/ឯកទេស តម្រូវឲ្យមានចំនួនក្រេឌីតអប្បបរមាសរុប៥៤ក្រេឌីតសម្រាប់កិច្ចការសិក្សាកម្រិតខ្ពស់(ការសិក្សាក្នុងថ្នាក់នូវមុខវិជ្ជាកម្រិតខ្ពស់) បូកបន្ថែមនិក្ខេបបទជំនាញមួយ ដែលជាធម្មតាត្រូវមានរយៈពេលស្រាវជ្រាវយ៉ាងតិច៣ឆ្នាំរហូតដល់៦ឆ្នាំនៃការសិក្សាពេញម៉ោង និងរយៈពេលស្រាវជ្រាវ៨ឆ្នាំនៃការសិក្សាមិនពេញម៉ោង ឬ រយៈពេលប្រហាក់ប្រហែល បន្ទាប់ពីទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស។ ចំពោះរចនាសម្ព័ន្ធកម្មវិធីអប់រំកម្រិតបណ្ឌិតដែលផ្តោតជាចម្បងលើការ ស្រាវជ្រាវដោយឯករាជ្យនៅក្នុងជំនាញណាមួយដែលផ្តល់ដោយគ្រឹះស្ថានមួយចំនួនតម្រូវឲ្យមានចំនួន ក្រេឌីតសរុបយ៉ាងតិច១២ក្រេឌីតបូកបន្ថែមការសរសេរនិក្ខេបបទស្រាវជ្រាវខ្នាតធំមួយ។

កម្មវិធីអប់រំកម្រិតបណ្ឌិតបច្ចេកវិទ្យា/ឯកទេស ជាប់ពាក់ព័ន្ធជាសំខាន់ទៅនឹងភាពមានវិជ្ជាជ្រៅជ្រះដោយឯករាជ្យ ភាពស្ទាត់ជំនាញលើការអភិវឌ្ឍថ្មីៗបំផុតក្នុងជំនាញចាំបាច់និងការបង្កើតថ្មី ការបកស្រាយនិងប្រើប្រាស់ចំណេះដឹងដែលផ្តល់នូវខ្លឹមសារសំខាន់ៗបន្ថែម លើការអភិវឌ្ឍនៃមុខវិជ្ជាមេរៀន ឬជំនាញវិជ្ជាជីវៈណាមួយ។ កម្មវិធីអប់រំកម្រិតបណ្ឌិតអាចផ្តោតទៅលើការស្រាវជ្រាវដោយឯករាជ្យ ដែលបង្ហាញជាលទ្ធផលនៅក្នុងនិក្ខេបបទបន្ថែមទៅលើចំណេះដឹងដែលមានស្រាប់ ឬ ការបូកបញ្ចូលគ្នារវាងកិច្ចការសិក្សាកម្រិតខ្ពស់ជាមួយនឹងនិក្ខេបបទវិជ្ជាជីវៈឬនិក្ខេបបទជំនាញអនុវត្ត។

គុណវុឌ្ឍិបណ្ឌិតបច្ចេកវិទ្យា/ឯកទេសដែលមាននៅក្នុងផ្នែកអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាលទ្ធផលនៃការសិក្សាដែលរួមបញ្ចូលទាំងស្វ័យអភិវឌ្ឍនិងអនុវត្តទូលំទូលាយទាំងចំណេះដឹងទ្រឹស្តីវិជ្ជាជីវៈនិងជំនាញក្នុងវិស័យផ្សេងៗនិង/ឬឯកទេសកម្រិតខ្ពស់។ អ្នកបញ្ចប់ការសិក្សាកម្រិតបណ្ឌិតបច្ចេកវិទ្យា/ឯកទេសមានសមត្ថភាពអាចបង្កើតនូវអ្វីមួយថ្មីដោយខ្លួនឯង តាមរយៈកិច្ចការសិក្សានិងស្រាវជ្រាវផ្ទាល់ខ្លួនកម្រិតខ្ពស់ ដោយបង្ហាញបញ្ហាទាក់ទងនឹងការអនុវត្តចំពោះវិជ្ជាជីវៈណាមួយដ៏ខ្ពស់នូវអ្វីដែលបានបង្កើតថ្មីនោះ ហើយត្រូវឲ្យមានគុណភាពល្អប្រសើរអាចយកមកប្រើប្រាស់ជាក់ស្តែងបាននូវទៅតាមផ្សេង

ខ. លក្ខណៈនៃបុគ្គលដែលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវមាន៖

- ការយល់ដឹងយ៉ាងស៊ីជម្រៅពីចំណុចសំខាន់ៗនៃចំណេះដឹងនិងការស្រាវជ្រាវជាន់ខ្ពស់នៅក្នុងការអប់រំទូទៅឬក្នុងជំនាញវិជ្ជាជីវៈ
- ការស្គាល់ច្បាស់ពីបញ្ហាដែលលេចឡើងចំពោះមុខនៃការអប់រំឬជំនាញវិជ្ជាជីវៈ និងការស្គាល់ពីបុព្វហេតុចម្បងនៃបញ្ហាទាំងនោះសម្រាប់ការអនុវត្តនាពេលបច្ចុប្បន្ននិងការសន្និដ្ឋានដែលអាចទទួលយកបានជាទូទៅ
- ភាពមានចំណេះវិជ្ជាជ្រៅជ្រះខ្ពង់ខ្ពស់ទាក់ទងនឹងការសំយោគទ្រឹស្តីការស្រាវជ្រាវក្នុងជំនាញដែលពាក់ព័ន្ធការបង្កើតនិងការបកស្រាយចំណេះដឹងថ្មី តាមរយៈការស្រាវជ្រាវឬការអនុវត្តទ្រឹស្តីនិងការស្រាវជ្រាវក្នុងការរួមចំណែកយ៉ាងសំខាន់ទៅលើការអនុវត្តវិជ្ជាជីវៈ
- ការយល់ដឹងច្បាស់លាស់អំពីបច្ចេកទេសក្នុងការស្រាវជ្រាវដែលអាចអនុវត្តទៅលើជំនាញនៃការសិក្សាដែលពាក់ព័ន្ធ
- សមត្ថភាពក្នុងការចងក្រងលទ្ធផលនៃការស្រាវជ្រាវដែលបានធ្វើនៅក្នុងនិក្ខេបបទស្រាវជ្រាវឬរបាយការណ៍គម្រោងស្រាវជ្រាវនិងនៅក្នុងអត្ថបទបោះពុម្ពផ្សព្វផ្សាយជាឯកសារយោងសម្រាប់ការសិក្សាឬសម្រាប់វិជ្ជាជីវៈផ្សេងៗ
- សមត្ថភាពក្នុងកម្រិតនេះ វាពាក់ព័ន្ធទៅនឹងស្វ័យអភិវឌ្ឍនិងការអនុវត្តនូវចំណេះដឹង បញ្ញាញាណនិងជំនាញក្នុងវិស័យផ្សេងៗនិង/ឬឯកទេសកម្រិតខ្ពស់ទាំងនៅក្នុងបរិបទទូទៅនិងឯកទេស
- សមត្ថភាពពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវនិងចាត់ចែងរួមទាំងទិដ្ឋភាពទាំងអស់ចំពោះអ្នកដទៃទាំងការងារនិងមុខនាទី ហើយរួមទាំងការរៀបចំផែនការការងារ ផែនការថវិកា និងផែនការយុទ្ធសាស្ត្រនានាដែលត្រូវការ
- សមត្ថភាពនៃការវិនិច្ឆ័យប្រកបដោយភាពស្មុគស្មាញកម្រិតខ្ពស់បំផុតក្នុងការងាររៀបចំផែនការ
- ការរៀបចំគម្រោងប្លង់ដំណើរការការងារបច្ចេកទេស ការងារស្រាវជ្រាវ ឬការងារគ្រប់គ្រង។

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- ប្រើប្រាស់បានយ៉ាងត្រឹមត្រូវនូវចំណេះដឹងនិង/ឬការយល់ដឹងជ្រៅជ្រះខាងវិជ្ជាជីវៈរបស់ខ្លួនទៅលើការអភិវឌ្ឍបន្ថែមផ្នែកចំណេះដឹងនិងការអនុវត្តក្នុងជំនាញរបស់ខ្លួនដែលជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍការយល់ដឹងនិងយុទ្ធសាស្ត្រថ្មីៗ
- ផ្តល់នូវភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហា ដែលកើតមានឡើងក្នុងជំនាញរបស់ខ្លួននិងមានសមត្ថភាពក្នុងការផ្ទេរគំនិតនិងការសន្និដ្ឋានរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាពដល់អ្នកពាក់ព័ន្ធនានាទោះជាអ្នកមានជំនាញឬគ្មានជំនាញក្តី
- អាចដោះស្រាយយ៉ាងជាប់លាប់និងហ្មត់ចត់នូវបញ្ហាស្មុគស្មាញដែលទាក់ទងនឹងអភិសមាចារនៅក្នុងវិស័យការអប់រំនិងវិជ្ជាជីវៈរបស់ខ្លួននិងផ្តួចផ្តើមបង្កើតបាននូវដំណោះស្រាយដ៏សមរម្យ ចំពោះបញ្ហាដែលមានឥទ្ធិពលដល់សហគមន៍ទាំងមូល។

## គ.លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានការយល់ដឹងច្បាស់លាស់ពីចំណុចសំខាន់ៗនៃចំណេះដឹងក្នុងការអប់រំឬជំនាញវិជ្ជាជីវៈដោយរួមបញ្ចូលទាំងព័ត៌មានជាក់លាក់ទ្រឹស្តី គោលការណ៍ និងទស្សនាទានជាមូលដ្ឋាននានា
- យល់ដឹងពីការអភិវឌ្ឍចុងក្រោយនៅក្នុងជំនាញវិជ្ជាជីវៈរបស់ខ្លួន ដោយរួមទាំងបញ្ហាដែលកើតមានឡើងនិងបច្ចេកទេសក្នុងការស្រាវជ្រាវនិងបញ្ហាប្រឈមជាចម្បងក្នុងការអភិវឌ្ឍការសន្និដ្ឋានដែលអាចទទួលយកបានជាទូទៅ។ សម្រាប់ការសិក្សាកម្រិតបណ្ឌិតជំនាញវិជ្ជាជីវៈ និស្សិតត្រូវទទួល បានចំណេះដឹងច្បាស់លាស់និងទូលំទូលាយ ស្តីពីការផ្លាស់ប្តូរក្នុងការអនុវត្តជាក់ស្តែងទាំងក្នុង ក្របខ័ណ្ឌតំបន់និងអន្តរជាតិ។
- មានចំណេះដឹងច្បាស់លាស់ពីការអភិវឌ្ឍនៅក្នុងជំនាញពាក់ព័ន្ធ ដែលមានឥទ្ធិពលទៅលើការអនុវត្តវិជ្ជាជីវៈ។

**ជំនាញក្នុងការគិត៖**

- ប្រើប្រាស់ការយល់ដឹងខាងទ្រឹស្តីនិងបច្ចេកទេសនៃការអង្កេត ដើម្បីយកមកវិភាគប្រកបដោយគំនិតច្នៃប្រឌិតលើព្រឹត្តិការណ៍និងបញ្ហាសំខាន់ៗព្រមទាំងអាចបង្កើតបាននូវដំណោះស្រាយថ្មីៗ ចំពោះបញ្ហាទាំងនោះ
- សំយោគការស្រាវជ្រាវនិងការសរសេរទ្រឹស្តីហើយអាចអភិវឌ្ឍនូវការយល់ដឹងថ្មីៗ ប្រកបដោយការច្នៃប្រឌិត ដោយផ្អែកលើការធ្វើសមាហរណកម្មរវាងគំនិតទាំងក្នុងនិងក្រៅជំនាញសិក្សាជាន់ខ្ពស់របស់ខ្លួន
- រៀបចំនិងដឹកនាំការស្រាវជ្រាវឬគម្រោងអភិវឌ្ឍន៍សំខាន់ៗ ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញនានាដែលទាក់ទងនឹងការអភិវឌ្ឍចំណេះដឹងថ្មីឬការធ្វើឲ្យកាន់តែប្រសើរឡើងក្នុងការងារប្រតិបត្តិវិជ្ជាជីវៈសំខាន់ៗ។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- ប្រព្រឹត្តយ៉ាងសមស្របជាមួយនឹងស្វ័យភាពនិងការផ្តើមគំនិតកម្រិតខ្ពស់ក្នុងសកម្មភាពវិជ្ជាជីវៈឬវិជ្ជាការជាន់ខ្ពស់
- ទទួលខុសត្រូវខ្ពស់ចំពោះសកម្មភាពរបស់ខ្លួន វាយតម្លៃ និងបង្កើនប្រសិទ្ធភាពការងាររបស់ខ្លួនតាមរយៈការទទួលយកមតិយោបល់ពិតនិងការធ្វើផែនការកែលម្អឲ្យកាន់តែប្រសើរឡើង
- សម្របសម្រួលនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងសកម្មភាពការងារជាក្រុមនិងអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងភាពជាអ្នកដឹកនាំក្នុងបរិស្ថានសង្គមនិងវិជ្ជាជីវៈដ៏ស្មុគស្មាញ
- ដោះស្រាយបានយ៉ាងហ្មត់ចត់និងឆាប់រហ័សនូវបញ្ហាសីលធម៌ដ៏ស្មុគស្មាញ ធ្វើការវិនិច្ឆ័យដោយការស៊ើបអង្កេតប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌និងធ្វើឬបង្ហាញសេចក្តីសន្និដ្ឋានឲ្យបានគ្រប់ជ្រុងជ្រោយទៅលើបញ្ហាឬកង្វល់ដែលប៉ះពាល់ទាំងនោះ។ ផ្តួចផ្តើមគំនិតក្នុងការលើកឡើងពី

ភាពមិនគ្រប់គ្រាន់ឬគ្មានប្រសិទ្ធភាពនៃក្រមសីលធម៌វិជ្ជាជីវៈដែលមានស្រាប់ ដើម្បីពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មឲ្យបានសមស្របនិងត្រឹមត្រូវ។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- ប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពនិងសមរម្យជាមួយអ្នកពាក់ព័ន្ធនៅក្នុងការសិក្សាទូទៅនិងវិជ្ជាជីវៈក៏ដូចជាក្នុងសហគមន៍ទាំងមូល តាមរយៈរបាយការណ៍និងបទបង្ហាញផ្លូវការនិងមិនផ្លូវការ និងតាមរយៈការបោះពុម្ពផ្សាយក្នុងការអប់រំទូទៅនិងវិជ្ជាជីវៈដូចជានិក្ខេបបទជំនាញឬរបាយការណ៍គម្រោងស្តីពីបញ្ហាសំខាន់និងស្មុគស្មាញណាមួយ
- គណនានិងប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវទិន្នន័យគណិតវិទ្យានិងស្ថិតិនិងប្រើប្រាស់បានយ៉ាងទូលំទូលាយនូវបច្ចេកវិទ្យាព័ត៌មានវិទ្យានិងទំនាក់ទំនងក្នុងការអង្កេតបញ្ហានិងការបង្ហាញសេចក្តីសន្និដ្ឋាននិងអនុសាសន៍។

## ឃ. ច្រកសិក្សាដើម្បីទទួលបានគុណវុឌ្ឍិ

**បេក្ខជនទទួលបានគុណវុឌ្ឍិនេះតាមរយៈ៖**

- មានគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស ហើយចូលសិក្សាកម្រិតបណ្ឌិត ដែលបានទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវរយៈពេល៣ឆ្នាំ ហើយសម្រេចបាននូវក្រេឌីតដែលកំណត់ក្នុងកម្រិតគុណវុឌ្ឍិនោះ តាមរយៈកិច្ចការសិក្សា ការងារសរសេរគម្រោង និងការងារស្រាវជ្រាវរួមបញ្ចូលគ្នា។
- អ្នកមានគុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស ហើយមានបទពិសោធការងាររយៈពេល២ឆ្នាំលើជំនាញពាក់ព័ន្ធនឹងទទួលបាននូវលំដាប់ឆ្លងចូលសិក្សាកម្រិតបណ្ឌិតបច្ចេកវិទ្យា/ឯកទេស ដែលបានទទួលស្គាល់និងចុះបញ្ជិកាត្រឹមត្រូវ តាមរយៈការធ្វើតេស្តទទួលស្គាល់ការសិក្សាពីមុន/សមត្ថភាពបច្ចុប្បន្នដែលរៀបចំឡើងដោយស្ថាប័នទទួលបន្ទុក។ ប្រការនេះបេក្ខជនត្រូវសិក្សាតែក្រេឌីតដែលនៅសល់ប៉ុណ្ណោះ។

# ៣.២ ការអប់រំឧត្តមសិក្សា

**ការរំពឹងទុកកម្រិតចូលរៀន (សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ)៖**

ការចូលសិក្សាកម្រិតក្រោយមធ្យមសិក្សាក្នុងក្របខ័ណ្ឌអប់រំឧត្តមសិក្សា ជាទូទៅនិស្សិតត្រូវបញ្ចប់ការសិក្សានៅមធ្យមសិក្សាសិន ហើយអាចមានតម្រូវការចំណេះដំបូងខ្លះអាស្រ័យតាមជំនាញនីមួយៗ។ ក្នុងករណីតម្រូវឲ្យមានវគ្គសិក្សាត្រៀមវគ្គសិក្សាបន្ថែមនេះ មិនត្រូវរាប់បញ្ចូលជាផ្នែកនៃការអប់រំឧត្តមសិក្សទេ ហើយក្រេឌីតដែលទទួលបានតាមរយៈការសិក្សានេះក៏មិនត្រូវបូកបញ្ចូលជាក្រេឌីតសរុប សម្រាប់ការទទួលបានសញ្ញាបត្រឧត្តមសិក្សាឡើយ។

**លទ្ធផលសិក្សារំពឹងទុកក្នុងកម្រិតចូលសិក្សា៖**

- មានការយល់ដឹងទូលំទូលាយពីចំណេះដឹងនិងជំនាញលើមុខវិជ្ជាទូទៅនៃវិស័យនីមួយៗ ដែលបង្រៀននៅសាលាមធ្យមសិក្សាចំណេះទូទៅគួបផ្សំនឹងចំណេះដឹងយ៉ាងទូលំទូលាយដែលជាតម្រូវការចាំបាច់សម្រាប់ការសិក្សាបន្តលើវិស័យដែលជ្រើសរើស។

ជំនាញក្នុងការគិត៖

- មានការយល់ដឹងពីគំនិតគោលការណ៍និងទ្រឹស្តីទូទៅលើមុខវិជ្ជាដែលសិក្សានិងមានសមត្ថភាពអនុវត្តការយល់ដឹងទាំងនោះក្នុងការវិភាគស្ថានភាពនិងបញ្ហាថ្មីៗដែលមានក្នុងការសិក្សានិងក្នុងជីវភាពប្រចាំថ្ងៃ
- មានការយល់ដឹងពីបញ្ហាទាក់ទងនឹងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចនិងមានលទ្ធភាពអាចអនុវត្តចំណេះដឹងដែលទទួលបានពីការសិក្សាក្នុងការវិភាគបញ្ហាទាំងនោះ។

ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖

- មានការទទួលខុសត្រូវលើអត្តចរិតនិងការសិក្សារបស់ខ្លួន ហើយអាចមានលទ្ធភាពចូលរួមធ្វើកិច្ចការនិងផ្តួចផ្តើមគំនិតតាមរយៈការណែនាំក្នុងការសិក្សានិងទម្រង់ឬកពាផ្សេងៗក្នុងការអភិវឌ្ឍខ្លួន
- ជឿទុកចិត្តបានថាអាចបំពេញកិច្ចការផ្សេងៗដែលដាក់ឲ្យធ្វើ ដោយមានការត្រួតពិនិត្យនិងណែនាំតិចតួច
- បំពេញកិច្ចការប្រកបដោយប្រសិទ្ធភាពសំដៅសម្រេចគោលដៅទូទៅក្នុងស្ថានភាពការងារជាក្រុម។

ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖

- ប្រើព័ត៌មានមូលដ្ឋានបច្ចេកវិទ្យាកុំព្យូទ័រនិងបំណិនលេខនព្វន្ត ក្នុងការដោះស្រាយបញ្ហានានាក្នុងបរិបទអប់រំនិងជីវភាពប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាព
- អាចប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ទាំងតាមរយៈការនិយាយផ្ទាល់មាត់ ការសរសេរ និងតាមរយៈការប្រើបច្ចេកវិទ្យាព័ត៌មាន។

## បរិញ្ញាបត្ររង

### ក. លក្ខណៈនៃកម្មវិធីបណ្តុះបណ្តាល

បរិញ្ញាបត្ររងតម្រូវឲ្យមានការសិក្សានៅឧត្តមសិក្សាយ៉ាងតិច៦០ក្រេឌីតក្នុងរយៈពេលពីរឆ្នាំឬរយៈពេលប្រហាក់ប្រហែល។ សញ្ញាបត្របរិញ្ញាបត្ររង បង្កើតឡើងក្នុងគោលបំណងអភិវឌ្ឍចំណេះដឹងនិងជំនាញ ដើម្បីបម្រើការងារនៅក្នុងវិស័យរដ្ឋបាលឬវិស័យវិជ្ជាជីវៈដែលមានតម្រូវការកម្រិតជំនាញឯកទេសតិចតួចនិងផ្តល់នូវមូលដ្ឋានចំណេះដឹងជាទ្រឹស្តីទូទៅសម្រាប់បន្តការសិក្សានៅកម្រិតបរិញ្ញាបត្រ។ សមាសធាតុចំណេះដឹងនិងជំនាញទាំងនេះមានសារៈសំខាន់ទោះបីជាការសង្កត់ធ្ងន់ទៅលើចំណេះដឹងទូទៅឬចំណេះដឹងវិជ្ជាជីវៈមានភាពខុសគ្នាអាស្រ័យលើមុខជំនាញដែលសិក្សា។ ចំពោះសញ្ញាបត្របរិញ្ញាបត្ររង ដែលទាក់ទងនឹងវិស័យការងារបណ្តុះបណ្តាល ត្រូវផ្តល់ចំណេះដឹងនិងជំនាញការងារផ្ទាល់ឲ្យបានគ្រប់គ្រាន់តាមការចាំបាច់ហើយជាទូទៅត្រូវមានយ៉ាងតិច៥០% នៃកម្មវិធីអប់រំទាំងមូល។

មុខវិជ្ជាសិក្សាសម្រាប់បរិញ្ញាបត្ររង ត្រូវរៀបចំឡើងឲ្យមានការទាក់ទងទៅនឹងកម្មវិធីអប់រំកម្រិតបរិញ្ញាបត្រតែពុំត្រូវឲ្យដូចគ្នាទាំងស្រុងនោះទេ។ មុខវិជ្ជាសិក្សាទាំងនោះមានភាពខុសៗគ្នា លើវិសាលភាពនិងភាពស៊ីជម្រៅអាស្រ័យលើកម្មវិធីអប់រំជំនាញតែមួយឬពហុជំនាញ ប៉ុន្តែត្រូវមានភាពស៊ីជម្រៅគ្រប់គ្រាន់ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់បន្តការសិក្សាក្នុងកម្រិតបរិញ្ញាបត្រដែលទាក់ទងគ្នា។

គុណវុឌ្ឍិកម្រិតបរិញ្ញាបត្ររងផ្តល់នូវការតម្រង់ទិសមូលដ្ឋានទូទៅក្នុងការចូលបម្រើការងារពិសេសក្នុងវិស័យមុខរបរវិជ្ជាជីវៈនិងផ្តល់នូវការណែនាំលើមូលដ្ឋាននៃវិជ្ជាណាមួយឬអន្តរពហុវិជ្ជា។

## ខ. លក្ខណៈរបស់បុគ្គលដែលទទួលគុណវុឌ្ឍិនេះ

**បុគ្គលទទួលគុណវុឌ្ឍិកម្រិតនេះត្រូវមាន៖**

- ចំណេះដឹងសំខាន់ៗស្តីពីដំណើរការគោលការណ៍និងទ្រឹស្តីនានាក្នុងវិស័យដែលខ្លួនសិក្សា រួមទាំងនីតិវិធីនិយតកម្មនិងការប្រតិបត្តិដែលទាក់ទងនឹងវិស័យវិជ្ជាជីវៈរបស់ខ្លួន
- សមត្ថភាពក្នុងការអនុវត្តនូវគំនិតទ្រឹស្តីនិងដំណើរការវិភាគវិធី ដើម្បីដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងការងារនិង/ឬវិស័យដែលបានសិក្សាដោយឈរលើការធ្វើវិភាគច្បាស់លាស់
- សមត្ថភាពក្នុងការអនុវត្តប្រកបដោយជោគជ័យនូវការទទួលខុសត្រូវលើការងារក្នុងវិស័យដែលបានសិក្សា
- សមត្ថភាពក្នុងការបកស្រាយនិងវាយតម្លៃលើទិន្នន័យគុណវិស័យនិងទិន្នន័យបរិមាណវិស័យ ហើយបង្ហាញសេចក្តីសន្និដ្ឋាន តាមរយៈការបង្ហាញផ្ទាល់មាត់និងការសរសេរដោយប្រើបច្ចេកវិទ្យាព័ត៌មាននិងព័ត៌មានសមស្រប។

**បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖**

- ចេះប្រើចំណេះដឹងនិងជំនាញ ដើម្បីដោះស្រាយបញ្ហានានាក្នុងវិស័យដែលខ្លួនសិក្សាជាមួយនឹងតម្រូវការនៃការណែនាំតិចតួចប៉ុន្តែការយល់ដឹងលើចំណេះដឹងនិងរបៀបដោះស្រាយបញ្ហាទាំងនោះនៅមានកម្រិតដែលអាចមានឥទ្ធិពលលើការវិភាគនិងការបកស្រាយនូវចំណេះដឹងទាំងនោះ
- ចេះស្វែងរកការប្រឹក្សាយោបល់ពីប្រភពសមស្របនានាតាមការចាំបាច់
- ចេះផ្តួចផ្តើមគំនិតក្នុងការរៀបចំផែនការបង្កើនចំណេះដឹងនិងជំនាញរបស់ខ្លួន
- ចេះគិតនិងធ្វើសកម្មភាពដោយឯករាជ្យប៉ុន្តែក៏ចេះធ្វើអន្តរកម្មក្នុងក្រុមឬការងារជាក្រុមប្រកបដោយន័យស្ថាបនា ដើម្បីសម្រេចបានគោលដៅរួមគ្នា
- យល់ដឹងពីផលប៉ះពាល់លើសកម្មភាពរបស់អ្នកដទៃនិងប្រមាណពីភាពសមស្របនៃសកម្មភាពទាំងនោះ ដោយគោរពដល់គោលការណ៍អភិសមាចារនិងសីលធម៌ហើយទទួលយកការទទួលខុសត្រូវចំពោះសកម្មភាពនានាដែលប្រព្រឹត្តឡើងដោយបុគ្គលឬជាក្រុម។

## គ. លទ្ធផលសិក្សា

ចំណេះដឹង

- [illegible]ទៅលើវិស័យដែលខ្លួនសិក្សា ហើយមានចំណេះដឹងច្បាស់លាស់និងស៊ីជម្រៅលើចំណុច

សំខាន់ៗមួយចំនួន ដោយរាប់ទាំងទ្រឹស្តីគំនិតនិងគោលការណ៍សំខាន់ៗ
- យល់ដឹងពីសារៈសំខាន់នៃការសិក្សាស្រាវជ្រាវនិងបញ្ហាដែលកើតមានឡើងនាពេលថ្មីៗ
- ចំពោះកម្មវិធីអប់រំដែលផ្តល់ដល់និស្សិត ដើម្បីចូលបម្រើការងារផ្នែកវិជ្ជាជីវៈឬការងារពាក់ព័ន្ធនឹងវិជ្ជាជីវៈមានចំណេះលើការអភិវឌ្ឍថ្មីៗនៅក្នុងការប្រតិបត្តិ តម្រូវការបច្ចេកទេសនិងនិយតកម្មនានាក្នុងវិស័យវិជ្ជាជីវៈ។

**ជំនាញក្នុងការគិត៖**
- អាចវិភាគនិងបកស្រាយព័ត៌មានបច្ចេកទេសនិងស្រាវជ្រាវ ហើយអាចប្រើប្រាស់ព័ត៌មានទាំងនោះដើម្បីដោះស្រាយបញ្ហានានាជាមួយនឹងតម្រូវការនៃការណែនាំខ្លះៗ
- អាចពិនិត្យពិច័យ លើបញ្ហាសំខាន់ឬបញ្ហាដែលកើតឡើងជាប្រក្រតីដោះស្រាយបញ្ហាទាំងនោះនិងលើកជាវិធីសាស្ត្រថ្មីៗដោយប្រើចំណេះដឹងអនុវត្តនិងទ្រឹស្តីដែលពាក់ព័ន្ធ
- យល់ដឹងនិងញែកទស្សនៈនិងទ្រឹស្តីនៃមុខវិជ្ជាដែលសិក្សា ហើយប្រើទស្សនៈនិងទ្រឹស្តីទាំងនោះនៅក្នុងបរិបទការងារនិងការសិក្សា
- យល់ដឹងពីចរិតលក្ខណៈចំណេះដឹងនៅក្នុងវិស័យដែលខ្លួនសិក្សា ហើយអាចយកចំណេះដឹងទាំងនោះទៅវិភាគនិងដោះស្រាយបញ្ហានានា
- នៅក្នុងកម្មវិធីអប់រំវិជ្ជាជីវៈ អាចប្រើចំណេះដឹងបច្ចេកទេសនិងវិជ្ជាជីវៈក្នុងការវិភាគនិងដោះស្រាយបញ្ហាសំខាន់ៗជាមួយនឹងតម្រូវការនៃការណែនាំតិចតួច ហើយអាចយល់និងពន្យល់ពីវិបាកដែលកើតមានតាមរយៈការសម្រេចចិត្តផ្សេងៗ។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**
- គិតពិចារណានិងធ្វើសកម្មភាពដោយឯករាជ្យ ប៉ុន្តែក៏ចេះធ្វើអន្តរកម្មក្នុងក្រុមឬការងារជាក្រុមប្រកបដោយន័យស្ថាបនាដើម្បីសម្រេចបានគោលដៅរួមគ្នា
- ចេះប្រើភាពជាអ្នកដឹកនាំក្នុងក្រុមការងារតូចៗដែលខ្លួនទទួលខុសត្រូវ
- កំណត់ពីចំណុចខ្សោយនៃចំណេះដឹងនិងជំនាញរបស់ខ្លួន ហើយធ្វើផែនការអនុវត្តន៍ ដើម្បីសិក្សាស្វែងយល់បន្តទៀត
- មានការទទួលខុសត្រូវលើសកម្មភាពផ្ទាល់ខ្លួននិងសកម្មភាពជាក្រុម
- យល់ដឹងនិងគោរពយ៉ាងម៉ឺងម៉ាត់នូវបទប្បញ្ញត្តិនិងក្រមសីលធម៌ ហើយចេះស្វែងរកការប្រឹក្សាផ្តល់យោបល់តាមការចាំបាច់
- យល់ដឹងពីផលប៉ះពាល់លើសកម្មភាពរបស់អ្នកដទៃហើយចេះប្រមាណពីភាពសមស្របនៃសកម្មភាពទាំងនោះដោយគិតពីវិបាកដែលអាចកើតមាន
- ក្នុងស្ថានភាពដែលមានការខ្វែងគំនិតគ្នាលើតម្លៃឬសារៈសំខាន់នៃអ្វីមួយ អាចលើកយកគម្លាតនៃការខ្វែងគំនិតគ្នានេះមកលាតត្រដាងនិងធ្វើការកាត់ក្តីតាមហេតុផលជាក់ស្តែង។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**
- អាចប្រើវិធីគណិតវិទ្យានិងស្ថិតិទូទៅ ក្នុងការពិនិត្យពិច័យនិងលើកដំណោះស្រាយ [illegible]

- ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពទាំងក្នុងការនិយាយ ការសរសេរ ការវែកញែករកហេតុ-ផល ការវិភាគ និងការធ្វើសេចក្តីសន្និដ្ឋានត្រឹមត្រូវនិងច្បាស់លាស់
- ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងក្នុងការវិភាគបញ្ហានិងកស្តុតាងនានាដែលទទួលបាន និងក្នុងការធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាព។

### ឃ. ច្រកសិក្សាដើម្បីទទួលបានគុណវុឌ្ឍិ

បេក្ខជនទូទៅត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឬសញ្ញាបត្រដែលមានតម្លៃស្មើដែលរាប់ទាំងវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានឬសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣។ ការចូលរៀនកម្រិតបរិញ្ញា-បត្ររងពុំតម្រូវឲ្យបេក្ខជនមានបទពិសោធការងារមុនចូលរៀនឡើយ។ ចំពោះបេក្ខជនដែលមានវិញ្ញាបន-បត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋានតម្រូវឲ្យមានការផ្ទេរក្រេឌីត។

បរិញ្ញាបត្ររងជាគុណវុឌ្ឍិដែលសិក្សារយៈពេលពីរឆ្នាំក្រោយថ្នាក់ទី១២។ ដូច្នេះហើយកម្មវិធីបណ្តុះ-បណ្តាលកម្រិតបរិញ្ញាបត្ររងអាចរៀបចំឡើងតាមរយៈមុខជំនាញតែមួយឬពហុជំនាញ ហើយត្រូវបូកបញ្ចូលជំនាញការងារទូទៅចាំបាច់មួយចំនួន តាមរយៈមុខវិជ្ជាតម្រង់ទិស។ ចំពោះការសិក្សាដែលបំពេញតម្រូវការនៃការប្រកបមុខរបរសម្រាប់អ្នកឯកទេសវិជ្ជាជីវៈក្នុងសមាគមវិជ្ជាជីវៈឬឧស្សាហកម្ម អាចធ្វើតាមរយៈការបំពេញការសិក្សាយកសញ្ញាបត្របរិញ្ញាបត្រវិជ្ជាជីវៈ។

មានច្រកសិក្សាដើម្បីបន្តយកគុណវុឌ្ឍិផ្សេងៗគ្នាជាច្រើនដែលអ្នកទទួលបានបរិញ្ញាបត្ររងអាចបន្តការសិក្សា។ ច្រកសិក្សាដែលនិយមជាង គឺតាមរយៈការសិក្សាបន្តក្នុងកម្មវិធីកម្រិតបរិញ្ញាបត្រលើវិស័យសិក្សាដែលស្របទៅនឹងមុខវិជ្ជាតម្រង់ទិសរយៈពេលមិនលើសពី២ឆ្នាំ បន្ថែមដោយមានចំនួនក្រេឌីតកំណត់ជាក់លាក់។ ច្រកសិក្សាមួយទៀត គឺតាមរយៈការសិក្សាបន្តក្នុងកម្មវិធីកម្រិតបរិញ្ញាបត្រលើជំនាញស្របឬជំនាញផ្សេងដែលមានចំនួនក្រេឌីតតិចជាងឬប្រហាក់ប្រហែលគ្នា។

## បរិញ្ញាបត្រ

### ក. លក្ខណៈកម្មវិធីបណ្តុះបណ្តាល

សញ្ញាបត្របរិញ្ញាបត្រតម្រូវឲ្យបេក្ខជនបំពេញយ៉ាងតិច១២០ក្រេឌីត ហើយជាធម្មតាត្រូវសិក្សាពេញម៉ោងរយៈពេល៤ឆ្នាំឬសមមូល។ ការសិក្សាអាចមានរយៈពេលខុសគ្នាទៅតាមជំនាញវិជ្ជាជីវៈនិងកម្មវិធីអប់រំនីមួយៗ។ ទោះជាកម្រិតបរិញ្ញាបត្រទាំងអស់តម្រូវឲ្យបំពេញក្រេឌីតអប្បបរមាចំនួន១២០ក្រេឌីតតាមរយៈការសិក្សានៅក្នុងថ្នាក់យ៉ាងណាក្តីចំនួនក្រេឌីតអាចកើនឡើងអាស្រ័យតាមតម្រូវការសិក្សាក្នុងវិស័យវិជ្ជាជីវៈផ្សេងៗគ្នា។ ចំពោះសញ្ញាបត្របរិញ្ញាបត្រលើជំនាញមួយចំនួនដែលមានកម្មវិធីបណ្តុះបណ្តាលរយៈពេលវែងការផ្តល់ក្រេឌីតបន្ថែមគឺដើម្បីបញ្ជាក់ថាមុខជំនាញនោះមានតម្រូវការនៃការសិក្សាច្រើន។

កម្មវិធីអប់រំកម្រិតបរិញ្ញាបត្របង្កើតក្នុងគោលបំណង ដើម្បីអភិវឌ្ឍការយល់ដឹងទូលំទូលាយក្នុងជំនាញនីមួយៗ រួមជាមួយការសិក្សាទាក់ទងទៅនឹងការវិភាគយ៉ាងជិតដល់លើការអភិវឌ្ឍនិងការស្រាវជ្រាវ

ថ្មីៗចុងក្រោយបំផុត។ និស្សិតត្រូវស្វែងយល់ពីចំណេះដឹងនិងទ្រឹស្តីសំខាន់ៗនៅក្នុងជំនាញផ្សេងៗទៀតដែលបានសិក្សា។

សញ្ញាបត្របរិញ្ញាបត្រជាគុណវុឌ្ឍិសម្រាប់ចូលបម្រើក្នុងវិស័យវិជ្ជាជីវៈដែលតម្រូវឲ្យមានកម្រិតជំនាញខ្ពស់ ហើយកម្មវិធីអប់រំត្រូវអភិវឌ្ឍទាំងចំណេះនិងជំនាញដើម្បីប្រតិបត្តិក្នុងវិស័យវិជ្ជាជីវៈទាំងនោះ និងទាំងមូលដ្ឋានចំណេះដឹងទ្រឹស្តីនិងអនុវត្តនិងការស្រាវជ្រាវដើម្បីបន្តការសិក្សានៅកម្រិតខ្ពស់បន្ថែម។

## ខ. លក្ខណៈរបស់បុគ្គលដែលទទួលគុណវុឌ្ឍិនេះ

**បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវមាន៖**

- ចំណេះដឹងទូលំទូលាយជាប្រព័ន្ធនិងប្រទាក់ក្រឡាក្នុងវិស័យដែលខ្លួនសិក្សា ព្រមទាំងទ្រឹស្តីនិងគោលការណ៍សំខាន់ៗដែលពាក់ព័ន្ធ
- សមត្ថភាពអង្កេតនិងអាចស្វែងរកដំណោះស្រាយលើបញ្ហាស្មុគស្មាញដែលកើតមានឡើងដោយប្រើប្រាស់ចំណេះដឹងដែលបានមកពីការសិក្សាលើជំនាញរបស់ខ្លួននិងវិស័យពាក់ព័ន្ធផ្សេងៗជាមួយនឹងតម្រូវការនៃការណែនាំតិចតួច
- សមត្ថភាពប្រើប្រាស់រូបមន្តគណិតវិទ្យានិងស្ថិតិដើម្បីវិភាគនិងដោះស្រាយបញ្ហាស្មុគស្មាញ ហើយអាចជ្រើសរើសនិងប្រើប្រាស់យន្តការសមស្របបំផុត ដើម្បីបង្ហាញនូវលទ្ធផលទទួលបានជូនសវនការនានា
- ចំពោះកម្មវិធីអប់រំវិជ្ជាជីវៈចំណេះដឹងនិងជំនាញដែលទទួលបានឆ្លើយតបទៅនឹងការអនុវត្តជាក់ស្តែងយ៉ាងមានប្រសិទ្ធភាពតាមជំនាញនីមួយៗ
- ចំពោះកម្មវិធីអប់រំទូទៅ ដែលមិនផ្តោតទៅលើការប្រតិបត្តិវិជ្ជាជីវៈចំណេះដឹងនិងការយល់ដឹងស៊ីជម្រៅនៃស្នាដៃស្រាវជ្រាវលើជំនាញដែលខ្លួនសិក្សានិងសមត្ថភាពបកស្រាយ វិភាគ និងវាយតម្លៃលើសារៈសំខាន់នៃការស្រាវជ្រាវក្នុងការពង្រីកចំណេះដឹងលើជំនាញនោះ។

**បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖**

- មានគំនិតផ្តួចផ្តើមក្នុងការរកនិងដោះស្រាយបញ្ហាផ្សេងៗដែលកើតមានចំពោះបុគ្គលផ្ទាល់ខ្លួននិងក្រុមដោយការប្រតិបត្តិក្នុងភាពជាអ្នកដឹកនាំក្នុងការស្វែងរកដំណោះស្រាយថ្មីៗជាក់ស្តែង
- ប្រើប្រាស់ចំណេះដឹងនិងវិធីសាស្ត្រផ្នែកទ្រឹស្តីទទួលបានក្នុងវិស័យដែលខ្លួនសិក្សា ក្នុងការពិនិត្យថ្លឹងថ្លែងលើបញ្ហានានាក្នុងបរិបទផ្សេងៗ
- យល់ដឹងពីចរិតលក្ខណៈចំណេះដឹងនៅក្នុងវិស័យដែលខ្លួនសិក្សា ហើយអាចយកចំណេះដឹងទាំងនោះទៅពិនិត្យពិច័យនិងលើកជាដំណោះស្រាយលើបញ្ហាក្នុងការសិក្សានិងវិជ្ជាជីវៈនានា
- ចូលរួមក្នុងសកម្មភាពនានា ដើម្បីរក្សាខ្លួនឲ្យដើរទាន់ការលូតលាស់នៅក្នុងវិស័យដែលខ្លួនសិក្សា និងដើម្បីពង្រីកចំណេះដឹងនិងការយល់ដឹងរបស់ខ្លួន
- ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវឥរិយាបថអត្តសីលធម៌និងទទួលខុសត្រូវខ្ពស់នៅក្នុងបរិបទសិក្សាវិជ្ជាជីវៈ និងសហគមន៍នានា។

គ. លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានចំណេះដឹងទូលំទូលាយជាប្រព័ន្ធនិងប្រទាក់ក្រឡាក្នុងវិស័យដែលខ្លួនសិក្សា ព្រមទាំងទ្រឹស្តីនិងគោលការណ៍សំខាន់ៗដែលពាក់ព័ន្ធ
- យល់ដឹងពីចំណេះដឹងនិងទ្រឹស្តីដែលទាក់ទងនឹងការអប់រំផ្សេងៗឬវិស័យវិជ្ជាជីវៈផ្សេងៗ ចំពោះកម្មវិធីអប់រំវិជ្ជាជីវៈ
- យល់ដឹងពីការអភិវឌ្ឍចុងក្រោយសំខាន់ៗនៃជំនាញឯកទេសក្នុងវិស័យដែលខ្លួនសិក្សា ដោយរួមបញ្ចូលចំណេះដឹងវិភាគនៃការស្រាវជ្រាវនាពេលបច្ចុប្បន្នទាក់ទងនឹងដំណោះស្រាយបញ្ហាទាំងឡាយដែលកើតមានឡើងនិងការពង្រីកចំណេះដឹង
- ក្នុងកម្មវិធីអប់រំដែលរៀបចំឡើងសម្រាប់បរិញ្ញាបត្របច្ចេកវិទ្យានិស្សិតត្រូវយល់ដឹងពីអនុសញ្ញាបទប្បញ្ញត្តិ និងតម្រូវការបច្ចេកទេសផ្សេងៗ ព្រមទាំងរបៀបធ្វើវិសោធនកម្មលើបញ្ហាខាងលើឲ្យឆ្លើយតបនឹងការផ្លាស់ប្តូររបស់សង្គម។

**ជំនាញក្នុងការគិត៖**

- អាចអង្កេតយល់និងវាយតម្លៃនូវព័ត៌មានគំនិតនិងភស្តុតាងថ្មីៗពីប្រភពផ្សេងៗនិងធ្វើការសន្និដ្ឋានទៅលើព្រឹត្តិការណ៍និងបញ្ហាដែលកើតមានឡើងជាមួយនឹងតម្រូវការនៃការណែនាំតិចតួច
- អាចអង្កេតបញ្ហាស្មុគស្មាញទាំងឡាយផ្តល់យោបល់និងបង្កើតដំណោះស្រាយថ្មីៗតាមរយៈការប្រើប្រាស់នូវចំណេះដឹងនិងបទពិសោធក្នុងជំនាញរបស់ខ្លួន
- អាចយកជំនាញនិងចំណេះដឹងទាំងនោះទៅអនុវត្តក្នុងវិជ្ជាជីវៈនិងក្នុងការអប់រំទូទៅ ដែលទាក់ទងនឹងការសិក្សាក្នុងជំនាញរបស់ខ្លួន។ ចំពោះផ្នែកអប់រំវិជ្ជាជីវៈនិស្សិតអាចយកនីតិវិធីសមស្របទូទៅមកប្រើប្រាស់ ប៉ុន្តែត្រូវកំណត់ឲ្យបានច្បាស់លាស់ពីស្ថានភាពដែលតម្រូវឲ្យមានការបង្កើតនូវដំណោះស្រាយថ្មីៗទាំងអស់នេះត្រូវការឆ្លើយតបហើយបង្កើតឡើងតាមរយៈទ្រឹស្តីនិងការអនុវត្ត។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- រួមចំណែកជាមួយក្រុមការងាររបស់ខ្លួននិងស្វែងរកដំណោះស្រាយលើបញ្ហាទាំងឡាយ ដែលកើតមានទោះក្នុងមុខនាទីជាថ្នាក់ដឹកនាំក្តីឬជាសមាជិកក្រុមក្តី
- អនុវត្តការងារក្នុងភាពជាអ្នកដឹកនាំនៅក្នុងស្ថានការពុំជាក់លាក់ដែលតម្រូវឲ្យមានដំណោះស្រាយថ្មី
- ផ្តួចផ្តើមស្វែងរកបញ្ហាទាំងឡាយដែលតម្រូវឲ្យមានការប្រុងប្រយ័ត្ន ហើយអាចដោះស្រាយនូវបញ្ហាទាំងនោះដោយសមរម្យទោះក្នុងការងារជាបុគ្គលឬជាក្រុមក្តី
- ទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន ហើយមានលទ្ធភាពស្វែងរកនិងប្រើមធ្យោបាយស្វែងរកព័ត៌មានថ្មីៗឬបច្ចេកទេសក្នុងការវិភាគ ដើម្បីបំពេញតម្រូវការក្នុងការសិក្សារបស់ខ្លួន
- មានលទ្ធភាពស្វ័យសិក្សាដោយខ្លួនឯង ដើម្បីបន្តសិក្សាទៅកម្រិតខាងមុខ
- អនុវត្តជំនាញការងារជាក្រុមនិងទំនាក់ទំនងអន្តរបុគ្គលដែលសមស្របទៅនឹងការងាររបស់ខ្លួន
- ដោះស្រាយបញ្ហាអកិសមាចារនិងវិជ្ជាជីវៈទាក់ទងនឹងការវិនិច្ឆ័យលើគុណតម្លៃនិងសីលធម៌ដែល

ងាយប៉ះពាល់ដល់អ្នកដទៃ ស្របតាមគុណតម្លៃជាមូលដ្ឋានសំខាន់ៗនិងក្រមសីលធម៌វិជ្ជាជីវៈ។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- ប្រើប្រាស់បានយ៉ាងប្រសើរនូវបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងក្នុងការប្រមូល បកស្រាយ និងផ្សព្វផ្សាយព័ត៌មាននិងគំនិតផ្សេងៗ
- ជ្រើសរើសវិធីសាស្ត្រគណិតវិទ្យាឬស្ថិតិ ដើម្បីប្រើប្រាស់ក្នុងការបកស្រាយទិន្នន័យព័ត៌មាននិងលើកជាដំណោះស្រាយនៅពេលធ្វើការពិនិត្យអង្កេតលើបញ្ហានានា
- ទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាពទាំងការនិយាយក៏ដូចជាសរសេរ ជ្រើសរើស និងប្រើប្រាស់ទម្រង់បទបង្ហាញសមស្របទៅតាមព្រឹត្តិការណ៍និងអ្នកចូលរួមផ្សេងៗ។

## ឃ. ច្រកសិក្សាដើម្បីទទួលបានគុណវុឌ្ឍិ

បេក្ខជនទូទៅត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឬសញ្ញាបត្រ ដែលមានតម្លៃស្មើរប់ទាំងវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន បរិញ្ញាបត្ររង សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ៣(កម្រិត៤) ឬសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស(កម្រិត៥)។ ចំពោះបេក្ខជនដែលមានបរិញ្ញាបត្ររង ឬសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេសតម្រូវឲ្យមានការផ្ទេរក្រេឌីត។ ការចូលសិក្សាកម្រិតបរិញ្ញាបត្រពុំតម្រូវឲ្យបេក្ខជនមានបទពិសោធការងារមុនចូលរៀនឡើយ។

សញ្ញាបត្របរិញ្ញាបត្រជាគុណវុឌ្ឍិដែលសិក្សារយៈពេលបួនឆ្នាំក្រោយថ្នាក់ទី១២។ ដូច្នេះហើយកម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ អាចរៀបចំឡើងតាមរយៈមុខជំនាញតែមួយឬពហុជំនាញ ហើយត្រូវបូកបញ្ចូលជំនាញការងារទូទៅចាំបាច់មួយចំនួនតាមរយៈមុខវិជ្ជាតម្រង់ទិស។

**កម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររួមមាន៖**

- ការសិក្សាដែលមានរយៈពេល៤ឬ៥ឆ្នាំ ឬច្រើនជាងចំពោះជំនាញវិជ្ជាជីវៈដែលបណ្តុះបណ្តាលនិស្សិតនូវជំនាញអនុវត្តនិងបច្ចេកទេស ដែលចាំបាច់យកទៅអនុវត្តនៅក្នុងវិជ្ជាជីវៈយ៉ាងមានប្រសិទ្ធភាព
- ការបញ្ចូលគ្នានៃកម្មវិធីអប់រំជំនាញផ្សេងគ្នាឬកម្មវិធីអប់រំសញ្ញាបត្រពីរត្រួតគ្នាដែលអនុញ្ញាតឲ្យនិស្សិតបញ្ចូលគ្នានូវមុខវិជ្ជាដែលមាននៅក្នុងជំនាញទាំងពីរ ហើយអាចទទួលបានសញ្ញាបត្រជំនាញទាំងពីរក្នុងរយៈពេលខ្លីជាងការសិក្សាជំនាញនីមួយៗដោយឡែកពីគ្នា។

សញ្ញាបត្របរិញ្ញាបត្រ ជាសញ្ញាបត្រដែលអនុញ្ញាតឲ្យនិស្សិតបន្តការសិក្សាទៅកម្រិតបរិញ្ញាបត្រជាន់ខ្ពស់។

# បរិញ្ញាបត្រជាន់ខ្ពស់

## ក. លក្ខណៈកម្មវិធីបណ្តុះបណ្តាល

បរិញ្ញាបត្រជាន់ខ្ពស់ជាទូទៅត្រូវបំពេញការសិក្សាបន្តពីកម្រិតបរិញ្ញាបត្រ រយៈពេល [illegible] ៣ឆ្នាំ សម្រាប់ការសិក្សាពេញម៉ោង ហើយរហូតដល់៦ឬ៨ឆ្នាំ សម្រាប់ការសិក្សាមិនពេញម៉ោងនិងមាន

ចំនួនក្រេឌីតសរុបយ៉ាងតិច៤៥-៥៧ក្រេឌីត។

កម្រិតបរិញ្ញាបត្រជាន់ខ្ពស់បង្កើតឡើងក្នុងគោលបំណងផ្តល់នូវចំណេះដឹងនិងជំនាញជាន់ខ្ពស់ទាំងលើការអប់រំទូទៅនិងទាំងវិជ្ជាជីវៈ ដល់និស្សិតដែលបានបញ្ចប់កម្រិតបរិញ្ញាបត្រជាមួយនឹងលទ្ធផលនៃការសិក្សាខ្ពស់ ដែលជាទូទៅតម្រូវឲ្យមានមធ្យមភាគនៃពិន្ទុនិទ្ទេសសរុបចាប់ពី២,៥ឡើងទៅ។

បរិញ្ញាបត្រជាន់ខ្ពស់ដែលផ្តោតការបណ្តុះបណ្តាលលើជំនាញឯកទេសវិជ្ជាជីវៈ ត្រូវបញ្ចូលក្នុងកម្មវិធីអប់រំនូវកិច្ចការសិក្សាកម្រិតខ្ពស់និងការសរសេរគម្រោងជាលក្ខណៈឯករាជ្យ ដោយយកចំណេះដឹងដែលបានសិក្សាមកដោះស្រាយបញ្ហានានានៅក្នុងវិស័យវិជ្ជាជីវៈរបស់ខ្លួន។

បរិញ្ញាបត្រជាន់ខ្ពស់ស្រាវជ្រាវដែលផ្តោតលើការធ្វើនិក្ខេបបទស្រាវជ្រាវ ត្រូវផ្តល់ជូនជាឈ្មោះសញ្ញាបត្រដែលផ្តើមជាមួយពាក្យ បរិញ្ញាបត្រជាន់ខ្ពស់សិល្បៈមនុស្សសាស្ត្រ (MA) ឬបរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ (MSC)។ បរិញ្ញាបត្រជាន់ខ្ពស់វិជ្ជាជីវៈដែលផ្តោតតែលើកិច្ចការសិក្សាសុទ្ធឬលើកិច្ចការសិក្សាផងនិងការសរសេរគម្រោងខ្នាតតូចឬខ្នាតធំផង ជាទូទៅត្រូវផ្តល់ជូនជាឈ្មោះសញ្ញាបត្រដែលផ្តើមជាមួយពាក្យបរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច(MBus) បរិញ្ញាបត្រជាន់ខ្ពស់រដ្ឋបាលធុរកិច្ច(MBA) បរិញ្ញាបត្រជាន់ខ្ពស់អប់រំ(MEd) បរិញ្ញាបត្រជាន់ខ្ពស់វិស្វកម្ម(MEg) ឬប្រើពាក្យពិពណ៌នាផ្សេងៗទៀតសម្រាប់ជំនាញវិជ្ជាជីវៈដែលពាក់ព័ន្ធ។

**ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់អាចធ្វើឡើងតាមរបៀបបីយ៉ាងដូចខាងក្រោម៖**

- **បរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការសិក្សាលើមុខវិជ្ជា**

  ការបណ្តុះបណ្តាលធ្វើឡើងតាមរយៈការសិក្សាលើមុខវិជ្ជាទាំងអស់ ដោយផ្អែកលើការប្រឡងជាសំណេរនិង/ឬការប្រឡងផ្ទាល់មាត់ដើម្បីបញ្ចប់ការសិក្សា។ កម្មវិធីបណ្តុះបណ្តាលនេះតម្រូវឲ្យនិស្សិតសិក្សាក្នុងថ្នាក់ផងនិងអាចសិក្សាជាក្រុមតូចៗផងលើមុខវិជ្ជាទាំងអស់ ហើយអាចតម្រូវឲ្យមានការធ្វើគម្រោងការស្រាវជ្រាវលើមុខវិជ្ជាណាមួយ។ កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការសិក្សាលើមុខវិជ្ជា តម្រូវឲ្យនិស្សិតសិក្សាលើមុខវិជ្ជាយ៉ាងតិចចំនួន៣៩ក្រេឌីតនៃចំនួនក្រេឌីតសរុបនិងចំនួន៦ក្រេឌីតលើគម្រោងស្រាវជ្រាវ ឬ៤៥ក្រេឌីតចំពោះនិស្សិតដែលពុំមានគម្រោងស្រាវជ្រាវ។

- **បរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការសិក្សាលើមុខវិជ្ជានិងស្រាវជ្រាវ**

  ការបណ្តុះបណ្តាលធ្វើឡើងតាមរយៈការសិក្សាលើមុខវិជ្ជាតម្រូវនិងការធ្វើរបាយការណ៍ស្រាវជ្រាវ ហើយការបញ្ចប់ការសិក្សាត្រូវផ្អែកលើការប្រឡងសំណេរនិង/ឬការប្រឡងផ្ទាល់មាត់និងលទ្ធផលនៃរបាយការណ៍។ កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ តាមរយៈការស្រាវជ្រាវតម្រូវឲ្យនិស្សិតសិក្សាលើមុខវិជ្ជាយ៉ាងតិចចំនួន៣៣ក្រេឌីតនៃចំនួនក្រេឌីតសរុប និងចំនួន១២ក្រេឌីតលើរបាយការណ៍ស្រាវជ្រាវ។

- **បរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការស្រាវជ្រាវ**

  ការបណ្តុះបណ្តាលធ្វើឡើងដោយផ្តោតលើការស្រាវជ្រាវជាចម្បង ហើយការបញ្ចប់ការ

សិក្សាត្រូវផ្តែកលើនិក្ខេបបទនៃការស្រាវជ្រាវ។ កម្មវិធីបណ្តុះបណ្តាលនេះតម្រូវឲ្យនិស្សិតសិក្សាតែលើមុខវិជ្ជាមូលដ្ឋានចាំបាច់មួយចំនួន ដូចជាវិធីសាស្ត្រស្រាវជ្រាវជាដើម ហើយពុំតម្រូវឲ្យនិស្សិតធ្វើឡើយ សិក្សាក្នុងថ្នាក់ ប្រឡង ឬធ្វើកិច្ចការផ្សេងៗឡើយ។ ការវាយតម្លៃការរីកចម្រើនរបស់និស្សិត ធ្វើឡើងតាមរយៈសាស្ត្រាចារ្យណែនាំដែលជាអ្នកត្រួតពិនិត្យនិងណែនាំនិស្សិតតាំងពីដើមដល់ចប់។ កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការស្រាវជ្រាវ ត្រូវមាន១២ក្រេឌីតលើមុខវិជ្ជាដែលទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវ ដើម្បីសរសេរនិក្ខេបបទឬមុខវិជ្ជាផ្សេងៗ អាស្រ័យតាមតម្រូវការនៃគ្រឹះស្ថានឧត្តមសិក្សានិងយ៉ាងតិច៣៣ក្រេឌីតលើនិក្ខេបបទ។

## ខ. លក្ខណៈនៃបុគ្គលដែលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវមាន៖

- ការយល់ដឹងបែបស៊ីជម្រៅលើទ្រឹស្តីការស្រាវជ្រាវនិងការអភិវឌ្ឍថ្មីៗ សំខាន់ៗនៃវិស័យមុខជំនាញឬវិជ្ជាជីវៈនិងវិបាកផ្សេងៗដែលចេញពីការរីកចម្រើនទាំងនោះ សំដៅរក្សាបាននូវចំណេះដឹងក្នុងវិស័យដែលខ្លួនសិក្សា
- ការយល់ដឹងនិងសមត្ថភាពក្នុងការប្រើប្រាស់វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និងការសាកសួរដែលមានលក្ខណៈជាក់លាក់នៅក្នុងវិស័យសិក្សាឬការប្រតិបត្តិវិជ្ជាជីវៈ ហើយប្រើវិធីសាស្ត្រទាំងនោះក្នុងការបំពេញការសិក្សាស្រាវជ្រាវចាំបាច់នានាឬក្នុងការធ្វើគម្រោងក្នុងជំនាញវិជ្ជាជីវៈរបស់ខ្លួន
- សមត្ថភាពធ្វើសំយោគនិងប្រើប្រាស់លទ្ធផលនៃការសិក្សាស្រាវជ្រាវនិងការអភិវឌ្ឍថ្មីៗក្នុងវិស័យជំនាញវិជ្ជាជីវៈរបស់ខ្លួនក្នុងការវិភាគ អភិវឌ្ឍ និងពិសោធសម្មតិកម្ម និងលើកជាដំណោះស្រាយលើបញ្ហានានាដែលទាក់ទងទៅនឹងទ្រឹស្តីនិងការអនុវត្ត
- សមត្ថភាពបង្ហាញពីលទ្ធផលនៃការសិក្សានិងស្រាវជ្រាវកម្រិតខ្ពស់ តាមរយៈការបោះពុម្ពជាឯកសារផ្សព្វផ្សាយជូនដល់សហគមន៍អ្នកសិក្សា អ្នកជំនាញការ និងអ្នកពាក់ព័ន្ធនានា។

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- ឆ្លើយតបយ៉ាងទៀងទាត់ទៅនឹងភាពស្មុគស្មាញក្នុងការសិក្សានិងបញ្ហាដែលទាក់ទងជំនាញដោយផ្តល់នូវដំណោះស្រាយបញ្ហាប្រកបដោយគំនិតច្នៃប្រឌិត ការវិនិច្ឆ័យត្រឹមត្រូវ ហើយប្រើប្រាស់នូវជំនាញទាំងនេះតាមការចាំបាច់ក្នុងការដោះស្រាយបញ្ហាក្នុងករណីពុំមានទិន្នន័យឬព័ត៌មានគ្រប់គ្រាន់
- សម្រេចចិត្តដោយមានភាពឯករាជ្យក្នុងការប្រឈមមុខនិងដោះស្រាយបញ្ហាដែលអាចដឹងមុននិងបញ្ហាកើតឡើងដោយចៃដន្យ ហើយសហការជាមួយអ្នកដទៃនិងផ្តល់ភាពជាអ្នកដឹកនាំតាមការចាំបាច់
- ប្រតិបត្តិតាមនិងជួយជំរុញអ្នកដទៃឲ្យយកសីលធម៌និងសុភវិនិច្ឆ័យទៅដោះស្រាយបញ្ហាផ្សេងៗដែលលំបាកនិងស្មុគស្មាញ
- មានការទទួលខុសត្រូវខ្ពស់ដោយមានភាពម្ចាស់ការលើការសិក្សានិងភាពជាអ្នកដឹកនាំ

ដែលជាឱកាស ដើម្បីជួយជំរុញការអភិវឌ្ឍផ្នែកវិជ្ជាជីវៈដល់អ្នកដទៃផ្សេងៗទៀត។

គ. លទ្ធផលសិក្សា

**ចំណេះដឹង៖**

- មានចំណេះដឹងច្បាស់លាស់លើចំណុចសំខាន់នៃមុខវិជ្ជានិងការអប់រំ ដែលរួមមានទស្សនាទាន គោលការណ៍ ទ្រឹស្តី និងការប្រតិបត្តិថ្មីៗដែលទាក់ទងដំណើរការនៃការសិក្សានិងការអនុវត្តក្នុងជំនាញវិជ្ជាជីវៈ
- មានការយល់ដឹងល្អិតល្អន់លើផ្នែកមួយឬច្រើនដែលស្មុគស្មាញក្នុងជំនាញឯកទេសរបស់ខ្លួនពាក់ព័ន្ធនឹងទ្រឹស្តី ការស្រាវជ្រាវ និងការអនុវត្តជាក់ស្តែង
- យល់ពីរបៀបដែលចំណេះដឹងថ្មីៗ ត្រូវបានអភិវឌ្ឍនិងដាក់ឲ្យប្រើប្រាស់និងផលប៉ះពាល់នៃការស្រាវជ្រាវថ្មីៗទៅលើចំណេះដឹងក្នុងជំនាញរបស់ខ្លួនក៏ដូចជាលើការប្រតិបត្តិជំនាញវិជ្ជាជីវៈ
- យល់ដឹងពីវិជានថ្មីៗនៅក្នុងតំបន់និងអន្តរជាតិដែលអាចមានឥទ្ធិពលលើជំនាញវិជ្ជាជីវៈដែលទាក់ទងនឹងហេតុផលស្តីពីការផ្លាស់ប្តូរ ក្នុងការអនុវត្តវិធានទាំងនេះនាពេលអនាគត។

**ជំនាញក្នុងការគិត៖**

- អាចយកចំណេះដឹងទាំងទ្រឹស្តីនិងការអនុវត្តទៅដោះស្រាយបញ្ហាថ្មីប្លែកនិងមិនអាចព្រាងទុកនៅក្នុងការសិក្សានិងជំនាញវិជ្ជាជីវៈ និងចេះបង្កើតដំណោះស្រាយចំពោះបញ្ហានិងព្រឹត្តិការណ៍ផ្សេងៗប្រកបដោយគំនិតច្នៃប្រឌិត
- មានលទ្ធភាពធ្វើការវិនិច្ឆ័យប្រកបដោយហេតុផលច្បាស់លាស់និងអាចទុកចិត្តបានក្នុងស្ថានភាពដែលព័ត៌មានពុំមានភាពគ្រប់គ្រាន់និងច្បាស់លាស់
- ធ្វើសំយោគនិងប្រើប្រាស់ឯកសារសិក្សាដែលបោះពុម្ពផ្សព្វផ្សាយឬរបាយការណ៍វិជ្ជាជីវៈផ្សេងៗ ហើយបង្កើតនូវគំនិតថ្មីៗដ៏មានសារៈសំខាន់និងបូកបញ្ចូលគំនិតទាំងនោះបង្កើតជាចំណេះដឹងថ្មីៗបន្ថែមទៀត
- ប្រើបច្ចេកទេសស្រាវជ្រាវទូទៅនិងបច្ចេកទេសស្រាវជ្រាវជំនាញឯកទេសក្នុងការវិភាគប្រកបដោយប្រឌិតញាណលើបញ្ហាស្មុគស្មាញទាំងឡាយ ហើយអាចទាញយកនូវសេចក្តីសន្និដ្ឋាននិងលើកជាសំណើទាក់ទងនឹងវិស័យការអប់រំនិងវិជ្ជាជីវៈរបស់ខ្លួន
- រៀបចំគម្រោងនិងការអនុវត្តគម្រោងខ្នាតធំ ការស្រាវជ្រាវដែលជាផ្នែកមួយនៃការសិក្សាដោយឯករាជ្យតាមរយៈការយកចំណេះដឹងទាំងទ្រឹស្តី ការអនុវត្ត និងបច្ចេកទេសស្រាវជ្រាវមកប្រើប្រាស់ដើម្បីបង្កើតនូវសេចក្តីសន្និដ្ឋានសំខាន់ៗ បន្ថែមលើចំណេះដឹងនិងការអនុវត្តវិជ្ជាជីវៈដែលមានហើយ។

**ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖**

- ផ្តួចផ្តើមគំនិតក្នុងការស្វែងរកនិងដោះស្រាយប្រកបដោយគំនិតច្នៃប្រឌិតនូវបញ្ហានិងស្ថានភាពស្មុគស្មាញកើតមានក្នុងបរិបទនៃការសិក្សានិងវិជ្ជាជីវៈរបស់ខ្លួន។ នៅពេលដែលមានតម្រូវការព័ត៌មាននិងជំនាញបន្ថែម និស្សិតមានលទ្ធភាពចាត់វិធានការស្វែងរកព័ត៌មាននិងអនុវត្តនូវជំនាញ

បន្ថែមដោយឯករាជ្យ

- ទទួលខុសត្រូវយ៉ាងពេញទំហឹង ចំពោះការងាររបស់ខ្លួននិងសហប្រតិបត្តិការជាមួយសមាជិកដទៃទៀត ដើម្បីដោះស្រាយគ្រប់ស្ថានការណ៍និងបញ្ហាទាំងឡាយប្រតិបត្តិនូវជំនាញភាពជាអ្នកដឹកនាំរបស់ខ្លួនទាំងជាផ្លូវការនិងមិនផ្លូវការតាមការចាំបាច់។ ចំពោះការងារជាក្រុមអាចបញ្ចេញនូវសកម្មភាពទាំងឡាយក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រុមទាំងមូល
- ដោះស្រាយយ៉ាងជាប់លាប់និងហ្មត់ចត់នូវបញ្ហាស្មុគស្មាញដែលទាក់ទងនឹងអភិសមាចារនៅក្នុងវង្វង់ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ខ្លួន។ មានលទ្ធភាពធ្វើការវិនិច្ឆ័យបានយ៉ាងត្រឹមត្រូវនិងមានសុពលភាព ដោយឈរលើគោលការណ៍និងគុណតម្លៃសង្គមជាមូលដ្ឋានចំពោះបញ្ហាដែលកើតមានឡើង ហើយមិនអាចដោះស្រាយតាមរយៈក្រមសីលធម៌ឬបទបញ្ញាដែលមាន
- ផ្តួចផ្តើមស្នើសុំឲ្យពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មលើក្រមសីលធម៌ដែលមិនសមស្របក្នុងការអនុវត្តក្នុងសង្គម។

**ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖**

- អាចប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពនិងសមរម្យជាមួយក្រុម អ្នកពាក់ព័ន្ធនានានៅក្នុងជំនាញវិជ្ជាជីវៈរបស់ខ្លួនក៏ដូចជាក្នុងសហគមន៍ទាំងមូលតាមរយៈរបាយការណ៍និងបទបង្ហាញទាំងជាផ្លូវការនិងមិនផ្លូវការ និងតាមរយៈការបោះពុម្ពផ្សាយដែលមានលក្ខណៈអប់រំនិងវិជ្ជាជីវៈដូចជានិក្ខេបបទឬរបាយការណ៍នៃគម្រោងស្រាវជ្រាវ
- អាចគណនា ស្រង់ស្ថិតិទិន្នន័យ និងប្រើប្រាស់បានយ៉ាងទូលំទូលាយនូវបច្ចេកវិទ្យាព័ត៌មានវិទ្យានិងទំនាក់ទំនង ដើម្បីអង្កេតបញ្ហាទាំងឡាយដែលកើតមានឡើងអាចបង្ហាញនូវសេចក្តីសន្និដ្ឋាននិងសំណូមពររបស់ខ្លួនជូនអ្នកដែលពាក់ព័ន្ធ។

## ឃ. ច្រកសិក្សាដើម្បីទទួលបានគុណវុឌ្ឍិ

បេក្ខជនដែលមានបំណងចង់សិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ត្រូវបង្ហាញភស្តុតាងសមត្ថភាពអាចបន្តការសិក្សាទទួលយកសញ្ញាបត្រកម្រិតខ្ពស់ក្នុងជំនាញដែលបានស្នើសុំ។ មានច្រកសិក្សាជាច្រើន ដើម្បីទទួលបានគុណវុឌ្ឍិនេះ។ ច្រកសិក្សាទាំងនេះប្រែប្រួលទៅតាមវិធីសាស្ត្រនៃកម្មវិធីអប់រំនីមួយៗនិងបែបបទដែលពាក់ព័ន្ធ។ ជាទូទៅកម្មវិធីបណ្តុះបណ្តាលដែលផ្តោតលើការស្រាវជ្រាវជាមូលដ្ឋាន តម្រូវឲ្យបេក្ខជនមានមូលដ្ឋាននៃការស្រាវជ្រាវជាមុន ចំណែកកម្មវិធីបណ្តុះបណ្តាលដែលផ្តោតលើកិច្ចការសិក្សាជាមូលដ្ឋានការវាយតម្លៃជ្រើសរើសបេក្ខជនមានលក្ខណៈទូលំទូលាយនិងងាយជាង។

ដោយសារច្រកសិក្សានិងលក្ខខណ្ឌវិធីសាស្ត្រក្នុងការទទួលគុណវុឌ្ឍិមានច្រើនប្រភេទ រយៈពេលនៃការសិក្សាក៏ប្រែប្រួលទៅតាមនោះដែរ។ ទោះជាយ៉ាងណាបរិញ្ញាបត្រជាន់ខ្ពស់ភាគច្រើនតម្រូវឲ្យសិក្សារយៈពេល២ឆ្នាំបន្ថែមលើការសិក្សាកម្រិតបរិញ្ញាបត្រ ដែលមានរយៈពេល៤ឆ្នាំឬច្រើនជាង

## សញ្ញាបត្របណ្ឌិត

### ក.លក្ខណៈកម្មវិធីបណ្តុះបណ្តាល

កម្មវិធីកម្រិតបណ្ឌិតតម្រូវឲ្យមានចំនួនក្រេឌីតអប្បបរមាសរុប៥៤ក្រេឌីត សម្រាប់កិច្ចការសិក្សាកម្រិតខ្ពស់ (ការសិក្សាក្នុងថ្នាក់នូវមុខវិជ្ជាកម្រិតខ្ពស់) បូកបន្ថែមនិក្ខេបបទជំនាញមួយដែលជាធម្មតាត្រូវមានរយៈពេលស្រាវជ្រាវយ៉ាងតិច៣ឆ្នាំរហូតដល់៦ឆ្នាំនៃការសិក្សាពេញម៉ោងនិងរយៈពេលស្រាវជ្រាវ ៨ឆ្នាំនៃការសិក្សាមិនពេញម៉ោងឬរយៈពេលប្រហាក់ប្រហែលបន្ទាប់ពីទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។

ចំពោះរចនាសម្ព័ន្ធកម្មវិធីអប់រំកម្រិតបណ្ឌិត ដែលផ្តោតជាចម្បងលើការស្រាវជ្រាវដោយឯករាជ្យនៅក្នុងជំនាញណាមួយផ្តល់ដោយគ្រឹះស្ថានមួយចំនួន តម្រូវឲ្យចំនួនក្រេឌីតសរុបយ៉ាងតិច១២ក្រេឌីតបូកបន្ថែមការសរសេរនិក្ខេបបទស្រាវជ្រាវខ្នាតធំមួយ។

កម្មវិធីអប់រំកម្រិតបណ្ឌិត ជាប់ពាក់ព័ន្ធជាសំខាន់ទៅនឹងភាពមានវិជ្ជាជ្រៅជ្រះដោយឯករាជ្យ ភាពស្ទាត់ជំនាញលើការអភិវឌ្ឍថ្មីៗបំផុតក្នុងជំនាញចាំបាច់និងការបង្កើតថ្មី ការបកស្រាយ និងប្រើប្រាស់ចំណេះដឹងដែលផ្តល់នូវខ្លឹមសារសំខាន់ៗ បន្ថែមលើការអភិវឌ្ឍនៃមុខវិជ្ជាមេរៀនឬជំនាញវិជ្ជាជីវៈណាមួយ។ កម្មវិធីអប់រំកម្រិតបណ្ឌិតអាចផ្តោតទៅលើការស្រាវជ្រាវដោយឯករាជ្យដែលបង្ហាញជាលទ្ធផលនៅក្នុងនិក្ខេបបទបន្ថែមទៅលើចំណេះដឹង ដែលមានស្រាប់ឬការបូកបញ្ចូលគ្នារវាងកិច្ចការសិក្សាកម្រិតខ្ពស់ជាមួយនឹងនិក្ខេបបទវិជ្ជាជីវៈឬនិក្ខេបបទជំនាញអនុវត្ត។

ជាធម្មតា សញ្ញាបត្របណ្ឌិតស្រាវជ្រាវត្រូវបានគេផ្តល់ងារឬសរសេរជាបុព្វបទ«បណ្ឌិតទស្សនវិជ្ជាឬបណ្ឌិតស្រាវជ្រាវ (PhD)»។ រីឯសញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ/ឯកទេសដែលផ្អែកលើកិច្ចការសិក្សាកម្រិតខ្ពស់និងនិក្ខេបបទឬគម្រោងអនុវត្តជំនាញ គឺជាធម្មតាត្រូវបានគេផ្តល់ងារឬបុព្វបទជា«បណ្ឌិតរដ្ឋបាលធុរកិច្ច(DBA)» «បណ្ឌិតអប់រំ(DEd)» «បណ្ឌិតវិស្វកម្ម(DEng)» ឬឈ្មោះជំនាញដទៃទៀតដែលសមស្របទៅនឹងជំនាញវិជ្ជាជីវៈដែលពាក់ព័ន្ធ។

កម្មវិធីអប់រំកម្រិតបណ្ឌិតមានច្រើនប្រភេទ ប្រែប្រួលទៅតាមការរៀបចំឬសន្សំនៃការស្រាវជ្រាវនិងកិច្ចការសិក្សា និងការតម្រង់ទិសទៅរកវិជ្ជាជីវៈ។ សញ្ញាបត្របណ្ឌិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចែកចេញជាបីប្រភេទ ដូចខាងក្រោម៖

- **សញ្ញាបត្របណ្ឌិតស្រាវជ្រាវ** ជាប្រភេទសញ្ញាបត្រឧត្តមសិក្សាកម្រិតខ្ពស់បំផុតដែលត្រូវបានប្រគល់ជូនទៅបុគ្គលណាម្នាក់ ដោយផ្អែកទៅលើការទទួលស្គាល់ស្នាដៃផ្តើមទាំងខាងវិធីសាស្ត្រស្រាវជ្រាវ ទាំងខាងលទ្ធផលនៃការស្រាវជ្រាវដែលអាចបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ព្រមទាំងមានការចូលរួមចំណែកក្នុងការសិក្សាស្រាវជ្រាវសម្រាប់ការបង្កើតចំណេះដឹងនិងការអនុវត្តថ្មី។ កម្មវិធីអប់រំប្រភេទនេះជាធម្មតាត្រូវបន្តពីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ស្រាវជ្រាវដោយផ្អែកតាមរយៈស្នាដៃស្រាវជ្រាវដែលស្ថិតក្រោមការត្រួតពិនិត្យ។

- **សញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ** ជាប្រភេទសញ្ញាបត្រឧត្តមសិក្សាខ្ពស់បំផុត ដែលត្រូវបានប្រគល់ជូនទៅបុគ្គលណាម្នាក់ដែលបានសិក្សាមុខវិជ្ជាជំនាញដូចជា វេជ្ជសាស្ត្រ ទន្តវេទនសាស្ត្រ ឱសថសាស្ត្រ

វិស្វកម្ម អប់រំ ធុរកិច្ច និងវិចិត្រសិល្បៈ ជាដើម។ បុគ្គលទទួលបានសញ្ញាបត្រប្រភេទនេះ បំពេញការងារជាចម្បងនិងបានចងក្រងចំណេះដឹង ដែលបានពីការសិក្សានិងបទពិសោធការងារទៅតាមវិធីសាស្ត្រ។ បុគ្គលទទួលបានសញ្ញាបត្របណ្ឌិតប្រភេទនេះមានគោលបំណងជាចម្បង គឺការបង្កើនសមត្ថភាពវិជ្ជាជីវៈផ្ទាល់ខ្លួនឲ្យកាន់តែប្រសើរឡើង។ ចំពោះគោរមងារជាព្រឹទ្ធាចារ្យសិល្បៈ មានកម្រិតសមមូលនឹងសញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ។ កម្មវិធីអប់រំកម្រិតបណ្ឌិតប្រភេទនេះ ជាធម្មតាត្រូវបន្តពីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ដែលមានការរួមបញ្ចូលគ្នារវាងកិច្ចការសិក្សានិងការស្រាវជ្រាវ។

- **សញ្ញាបត្របណ្ឌិតកិត្តិយស** ជាសញ្ញាបត្របណ្ឌិតមួយប្រភេទដែលពុំមានរាប់បញ្ចូលក្នុងក្របខ័ណ្ឌគុណវុឌ្ឍិទេ និយាយរួមគឺសញ្ញាបត្របណ្ឌិតដែលគ្រឹះស្ថានឧត្តមសិក្សាប្រគល់ជូនបុគ្គលណាម្នាក់ដោយសារទទួលស្គាល់ស្នាដៃឆ្នើមកម្រិតខ្ពស់ដែលមានអត្ថប្រយោជន៍ដល់សង្គមនិងមនុស្សជាតិតាមរយៈសមិទ្ធផលការងារ ការសរសេរសៀវភៅ ឬការផ្សព្វផ្សាយការស្រាវជ្រាវជាដើម។

## ខ. លក្ខណៈនៃបុគ្គលដែលទទួលគុណវុឌ្ឍិនេះ

បុគ្គលទទួលគុណវុឌ្ឍិកម្រិតនេះត្រូវមាន៖

- ការយល់ដឹងយ៉ាងស៊ីជម្រៅពីចំណុចសំខាន់ៗនៃចំណេះដឹងនិងការស្រាវជ្រាវជាន់ខ្ពស់នៅក្នុងការអប់រំទូទៅឬក្នុងជំនាញវិជ្ជាជីវៈ
- ការយល់ច្បាស់ពីបញ្ហាដែលលេចឡើងចំពោះមុខនៃការអប់រំឬជំនាញវិជ្ជាជីវៈនិងការស្គាល់ពីបុព្វហេតុចម្បងនៃបញ្ហាទាំងនោះ សម្រាប់ការអនុវត្តនាពេលបច្ចុប្បន្ននិងការសន្និដ្ឋានដែលអាចទទួលយកបានជាទូទៅ
- ភាពមានចំណេះវិជ្ជាជ្រៅជ្រះខ្ពង់ខ្ពស់ទាក់ទងនឹងការសំយោគទ្រឹស្តី ការស្រាវជ្រាវក្នុងជំនាញដែលពាក់ព័ន្ធ ការបង្កើត និងការបកស្រាយចំណេះដឹងថ្មីតាមរយៈការស្រាវជ្រាវឬការអនុវត្តទ្រឹស្តីនិងការស្រាវជ្រាវក្នុងការរួមចំណែកយ៉ាងសំខាន់ទៅលើការអនុវត្តវិជ្ជាជីវៈ
- ការយល់ដឹងច្បាស់លាស់អំពីបច្ចេកទេសក្នុងការស្រាវជ្រាវដែលអាចអនុវត្តទៅលើជំនាញនៃការសិក្សាដែលពាក់ព័ន្ធ
- សមត្ថភាពក្នុងការចងក្រងលទ្ធផលនៃការស្រាវជ្រាវដែលបានធ្វើនៅក្នុងនិក្ខេបបទស្រាវជ្រាវឬរបាយការណ៍គម្រោងស្រាវជ្រាវនិងនៅក្នុងអត្ថបទបោះពុម្ពផ្សព្វផ្សាយជាឯកសារយោងសម្រាប់ការសិក្សាឬសម្រាប់វិជ្ជាជីវៈផ្សេងៗ។

បុគ្គលទទួលបានគុណវុឌ្ឍិកម្រិតនេះត្រូវ៖

- ប្រើប្រាស់បានយ៉ាងត្រឹមត្រូវនូវចំណេះដឹងនិង/ឬការយល់ដឹងជ្រៅជ្រះខាងវិជ្ជាជីវៈរបស់ខ្លួនទៅលើការអភិវឌ្ឍបន្ថែមផ្នែកចំណេះដឹងនិងការអនុវត្តក្នុងជំនាញរបស់ខ្លួនដែលជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍការយល់ដឹងនិងយុទ្ធសាស្ត្រថ្មីៗ
- ផ្តល់នូវភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងជំនាញរបស់ខ្លួននិងមានសមត្ថភាពក្នុងការផ្ទេរគំនិតនិងការសន្និដ្ឋានរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព

ដល់អ្នកពាក់ព័ន្ធនានាទោះជាអ្នកមានជំនាញឬគ្មានជំនាញក្តី

- អាចដោះស្រាយយ៉ាងជាប់លាប់និងហ្មត់ចត់នូវបញ្ហាស្មុគស្មាញដែលទាក់ទងនឹងអភិសមាចារនៅក្នុងរង្វង់ការអប់រំនិងវិជ្ជាជីវៈរបស់ខ្លួននិងផ្តួចផ្តើមបង្កើតបាននូវដំណោះស្រាយដ៏សមរម្យ ចំពោះបញ្ហាដែលជះឥទ្ធិពលដល់សហគមន៍ទាំងមូល។

## គ. លទ្ធផលសិក្សា

### ចំណេះដឹង៖

- មានការយល់ដឹងច្បាស់លាស់ពីចំណុចសំខាន់ៗនៃចំណេះដឹងក្នុងការអប់រំឬជំនាញវិជ្ជាជីវៈដោយរួមបញ្ចូលទាំងព័ត៌មានជាក់លាក់ ទ្រឹស្តី គោលការណ៍និងទស្សនាទានជាមូលដ្ឋាននានា
- យល់ដឹងពីការអភិវឌ្ឍចុងក្រោយនៅក្នុងជំនាញវិជ្ជាជីវៈរបស់ខ្លួន ដោយរួមទាំងបញ្ហាដែលកើតមានឡើងនិងបច្ចេកទេសក្នុងការស្រាវជ្រាវនិងបញ្ហាប្រឈមជាចម្បងក្នុងការអភិវឌ្ឍ ការសន្និដ្ឋានដែលអាចទទួលយកបានជាទូទៅ។ សម្រាប់ការសិក្សាកម្រិតបណ្ឌិតជំនាញវិជ្ជាជីវៈនិស្សិតត្រូវទទួលបានចំណេះដឹងច្បាស់លាស់និងទូលំទូលាយស្តីពីការផ្លាស់ប្តូរក្នុងការអនុវត្តជាក់ស្តែងទាំងក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ
- មានចំណេះដឹងច្បាស់លាស់ពីការអភិវឌ្ឍនៅក្នុងជំនាញពាក់ព័ន្ធដែលមានឥទ្ធិពលទៅលើការអនុវត្តវិជ្ជាជីវៈ។

### ជំនាញក្នុងការគិត៖

- អាចប្រើប្រាស់ការយល់ដឹងខាងទ្រឹស្តីនិងបច្ចេកទេសនៃការអង្កេត ដើម្បីយកមកវិភាគប្រកបដោយថ្លៃប្រឌិតលើព្រឹត្តិការណ៍និងបញ្ហាសំខាន់ៗ ព្រមទាំងអាចបង្កើតបាននូវដំណោះស្រាយថ្មីៗចំពោះបញ្ហាទាំងនោះ
- អាចសំយោគការស្រាវជ្រាវនិងការសរសេរទ្រឹស្តី ហើយអាចអភិវឌ្ឍនូវការយល់ដឹងថ្មីៗប្រកបដោយការច្នៃប្រឌិតដោយផ្អែកលើការធ្វើសមាហរណកម្មរវាងគំនិតទាំងក្នុងនិងក្រៅជំនាញសិក្សាជាន់ខ្ពស់របស់ខ្លួន
- អាចរៀបចំនិងដឹកនាំការស្រាវជ្រាវឬគម្រោងអភិវឌ្ឍន៍សំខាន់ៗ ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញនានាដែលទាក់ទងនឹងការអភិវឌ្ឍចំណេះដឹងថ្មីឬការធ្វើឲ្យកាន់តែប្រសើរឡើងក្នុងការងារប្រតិបត្តិវិជ្ជាជីវៈសំខាន់ៗ។

### ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ៖

- ប្រព្រឹត្តិយ៉ាងសមស្របជាមួយនឹងស្វ័យភាពនិងការផ្តើមគំនិតកម្រិតខ្ពស់ក្នុងសកម្មភាពវិជ្ជាជីវៈឬវិជ្ជាការជាន់ខ្ពស់
- ទទួលខុសត្រូវខ្ពស់ចំពោះសកម្មភាពរបស់ខ្លួន វាយតម្លៃ និងបង្កើនប្រសិទ្ធភាពការងាររបស់ខ្លួនតាមរយៈការទទួលយកមតិយោបល់ពិតនិងការធ្វើផែនការកែលម្អឲ្យកាន់តែប្រសើរឡើង
- [illegible]លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងសកម្មភាពការងារជាក្រុមនិងអនុវត្តយ៉ាង

មានប្រសិទ្ធភាពក្នុងភាពជាអ្នកដឹកនាំក្នុងបរិស្ថានសង្គមនិងវិជ្ជាជីវៈដ៏ស្មុគស្មាញ

- ដោះស្រាយបានយ៉ាងហ្មត់ចត់និងឆាប់រហ័សនូវបញ្ហាសីលធម៌ដ៏ស្មុគស្មាញ ធ្វើការវិនិច្ឆ័យដោយការស៊ើបអង្កេតប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌ និងធ្វើឲ្យបង្ហាញសេចក្ដីសន្និដ្ឋានឲ្យបានគ្រប់ជ្រុងជ្រោយទៅលើបញ្ហាឬកង្វល់ដែលប៉ះពាល់ទាំងនោះ។ ផ្ដួចផ្ដើមគំនិតក្នុងការលើកឡើងពីភាពមិនគ្រប់គ្រាន់ឬគ្មានប្រសិទ្ធភាពនៃក្រមសីលធម៌វិជ្ជាជីវៈដែលមានស្រាប់ ដើម្បីពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មឲ្យបានសមស្របនិងត្រឹមត្រូវ។

ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង៖

- ប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពនិងសមរម្យជាមួយអ្នកពាក់ព័ន្ធនៅក្នុងការសិក្សាទូទៅនិងវិជ្ជាជីវៈក៏ដូចជាក្នុងសហគមន៍ទាំងមូលតាមរយៈរបាយការណ៍និងបទបង្ហាញផ្លូវការនិងមិនផ្លូវការ និងតាមរយៈការបោះពុម្ពផ្សាយក្នុងការអប់រំទូទៅនិងវិជ្ជាជីវៈ ដូចជានិក្ខេបបទជំនាញឬរបាយការណ៍គម្រោងស្ដីពីបញ្ហាសំខាន់និងស្មុគស្មាញណាមួយ
- គណនានិងប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវទិន្នន័យ គណិតវិទ្យា និងស្ថិតិនិងប្រើប្រាស់បានយ៉ាងទូលំទូលាយនូវបច្ចេកវិទ្យាព័ត៌មានវិទ្យានិងទំនាក់ទំនងក្នុងការអង្កេតបញ្ហានិងការបង្ហាញសេចក្ដីសន្និដ្ឋាននិងអនុសាសន៍។

### ឃ. ច្រកសិក្សាដើម្បីទទួលបានគុណវុឌ្ឍិ

បេក្ខជនទូទៅត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់និងត្រូវបានរំពឹងទុកថាអាចបង្ហាញពីសក្ដានុពលក្នុងការបន្តការសិក្សាកម្រិតបណ្ឌិតតាមជំនាញសិក្សាដែលស្នើសុំ។ ក្នុងករណីខ្លះបេក្ខជនអាចបន្តការសិក្សារបស់ខ្លួនពីកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ទៅកម្រិតបណ្ឌិតតែម្ដង បើទោះបីជាគេមិនទាន់ទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឡើយ។ សម្រាប់កម្មវិធីកម្រិតបណ្ឌិតមួយចំនួន បទពិសោធក្នុងជំនាញវិជ្ជាជីវៈគឺជាតម្រូវការសំខាន់មួយ។

ដោយហេតុថាបេក្ខជនមានចំណេះនិងជំនាញពាក់ព័ន្ធផ្សេងៗគ្នាច្រើនប្រភេទ រយៈពេលនៃការសិក្សាក៏ប្រែប្រួលទៅតាមនោះដែរ។ ទោះជាយ៉ាងណាកម្មវិធីអប់រំកម្រិតបណ្ឌិតស្រាវជ្រាវឬបណ្ឌិតវិជ្ជាជីវៈភាគច្រើនតម្រូវឲ្យសិក្សារយៈពេលពី៣ទៅ៦ឆ្នាំនៃការសិក្សាពេញម៉ោង។

ព័ត៌មានបន្ថែមមានបញ្ជាក់នៅក្នុងអនុក្រឹត្យលេខ១៥១អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្ដីពីការបណ្ដុះបណ្ដាលកម្រិតបណ្ឌិត។

## ៤. ការគ្រប់គ្រងនិងចេញគុណវុឌ្ឍិ

### ៤.១ ការគ្រប់គ្រងនិងអភិវឌ្ឍ

ការគ្រប់គ្រងលើការអនុវត្ត និងអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជាត្រូវស្ថិតនៅក្រោមក្រសួងទទួលបន្ទុកវិស័យអប់រំ និងស្ថាប័នទទួលស្គាល់គុណភាពអប់រំ។

### ៤.២ ភាពខុសគ្នារវាងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនិងការអប់រំឧត្តមសិក្សា

កម្រិតគុណវុឌ្ឍិនៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការអប់រំឧត្តមសិក្សាទូទៅដែលមានឈ្មោះត្រួតគ្នានិងប្រហាក់ប្រហែលគ្នាត្រូវបានប្រើប្រាស់សម្រាប់វិស័យទាំងពីរ។ ដោយសារតែភាពផ្សេងគ្នានេះមានសារៈសំខាន់នៅក្នុងការជ្រើសរើសប្រភេទនៃការសិក្សា សហគមន៍សិក្សាត្រូវបញ្ជាក់ឲ្យបានត្រឹមត្រូវពីអ្វីដែលនិស្សិតបានរៀនដោយវែកញែកឲ្យបានច្បាស់លាស់ក្នុងការប្រើប្រាស់ឈ្មោះគុណវុឌ្ឍិទាំងនោះ។

ដើម្បីបង្ហាញពីភាពផ្សេងគ្នា ការប្រើប្រាស់ឈ្មោះគុណវុឌ្ឍិសម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គួរមានបញ្ចូលនូវពាក្យសព្ទបច្ចេកទេសមកជាមួយ។ ស័ព្ទ«បច្ចេកវិទ្យា»និង«បច្ចេកទេស» អាចប្រើសម្រាប់ផ្តល់ឈ្មោះគុណវុឌ្ឍិផ្សេងៗពីគ្នាទៅតាមជំនាញផ្សេងគ្នា។ ឧទាហរណ៍ បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសនិងជំនាញវិស្វកម្មមេកានិក បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសព័ត៌មានវិទ្យាឬបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសប្រព័ន្ធរដ្ឋបាល សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេសផលិតកម្មកម្មន្ត សញ្ញាបត្រជាន់ខ្ពស់បច្ចេក/ឯកទេសវិទ្យាសាស្ត្រកុំព្យូទ័រ សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស/ឯកទេសជំនាញអគ្គិសនី។

ដើម្បីធានាឲ្យមានភាពផ្សេងគ្នា ក្នុងការប្រើប្រាស់ឈ្មោះគុណវុឌ្ឍិរវាងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការអប់រំឧត្តមសិក្សា ពាក្យ«បច្ចេកទេស»ឬ«បច្ចេកវិទ្យា» គួរកុំយកមកប្រើជា ឈ្មោះគុណវុឌ្ឍិសិក្សាសម្រាប់ផ្នែកការអប់រំឧត្តមសិក្សា។

### ៤.៣ ការប្រើឈ្មោះជំនាញសិក្សា

សម្រាប់កម្មវិធីអប់រំឧត្តមសិក្សាកន្លែងណា ដែលមិនមានប្រើឈ្មោះជំនាញសិក្សាវិជ្ជាជីវៈទេនោះ ជាការចាំបាច់ណាស់ក្នុងការប្រើប្រាស់ការពិពណ៌នាទៅលើជំនាញសិក្សាឲ្យបានត្រឹមត្រូវនិងមានសង្គតិភាព។ ឈ្មោះជំនាញសិក្សា គឺជាពាក្យសព្ទដែលត្រូវប្រើសម្រាប់ពិពណ៌នាពីវិស័យសិក្សាទូទៅ (សិល្បៈ វិទ្យាសាស្ត្រ វិស្វកម្ម ។ល។) និងនៅក្នុងជំនាញសិក្សាពិសេសមួយចំនួន លើកលែងតែកម្មវិធីបណ្តុះបណ្តាលសម្រាប់កម្រិតសញ្ញាបត្រមួយចំនួនដែលត្រូវបានរៀបចំឡើងសម្រាប់ឈ្មោះគុណវុឌ្ឍិវិជ្ជាជីវៈ ដែលទាក់ទងទៅនឹងជំនាញវិជ្ជាជីវៈនោះ (បរិញ្ញាបត្រវិស្វកម្ម បរិញ្ញាបត្រពាណិជ្ជសាស្ត្រ បរិញ្ញាបត្រអប់រំ បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម។ល។)។

ស័ព្ទ«សិល្បៈ»គួរតែប្រើសម្រាប់ការសិក្សាផ្នែកមនុស្សសាស្ត្រឬវិទ្យាសាស្ត្រសង្គមនិងស័ព្ទ«វិទ្យាសាស្ត្រ» គួរប្រើសម្រាប់ការសិក្សាផ្នែកវិទ្យាសាស្ត្រពិតឬវិទ្យាសាស្ត្រអនុវត្តដែលរួមមានវិទ្យាសាស្ត្របរិស្ថាន ជីវវិទ្យា រូបវិទ្យា និងវិទ្យាសាស្ត្រវេជ្ជសាស្ត្រ។

នៅកម្រិតគុណវុឌ្ឍិក្រោយបរិញ្ញាបត្រស័ព្ទ«បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ» តែងប្រើសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រពិតឬវិទ្យាសាស្ត្រអនុវត្ត និងស័ព្ទ «បរិញ្ញាបត្រជាន់ខ្ពស់សិល្បៈ» ត្រូវប្រើសម្រាប់កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ស្រាវជ្រាវផ្នែកមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម និងស័ព្ទ «បណ្ឌិតស្រាវជ្រាវ» ត្រូវប្រើសម្រាប់កម្រិតសញ្ញាបត្របណ្ឌិតស្រាវជ្រាវក្នុងវិស័យណាមួយ។ ចំពោះសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ កម្រិតគុណវុឌ្ឍិក្រោយបរិញ្ញាបត្រ (បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសនិង

បណ្ឌិតវិជ្ជាជីវៈ) តម្រូវឲ្យនិស្សិតសិក្សាមុខវិជ្ជាតម្រូវក្នុងថ្នាក់ ភាគច្រើនដោយបូកបន្ថែមការសរសេរគម្រោងតាមជំនាញឬសរសេរជានិក្ខេបបទ ហើយឈ្មោះសញ្ញាបត្រ គឺដាក់តាមជំនាញសិក្សាដោយមិនមានស័ព្ទនៅពីមុខទេ។

តារាងគំរូឈ្មោះគុណវុឌ្ឍិសម្រាប់កម្រិតក្រោយមធ្យមសិក្សា

| កម្រិត | ផ្នែកទូទៅ (Academic) | ផ្នែកវិជ្ជាជីវៈ (Professional) |
|---|---|---|
| គុណវុឌ្ឍិកម្រិត៥៖<br>-បរិញ្ញាបត្ររង<br>-សញ្ញាបត្រជាន់ខ្ពស់ | បរិញ្ញាបត្ររងសិល្បៈឬបរិញ្ញាបត្ររងវិទ្យាសាស្ត្រ ឬបរិញ្ញាបត្ររង ... | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស ... (ជំនាញ) |
| គុណវុឌ្ឍិកម្រិត៦៖<br>- បរិញ្ញាបត្រ | បរិញ្ញាបត្រសិល្បៈឬបរិញ្ញាបត្រវិទ្យាសាស្ត្រ ឬបរិញ្ញាបត្រ ... | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស...(ឈ្មោះជំនាញវិជ្ជាជីវៈ - ដូចជា ពាណិជ្ជសាស្ត្រ អប់រំ វិស្វកម្ម) |
| គុណវុឌ្ឍិកម្រិត៧៖<br>- បរិញ្ញាបត្រជាន់ខ្ពស់ | បរិញ្ញាបត្រជាន់ខ្ពស់សិល្បៈឬវិទ្យាសាស្ត្រ (បរិញ្ញាបត្រជាន់ខ្ពស់ស្រាវជ្រាវ) | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស.. (ឈ្មោះជំនាញវិជ្ជាជីវៈ- ដូចជា ពាណិជ្ជ-សាស្ត្រ អប់រំ វិស្វកម្ម) |
| គុណវុឌ្ឍិកម្រិត៨៖<br>- បណ្ឌិត | បណ្ឌិតទស្សនវិជ្ជា(បណ្ឌិតស្រាវជ្រាវ) | បណ្ឌិត ...(ឈ្មោះជំនាញ វិជ្ជាជីវៈ -ដូចជា ពាណិជ្ជសាស្ត្រ អប់រំ វិស្វកម្ម) (បណ្ឌិតវិជ្ជាជីវៈ) |

<u>សម្គាល់</u>៖ ករណីដែលវិស័យជំនាញត្រូវរាប់បញ្ចូលជាមួយឈ្មោះគុណវុឌ្ឍិទូទៅ (ដូចជា សញ្ញាបត្រកសិកម្មឬបរិញ្ញាបត្រវិស្វកម្ម ជំនាញបច្ចេកវិទ្យាព័ត៌មានវិទ្យាឬបរិញ្ញាបត្រពាណិជ្ជសាស្ត្រ ជំនាញគណនេយ្យ) ការសិក្សាយ៉ាងតិច៥០% គួរស្ថិតនៅក្នុងវិស័យនៃជំនាញនោះ។

## ៤.៤ ការផ្តល់សញ្ញាបត្រកម្រិតបណ្ឌិត

សញ្ញាបត្របណ្ឌិតស្រាវជ្រាវ ប្រើសម្រាប់កម្មវិធីអប់រំកម្រិតបណ្ឌិតដែលផ្តោតលើការស្រាវជ្រាវជាសំខាន់។ សញ្ញាបត្របណ្ឌិតបច្ចេកវិទ្យា/ឯកទេស(វិជ្ជាជីវៈ) ដូចជា បណ្ឌិតរដ្ឋបាលធុរកិច្ច បណ្ឌិតអប់រំ បណ្ឌិតវិស្វកម្ម អាចរាប់បញ្ចូលជាសមាសភាគនៃការស្រាវជ្រាវកម្រិតខ្ពស់ ប៉ុន្តែសង្កត់ធ្ងន់ទៅលើកិច្ចការជាក់ស្តែងជាចម្បងនិងមុខវិជ្ជាតម្រូវសិក្សាក្នុងកម្រិត ក៏ដូចជាការសរសេរនិក្ខេបបទឬគម្រោង តាមជំនាញដើម្បីបញ្ចប់កម្រិតបណ្ឌិត។ សញ្ញាបត្រកម្រិតបណ្ឌិតទាំងពីរប្រភេទនេះ ស្ថិតនៅលើកម្រិត សមមូលគ្នា (មានតម្លៃស្មើគ្នា)។

សញ្ញាបត្របណ្ឌិតកិត្តិយស ជាសញ្ញាបត្រកិត្តិយសដែលគ្រឹះស្ថានឧត្តមសិក្សាប្រគល់ជូនបុគ្គលណាម្នាក់ដែលមានស្នាដៃឆ្នើមកម្រិតខ្ពស់ជួយជាវិភាគទានដល់សង្គមនិងមនុស្សជាតិ ហើយអាចរាប់បញ្ចូលឬមិនរាប់បញ្ចូលនូវវិភាគទានសម្រាប់គ្រឹះស្ថានឧត្តមសិក្សាដែលផ្តល់សញ្ញាបត្រកិត្តិយស។ សញ្ញាបត្រកិត្តិយស ជាទូទៅប្រើសម្រាប់បណ្ឌិតច្បាប់ឬបណ្ឌិតអក្សរសាស្ត្រ តែទោះជាយ៉ាងនេះក្តីងារបណ្ឌិតកិត្តិយស

នៃជំនាញពិសេស អាចនឹងប្រើប្រាស់សម្រាប់ស្នាដៃឆ្នើមឬភាគទានណាដែលនឹងត្រូវទទួលស្គាល់ជាបណ្ឌិតកិត្តិយសនៅក្នុងជំនាញនោះ។ អ្នកទទួលបានសញ្ញាបត្រកិត្តិយសទាំងនោះមានសិទ្ធិប្រើងារកិត្តិយសនោះ ប៉ុន្តែក៏មិនអាចប្រើបានដូចធម្មតា នៅក្នុងស្ថានភាពសាធារណៈទូទៅឡើយ។ ទោះយ៉ាងណា គ្រឹះស្ថានឧត្តមសិក្សាដែលផ្តល់សញ្ញាបត្រកិត្តិយស អាចប្រើងារកិត្តិយសជាមួយបុគ្គលនោះជាធម្មតាបាន។

### ៤.៨ ទម្រង់ស្នើសម្រាប់គុណវុឌ្ឍិ

គ្រប់គុណវុឌ្ឍិដែលចេញទាំងអស់ អាចរាប់បញ្ចូលនូវធាតុដូចខាងក្រោម៖

- ឈ្មោះ លេខកូដ និង ឡូហ្គោរបស់ស្ថាប័នឬគ្រឹះស្ថានដែលចេញ
- ឈ្មោះបុគ្គលដែលទទួលគុណវុឌ្ឍិ
- ឈ្មោះនិងប្រភេទគុណវុឌ្ឍិនៅក្នុង ក.គ.ជ.ក ដូចជា វិញ្ញាបនបត្រ សញ្ញាបត្រ ...
- កាលបរិច្ឆេទនៃការចេញ
- ហត្ថលេខាអ្នកដែលមានសិទ្ធិចេញ

នៅក្នុងវិស័យអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គួរបន្ថែមនូវធាតុមួយចំនួនដូចខាងក្រោម៖

- សេចក្តីបញ្ជាក់ពីប្រភេទឧស្សាហកម្ម ដូចជា វិស្វកម្ម
- ផ្នែកមុខរបរឬមុខងារ នៅក្នុងវង់ក្រចក ឧទាហរណ៍ (ផលិតកម្ម)
- ពាក្យ «គុណវុឌ្ឍិដែលបានផ្តល់ជូននេះ មានការទទួលស្គាល់នៅក្នុង ក.គ.ជ.ក»។

## ៥. បញ្ហានិងទំនាក់ទំនង

### ៥.១ ទំនាក់ទំនងរវាងការអប់រំឧត្តមសិក្សានិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

កម្មវិធីអប់រំនៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈផ្តោតជាសំខាន់ទៅលើសមត្ថភាពដែលទាញចេញដោយផ្ទាល់ពីតម្រូវការការងារសម្រាប់មុខរបរនិងអាជីពច្បាស់លាស់។ កម្មវិធីអប់រំឧត្តមសិក្សាផ្តោតជាចម្បងទៅលើសោលភាពនៃការស្រាវជ្រាវនិងការអភិវឌ្ឍនៃចំណេះដឹងឲ្យបានទូលំទូលាយនៅក្នុងជំនាញសិក្សានិងការប្រើប្រាស់នៃចំណេះដឹងទ្រឹស្តីនិងចំណេះដឹងអនុវត្តក្នុងការស្រាវជ្រាវនិងការអនុវត្តនៅក្នុងមុខរបរអាជីព។

ទោះយ៉ាងនេះក្តី ការអប់រំក្នុងវិស័យទាំងពីរនៅមានភាពស្រដៀងគ្នា។ នៅក្នុងវិស័យទាំងពីរ មានអង្គសំខាន់ពីរ គឺចំណេះដឹងនិងនិស្សិតដែលត្រូវបានរំពឹងទុកក្នុងការអភិវឌ្ឍសមត្ថភាពគិតនិងការដោះស្រាយបញ្ហា គុណភាព បុគ្គលិកលក្ខណៈនៃការទទួលខុសត្រូវ សុចរិតភាព និងសមត្ថភាពក្នុងការបន្តការសិក្សា។

លក្ខណៈនៃការបង្រៀននិងរៀននៅក្នុងវិស័យទាំងពីរគួរត្រូវបានបញ្ជាក់ឲ្យបានច្បាស់លាស់ ដូច្នេះការជ្រើសរើសជំនាញពិសេសអាចគ្រោងទុកជាមុនបានសម្រាប់កម្មវិធីអប់រំដែលត្រូវផ្តល់ជូននិស្សិត។ វាជាការចាំបាច់ដែរ ដែលត្រូវទទួលស្គាល់ថាកម្មវិធីអប់រំជំនាញដូចគ្នានៅក្នុងវិស័យទាំងពីរអាចមានបញ្ចូលមុខវិជ្ជា

សិក្សាប្រហាក់ប្រហាក់គ្នាជាច្រើន។ ដូច្នេះហើយ បើសិនជានិស្សិតដែលសិក្សានៅក្នុងវិស័យមួយមានបំណងបន្តការសិក្សាជំនាញដដែលទៅក្នុងវិស័យមួយទៀត (រវាងវិស័យអប់រំឧត្តមសិក្សានិងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ) គួរពិចារណាផ្តល់ឲ្យជាក្រេឌីតឬលើកលែងមុខវិជ្ជាដូចគ្នាឬសមមូលគ្នាដែលបានរៀនរួចហើយនៅក្នុងវិស័យដែលបានសិក្សាពីមុន។ នេះជាការចាំបាច់ក្នុងការផ្តល់ការគាំទ្រដល់ការផ្ទេរការសិក្សារបស់និស្សិត។

## ៥.២ ការទទួលស្គាល់ការសិក្សាពីមុនមក

និស្សិតភាគច្រើននឹងចាប់យកការសិក្សានៅកម្រិតឧត្តមសិក្សាតែម្តង បន្ទាប់ពីបញ្ចប់ការសិក្សាមធ្យមសិក្សាទុតិយភូមិនិងទទួលយកកម្មវិធីអប់រំពេញលេញនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ដូចគ្នានេះដែរ និស្សិតអាចចាប់យកការសិក្សានៅក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ បន្ទាប់ពីចេញពីសាលាមធ្យមសិក្សា។

ក្នុងករណីខ្លះនិស្សិតអាចនឹងអភិវឌ្ឍចំណេះដឹងនិងជំនាញសំខាន់ៗ តាមរយៈការអប់រំក្រៅប្រព័ន្ធ ឬនៅក្នុងការងារ។ នេះជាករណីសំខាន់ពិសេសនៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសម្រាប់កម្មវិធីបណ្តុះបណ្តាលណា ដែលផ្តោតលើសមត្ថភាពអនុវត្តជាចម្បងនិងសម្រាប់និស្សិតវ័យចំណាស់ដែលមានបទពិសោធការងារសមស្រប អាចចុះឈ្មោះសិក្សាក្នុងកម្មវិធីបណ្តុះបណ្តាលនានាដើម្បីទទួលបានគុណវុឌ្ឍិសិក្សាផ្លូវការឬដើម្បីអភិវឌ្ឍជំនាញរបស់ពួកគេ។

ពេលខ្លះនិស្សិតបំពេញការសិក្សាជាន់ខ្ពស់បន្តពីថ្នាក់ទី១២ ដែលមានលក្ខណៈមិនដូចគ្នាទាំងស្រុងក៏ដោយ ក៏អាចមានតម្លៃស្មើនឹងផ្នែកណាមួយនៃកម្មវិធីអប់រំនៅក្នុងគ្រឹះស្ថានដែលគេចុះឈ្មោះនោះដែរ។ ការសិក្សាជាន់ខ្ពស់នេះ អាចត្រូវបានរៀបចំឡើងតាមរយៈការផ្តល់ជូនកម្មវិធីអប់រំពិសេសក្នុងកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានដទៃឬតាមរយៈកម្មវិធីអប់រំបំពេញបន្ថែមដោយផ្នែកនៅក្នុងគ្រឹះស្ថានក្រោយមធ្យមសិក្សាផ្សេងទៀត។

និស្សិតគួរតែមិនត្រូវបានតម្រូវឲ្យបំពេញឡើងវិញនូវការងារដដែល ដែលពួកគេបានបញ្ចប់ដោយជោគជ័យនៅកន្លែងមួយផ្សេងទៀតរួចទៅហើយ។ គេគួរតែទទួលបានក្រេឌីតឬការសិក្សាកម្រិតខ្ពស់ជាងនៅពេលដែលមានការបង្ហាញថា ពួកគេមានចំណេះដឹងនិងជំនាញដែលសមមូលទៅនឹងលទ្ធផលសិក្សាដែលបានរៀបរាប់នៅក្នុងក្របខ័ណ្ឌគុណវុឌ្ឍិ ហើយពួកគេគួរតែត្រូវបានអនុញ្ញាតឲ្យបន្តការសិក្សាបន្ថែមតាមមធ្យោបាយដែលអាចបត់បែនបាន។

ម្យ៉ាងទៀត វាជាការផ្តល់អត្ថប្រយោជន៍ដល់និស្សិតដែលមិនមានប្រវត្តិឬព័ត៌មាននៃការសិក្សាគ្រប់គ្រាន់ក្នុងការបន្តការសិក្សារបស់ពួកគេ។ ជាការសំខាន់ផងដែរដែលគ្រឹះស្ថានបានកំណត់ពីលក្ខណៈពិសេសរបស់និស្សិត ដែលឆ្លុះបញ្ចាំងពីបេសកកម្មនិងគោលបំណងរបស់គ្រឹះស្ថានដោយអនុញ្ញាតដល់និស្សិតដែលទទួលបានការសិក្សាកម្រិតខ្ពស់ជាងមានឱកាសនៅក្នុងគ្រឹះស្ថានសិក្សាថ្មីដែលគេសិក្សា ដើម្បីអភិវឌ្ឍលក្ខណៈពិសេសទាំងនោះ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ និងស្ថាប័នទទួលស្គាល់គុណភាពអប់រំ ត្រូវរៀបចំគោលការណ៍ និងសេចក្តីណែនាំក្នុងការប្រតិបត្តិ សម្រាប់ដំណើរការទទួលស្គាល់ការសិក្សាពីមុនដែលនឹងផ្តល់នូវ...

រួមនិងឯកភាពថ្នាក់ជាតិទាំងការទទួលស្គាល់ការសិក្សាពីមុន និងការផ្ទេរក្រេឌីតឆ្លងកាត់រវាងវិស័យអប់រំឧត្តមសិក្សានិងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យមានលក្ខណៈស្តង់ដាច្បាស់លាស់។

គ្រឹះស្ថានគួរបង្កើតគោលនយោបាយនិងដំណើរការ សម្រាប់វាយតម្លៃសាវតាររបស់និស្សិតដែលអាចទទួលបានការសិក្សាកម្រិតខ្ពស់ជាង ដើម្បីឆ្ពោះទៅទទួលបានវិជ្ជាជីវៈបច្ចេកទេសឬការសិក្សានៅឧត្តមសិក្សានិងផ្តល់នូវការប្រឹក្សា និងការណែនាំសម្រាប់និស្សិតដែលទទួលបានការសិក្សាកម្រិតខ្ពស់ជាងអំពីដំណើរការទាំងនោះ។គ្រឹះស្ថានក៏គួរធ្វើការពិនិត្យលើកិច្ចការរបស់និស្សិតទាំងនេះនិងកែសម្រួលដំណើរការនិងលក្ខណវិនិច្ឆ័យរបស់គ្រឹះស្ថានតាមការចាំបាច់។

ការទទួលខុសត្រូវលើការកំណត់សិទ្ធិទទួលចូលសិក្សាក្នុងកម្មវិធីអប់រំឬបណ្តុះបណ្តាល និងចំនួនក្រេឌីតឬឯកតាសមត្ថភាពដែលបានផ្តល់ជូនលើការសិក្សាដែលមានពីមុន ត្រូវទុកសិទ្ធិឲ្យគ្រឹះស្ថានដែលនិស្សិតចុះឈ្មោះសិក្សា។ ប៉ុន្តែជាការណែនាំទូទៅ និស្សិតដែលបានបញ្ចប់គុណវុឌ្ឍិសញ្ញាបត្របច្ចេកទេសនៅមហាវិទ្យាល័យបច្ចេកវិទ្យាឬវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់ អាចទទួលបានចំនួនក្រេឌីតប្រមាណ៣០ក្រេឌីតនៃការសិក្សាមុខវិជ្ជាសមមូលគ្នា។ អាស្រ័យទៅតាមខ្លឹមសារជាក់លាក់របស់មុខវិជ្ជាដែលពាក់ព័ន្ធ ចំនួនក្រេឌីតនេះអាចនឹងបង្កើនឬបន្ថយតិចជាង៣០ក្រេឌីត ហើយអាចជាការចាំបាច់ត្រូវបង្កើតបញ្ញត្តិសម្រាប់កម្មវិធីផ្ទេរពិសេសនៅក្នុងវិស័យមុខវិជ្ជា ដែលតម្រូវការជាមុនសម្រាប់ការសិក្សាកម្រិតខ្ពស់បន្ទាប់។

## ៤.៣ ការរំពឹងទុកស្តីពីការចូលសិក្សាក្រោយមធ្យមសិក្សា

ក្របខ័ណ្ឌគុណវុឌ្ឍិ គឺផ្អែកទៅតាមការសន្មតថានិស្សិតដែលចូលសិក្សានៅក្នុងការអប់រំឬការបណ្តុះ-បណ្តាលកម្រិតក្រោយមធ្យមសិក្សា បានបញ្ចប់កម្មវិធីមធ្យមសិក្សាឬកម្មវិធីសមមូលពេញលេញ និងបានទទួលចំណេះដឹងនិងជំនាញ ដើម្បីចូលសិក្សាប្រកបដោយប្រសិទ្ធភាពនៅកម្រិតក្រោយមធ្យមសិក្សាតាមជំនាញសិក្សាដែលពួកគេបានជ្រើសរើស។ សាវតារនៃការសន្មតនេះ រាប់បញ្ចូលទាំងសមត្ថភាពសរសេរនិងផ្ទាល់មាត់ក្នុងភាសាសិក្សាអប់រំ សមត្ថភាពច្នៃប្រឌិត និងការអនុវត្តចំណេះដឹងនិងជំនាញគិតវិភាគដែលទទួលបានពីការសិក្សាមុខវិជ្ជាពាក់ព័ន្ធ និងសមត្ថភាពធ្វើការដោយឯករាជ្យនិងការទទួលខុសត្រូវលើការសិក្សារបស់ខ្លួន។ ការសន្មតនេះ រាប់បញ្ចូលផងដែរនូវតម្រូវការជាមុនសម្រាប់ការសិក្សាជំនាញពិសេស។

និស្សិតដែលមានលក្ខណសម្បត្តិច្បាស់លាស់តាមតម្រូវការនៃកម្រិតគុណវុឌ្ឍិដែលរំពឹងទុក អាចបន្ត ដោយផ្ទាល់ក្នុងកម្មវិធីអប់រំដូចមានរៀបរាប់ក្នុងក្របខ័ណ្ឌគុណវុឌ្ឍិ។

និស្សិតអាចនឹងត្រូវបំពេញការសិក្សាថ្នាក់ត្រៀមឬថ្នាក់មូលដ្ឋានដែលរៀបចំឡើង ដើម្បីធានាឲ្យពួកគេមានចំណេះដឹងភាសា ជំនាញសិក្សា និងប្រវត្តិសិក្សាចាំបាច់ ដើម្បីទទួលបានជោគជ័យនៅក្នុងការសិក្សាកម្រិតក្រោយមធ្យមសិក្សា។ ការតម្រូវឲ្យសិក្សាថ្នាក់ត្រៀម មិនមែនជាផ្នែកមួយនៃកម្មវិធីអប់រំកម្រិតក្រោយមធ្យមសិក្សាឡើយ។ ចំនួនក្រេឌីតដែលអាចនឹងត្រូវបានបែងចែកសម្រាប់ការសិក្សាមូលដ្ឋានឬថ្នាក់ត្រៀមនេះ មិនរាប់បញ្ចូល ដើម្បីទទួលបានកម្រិតអប់រំក្រោយមធ្យមសិក្សាទេ។

## ៤.៤ ទំនាក់ទំនងរវាងតម្រូវការស្រាវជ្រាវនិងវិជ្ជាជីវៈនៅក្នុងឧត្តមសិក្សា

[illegible]ខុសគ្នាសំខាន់រវាងកម្មវិធីអប់រំស្រាវជ្រាវ ដែលផ្តោតទៅលើការស្រាវជ្រាវនិងការបង្រៀ

ចំណេះដឹងចូលក្នុងជំនាញដែលមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការងារវិជ្ជាជីវៈ និងកម្មវិធីអប់រំផ្សេងទៀតដែលរៀបចំឡើង ដើម្បីផ្តល់ដល់និស្សិតនូវចំណេះដឹងនិងជំនាញកម្រិតខ្ពស់ដែលជាតម្រូវការសម្រាប់អាជីពវិជ្ជាជីវៈ។

កម្មវិធីអប់រំទាំងពីរប្រភេទមិនមែនដាច់ដោយឡែកពីគ្នានោះទេ។ កម្មវិធីអប់រំស្រាវជ្រាវគួរអភិវឌ្ឍសមត្ថភាពដែលអាចមានតម្លៃសំខាន់សម្រាប់ការងារក៏ដូចជាសម្រាប់ជីវិតប្រចាំថ្ងៃ ចំណែកឯកម្មវិធីអប់រំវិជ្ជាជីវៈ គួរធ្វើឲ្យពាក់ព័ន្ធទៅនឹងការយល់ដឹងខាងចំណេះដឹងទ្រឹស្តីនិងការស្រាវជ្រាវនៅក្នុងជំនាញសិក្សានិងវិស័យដែលជាប់ទាក់ទងគ្នានិងអភិវឌ្ឍគំនិតទូទៅនិងសមត្ថភាពដោះស្រាយបញ្ហាដែលអាចអនុវត្តបាននៅក្នុងបរិបទណាមួយ។ ទោះជាយ៉ាងនេះក្តី ការសង្កត់ធ្ងន់ពីភាពផ្សេងគ្នាគួរមានការឆ្លុះបញ្ចាំងនៅក្នុងខ្លឹមសារកម្មវិធីអប់រំលម្អិតនិងនៅក្នុងឈ្មោះកម្រិតគុណវុឌ្ឍិ។

ការបញ្ចប់កម្មវិធីអប់រំឧត្តមសិក្សាពីគ្រឹះស្ថានដែលមានការទទួលស្គាល់គុណភាពអប់រំនិងការផ្តល់ឲ្យសញ្ញាបត្រសិក្សាតែងតែទទួលបានជាមួយនឹងសិទ្ធិអនុវត្តវិជ្ជាជីវៈ។ ដូច្នេះហើយ វាមានសារៈសំខាន់ ក្នុងការពិចារណាថា មិនមែនគ្រាន់តែកម្រិតចំណេះដឹងនិងជំនាញទូទៅដែលកម្មវិធីអប់រំផ្តោតជាសំខាន់ដើម្បីអភិវឌ្ឍសមត្ថភាពនិស្សិតដូចដែលមានរៀបរាប់នៅក្នុងក្របខ័ណ្ឌនេះប៉ុណ្ណោះទេ ប៉ុន្តែចំណេះដឹង និងជំនាញពិសេសដែលចាំបាច់សម្រាប់វិជ្ជាជីវៈរបស់និស្សិតក៏នឹងត្រូវរៀបចំផងដែរ។ អ្វីដែលជាការជាប់ទាក់ទងគ្នារវាងកម្មវិធីអប់រំទាំងពីរជាទូទៅអាចប្រៀបធៀបគ្នាបាននៅក្នុងគ្រឹះស្ថានផ្សេងគ្នានិងនៅក្នុងប្រទេសផ្សេងគ្នានិងតម្រូវការពិសេសដែលទាក់ទងទៅនឹងព្រះរាជាណាចក្រកម្ពុជា។ ជាការណែនាំ គ្រឹះស្ថានគួរពិចារណាពីតម្រូវការកម្មវិធីបណ្តុះបណ្តាលពិសេស របស់ស្ថាប័នទទួលស្គាល់គុណភាពអប់រំជំនាញ ឬ ស្ថាប័នវិជ្ជាជីវៈក៏ដូចជាតម្រូវការពិសេសណាមួយសម្រាប់អនុវត្តវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា។

ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ បង្កើតកម្រិតគុណវុឌ្ឍិនិងតម្រូវការជំនាញតាមប្រភេទសម្រាប់គ្រប់គុណ-វុឌ្ឍិទាំងអស់។ មានការរំពឹងទុកថា ការបន្ថែមទៅលើតម្រូវការចំណេះដឹងនិងជំនាញពិសេសសម្រាប់មុខរបរវិជ្ជាជីវៈនានានឹងត្រូវបានធ្វើឡើងសម្រាប់កម្ពុជា។ ក្នុងរយៈពេលនៃការរៀបចំ គ្រឹះស្ថានត្រូវទទួលខុសត្រូវលើការអភិវឌ្ឍកម្មវិធីអប់រំនិងនីតិវិធីវាយតម្លៃរបស់ខ្លួន ដើម្បីធានាថាវាពិតជាបានឆ្លើយតបទៅនឹងតម្រូវការសម្រាប់ការអនុវត្តក្នុងវិជ្ជាជីវៈនិងលក្ខណវិនិច្ឆ័យសម្រាប់ការទទួលស្គាល់គុណភាពអប់រំ និងគិតបញ្ចូលទាំងភាពគ្រប់គ្រាន់នៃនីតិវិធីទាំងនោះ។

នៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តម្រូវការសមត្ថភាពនិងជំនាញត្រូវបានកំណត់តាមរយៈការពិគ្រោះយោបល់ជាមួយសហគ្រាសឬក្រុមហ៊ុន ហើយការកំណត់នូវតម្រូវការជំនាញទាំងនោះសម្រាប់គុណវុឌ្ឍិនីមួយៗ ត្រូវធ្វើឡើងតាមការប្រឹក្សាយោបល់និងក្នុងន័យបញ្ជាក់ពីការទទួលស្គាល់គុណភាពដោយត្រូវបង្ហាញឲ្យឃើញថា និស្សិតនឹងទទួលបាននូវសមត្ថភាពនិងជំនាញទាំងនោះយ៉ាងពិតប្រាកដ។

### ៥.៥ កម្មវិធីអប់រំនិងកម្រិតគុណវុឌ្ឍិទទួលបានដែលផ្តល់ដោយសមាគមវិជ្ជាជីវៈ

សមាគមវិជ្ជាជីវៈមួយចំនួនដែលមានទីតាំងនៅក្នុងប្រទេសដទៃ អាចផ្តល់ការទទួលស្គាល់ [illegible] បទពិសោធវិជ្ជាជីវៈឬការបណ្តុះបណ្តាលជំនាញឯកទេសនូវកម្រិតឬឋានៈជា«សញ្ញាបត្រវ [illegible]

«សញ្ញាបត្រ» ឬ «កម្រិតស្មើ» និងពេលខ្លះធ្វើការបណ្តុះបណ្តាលបែបនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ កម្មវិធីអប់រំនិងទម្រង់បណ្តុះបណ្តាលនៃការទទួលស្គាល់ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា ពេលខ្លះត្រូវបានផ្តល់ដោយក្រុមហ៊ុនកុំព្យូទ័រ ដើម្បីទទួលស្គាល់បទពិសោធនិងជំនាញក្នុងការប្រើប្រាស់ប្រព័ន្ធរបស់គេ។

កម្មវិធីអប់រំនិងបណ្តុះបណ្តាលបែបនេះមួយចំនួន អាចត្រូវបានគេផ្តល់តម្លៃនិងផ្តល់ការទទួលស្គាល់ខ្ពស់។ ប៉ុន្តែភាគច្រើននៃកម្មវិធីអប់រំតាមលក្ខណៈបែបនេះ មិនត្រូវបានគេទទួលស្គាល់ឬផ្តល់តម្លៃ ដូចជាគុណវុឌ្ឍិកម្រិតសញ្ញាបត្រឬលទ្ធផលសិក្សានៃការស្រាវជ្រាវនោះទេ ហើយកម្មវិធីអប់រំនិងកម្រិតទទួលបានទាំងនេះក៏មិនស្ថិតនៅក្នុងផ្នែកណាមួយនៃក្របខ័ណ្ឌគុណវុឌ្ឍិនេះដែរ។ ទោះជាគ្រឹះស្ថានឧត្តមសិក្សាខ្លះអាចទទួលស្គាល់ការសិក្សាទាំងនោះនិងផ្តល់ជាក្រេឌីត ដើម្បីបន្តយកគុណវុឌ្ឍិនៅកម្រិតឧត្តមសិក្សាដែលគ្រឹះស្ថានផ្តល់ការបណ្តុះបណ្តាល។ ឱកាសបែបនេះត្រូវផ្តល់តាមកម្រិតតម្រូវការនិងអភិវឌ្ឍតាមស្តង់ដាលទ្ធផលសិក្សារំពឹងទុកដែលមានក្នុងកម្មវិធីបណ្តុះបណ្តាល។

## ៤.៦ កម្រិតបញ្ចប់មធ្យមឬពាក់កណ្តាលនៃកម្មវិធីអប់រំរយៈពេលវែង

កម្មវិធីអប់រំសម្រាប់ទទួលបានគុណវុឌ្ឍិ ត្រូវតែផ្តល់លំដាប់នៃសកម្មភាពទាក់ទងគ្នាដែលរៀបចំឡើង ដើម្បីបង្កើតសំណុំសមត្ថភាពដែលអ្នកបញ្ចប់ការសិក្សាត្រូវទទួលបាន។ វាមិនមែនជាការសន្សំឬការបណ្តាក់ក្រេឌីតសាមញ្ញនោះទេ។ ទោះជាកម្រិតបញ្ចប់ពាក់កណ្តាលនៃកម្មវិធីអប់រំរយៈពេលវែង ត្រូវបានផ្តល់ឲ្យនិស្សិត ឧទាហរណ៍ សញ្ញាបត្រដែលចេញសម្រាប់និស្សិតដែលបានបញ្ចប់ការសិក្សារយៈពេលពីរឆ្នាំដំបូងនៃកម្មវិធីអប់រំរយៈពេលវែង ចាំបាច់ត្រូវតែជាគុណវុឌ្ឍិមួយដែលមានប្រយោជន៍ឬប្រើការបាន ហើយនិស្សិតនោះមានចំណេះដឹងនិងជំនាញដែលមានតម្លៃត្រឹមកម្រិតដែលបានបញ្ចប់។ កម្មវិធីអប់រំដែលរៀបចំឡើងសម្រាប់កម្រិតទាំងនេះ អាចមានការតម្រង់ទិសទៅរកការអនុវត្តច្រើនជាងការសិក្សារយៈពេលពីរឆ្នាំដំបូងនៃកម្មវិធីអប់រំរយៈពេលវែង ដែលជាការសិក្សាតម្រង់ទៅរកមូលដ្ឋានគ្រឹះសម្រាប់បន្តទៅកម្រិតគុណវុឌ្ឍិរយៈពេលវែងពេញលេញ។

ដូច្នេះហើយ គ្រឹះស្ថានសិក្សាមិនអាចសម្រេចផ្តល់សញ្ញាបត្រឲ្យទៅនិស្សិតដែលបានបញ្ចប់ការសិក្សារយៈពេលពីរឆ្នាំដំបូងនៃកម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រ ឬសម្រេចផ្តល់សញ្ញាបត្រជាន់ខ្ពស់ឲ្យ ទៅនិស្សិតដែលចុះឈ្មោះសិក្សាកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ដែលធ្លាក់មុខវិជ្ជាមួយចំនួន លុះត្រាកម្មវិធីអប់រំ នោះមានការអនុញ្ញាតនិងគ្រោងទុកជាស្រេចសម្រាប់កម្រិតបញ្ចប់តាមដំណាក់កាលទាំងនោះ។

ដូចគ្នានេះដែរចំពោះកម្មវិធីអប់រំរយៈពេលខ្លីដែលត្រូវបានពង្រីកពេលវេលាអប់រំ ជាឧទាហរណ៍ កម្មវិធីអប់រំកម្រិតសញ្ញាបត្រជាន់ខ្ពស់បានពង្រីកពេលវេលានិងផ្លាស់ប្តូរទៅកម្រិតបរិញ្ញាបត្រ គ្រឹះស្ថានសិក្សាត្រូវពិនិត្យឡើងវិញលើកម្មវិធីអប់រំទាំងមូល ដើម្បីធានាថាសមាសភាគនៃកម្មវិធីអប់រំនិងលំដាប់នៃសកម្មភាពមានភាពសមស្រប សម្រាប់ការអភិវឌ្ឍចំណេះដឹងនិងជំនាញខ្ពស់បន្ថែមតាមតម្រូវការនៃកម្រិតសិក្សាថ្មី។ ពោល គឺគ្រឹះស្ថានសិក្សាមិនអាចបញ្ចូលក្នុងកម្មវិធីអប់រំដែលមានស្រាប់ដោយពុំមានការពិនិត្យឡើងវិញទៅលើ[illegible]នៃកម្មវិធីអប់រំទាំងមូលនោះឡើយ។

### ៤.៧ សមមូលភាពនៃសញ្ញាបត្រក្នុងកម្រិតអន្តរជាតិ

ការទទួលស្គាល់ស្តង់ដាសមមូលជាមួយនឹងស្តង់ដាអន្តរជាតិ គឺជាការសំខាន់។ ការតម្រូវសម្រាប់គុណវុឌ្ឍិអាចនឹងយកមកប្រើជាការណែនាំយ៉ាងមានប្រយោជន៍ក្នុងការបង្កើតស្តង់ដាសមមូល។

ជាគោលការណ៍ គុណវុឌ្ឍិបរិញ្ញាបត្រដែលមានកម្មវិធីបណ្តុះបណ្តាល៤ឆ្នាំនៅក្នុងក្របខ័ណ្ឌនេះ មានតម្លៃសមមូលទៅនឹងកម្រិតបរិញ្ញាបត្រនៅក្នុងប្រទេសដទៃនៃតំបន់អាស៊ាន សមមូលនឹងបរិញ្ញាបត្រកិត្តិយសនៅចក្រភពអង់គ្លេសឬសមមូលនឹងកម្រិតបរិញ្ញាបត្រនៅអឺរ៉ុប អាមេរិកខាងជើង អូស្ត្រាលី និងកន្លែងផ្សេងទៀតនៅក្នុងពិភពលោក។ ការអនុវត្តនេះមិនមែនសម្រាប់តែកម្រិតបរិញ្ញាបត្រប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់គ្រប់គុណវុឌ្ឍិដែលផ្តល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការអនុវត្តនេះ ធ្វើឡើងលើគ្រប់កម្មវិធីអប់រំដែលផ្តល់ដោយគ្រឹះស្ថានសិក្សាដែលមានការទទួលស្គាល់គុណភាពអប់រំ។ គ្រប់កម្មវិធីអប់រំ និងបណ្តុះបណ្តាលសម្រាប់គុណវុឌ្ឍិគួរផ្តល់ឲ្យមានចំណេះដឹងជំនាញទូទៅនិងជំនាញវិជ្ជាជីវៈភ្ជាប់ជាមួយនឹងការសិក្សាសម្រាប់គុណវុឌ្ឍិ ដែលអាចប្រដូចគ្នាបានពេញពិភពលោក។

ខណៈដែលការបញ្ជាក់ភាពច្បាស់លាស់នៃក្របខ័ណ្ឌគុណវុឌ្ឍិ ត្រូវប្រមូលផ្តុំចងក្រងជាមួយកម្មវិធីអប់រំនិងបណ្តុះបណ្តាលដែលមានផ្តល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា តម្រូវការនិងឱកាសនៃការទទួលស្គាល់មានភាពខុសគ្នាទៅតាមតំបន់ផ្សេងគ្នានៃពិភពលោក ហើយការសិក្សាដែលធ្វើឡើងនៅកន្លែងផ្សេងអាចនឹងឆ្លុះបញ្ចាំងពីភាពផ្សេងគ្នានៃតម្រូវការនិងរចនាសម្ព័ន្ធនៅក្នុងប្រព័ន្ធអប់រំផ្សេងគ្នា។ សម្រាប់គោល-បំណងនៃការវាយតម្លៃកម្រិតសមមូលនៃការសិក្សាដែលបានបញ្ចប់នៅកន្លែងដទៃ ក្របខ័ណ្ឌគុណវុឌ្ឍិនឹងត្រូវយកមកប្រើជាគោលការណ៍ដើម្បីវាយតម្លៃ ប៉ុន្តែត្រូវមានការពិចារណាទៅលើឋានៈនៃក្របខ័ណ្ឌគុណវុឌ្ឍិដែលពាក់ព័ន្ធគ្នានិងវិសាលភាពនៃការសិក្សា ដែលបានទទួលស្គាល់ជាគុណវុឌ្ឍិវិជ្ជាជីវៈនៅក្នុងយុត្តាធិការដទៃ (ទទួលស្គាល់ដោយស្ថាប័នផ្សេងដែលមានសមត្ថកិច្ច)។ ដូច្នេះគុណវុឌ្ឍិត្រូវបានវាយតម្លៃតាមករណីនីមួយៗ គឺធ្វើមួយករណីម្តងៗ។ នេះអាចជាលទ្ធផលនៅក្នុងកម្មវិធីអប់រំនិងបណ្តុះបណ្តាលរយៈពេលវែង ឬខ្លីដែលត្រូវទទួលយកសម្រាប់គោលបំណងការងារឬបៀវត្ស ឬសម្រាប់ការទទួលចូលទៅសិក្សាកម្រិតក្រោយបរិញ្ញាបត្រ គឺសមមូលទៅនឹងគុណវុឌ្ឍិសញ្ញាបត្រដែលផ្តល់នៅកម្ពុជា។ ទោះជាយ៉ាងនេះក្តីការទទួលយល់ព្រមលើសញ្ញាបត្រទាំងនោះ ជាគុណវុឌ្ឍិគឺមិនប៉ះពាល់ទៅលើអ្វីដែលជាតម្រូវការសម្រាប់កម្មវិធីអប់រំដែលផ្តល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៤.៨ ការអនុវត្តក្របខ័ណ្ឌគុណវុឌ្ឍិជាតិទៅលើគ្រឹះស្ថានអន្តរជាតិ

ជំនួយដែលផ្តល់ឲ្យនិស្សិតនិងគ្រឹះស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយស្ថាប័នអន្តរជាតិត្រូវបានទទួលស្វាគមន៍និងត្រូវបានយល់ថាជាការទទួលបាននូវគុណវុឌ្ឍិស្រាវជ្រាវឬបច្ចេកទេសដែលចេញដោយគ្រឹះស្ថានណាមួយហើយនិស្សិតត្រូវបំពេញឲ្យបាននូវរាល់លក្ខខណ្ឌតម្រូវរបស់គ្រឹះស្ថាននោះ។

ទោះជាយ៉ាងនេះក្តី គេមិនអាចផ្លាស់ប្តូរឬលុបចោលការរំពឹងទុកនៃកម្មវិធីអប់រំនៅក្នុងព្រះរាជា-ណាចក្រកម្ពុជាតែជាការបំពេញនូវលក្ខខណ្ឌតម្រូវដែលបានបង្កើតនៅកម្ពុជា។ ទាំងនេះពុំប៉ះពាល់ដល់សង្គតិភាព ជាមួយក្របខ័ណ្ឌគុណវុឌ្ឍិជាតិដែលរួមមានការអនុលោមតាមការតម្រូវចំនួន[illegible]

សម្រាប់ការសិក្សាប្រចាំឆ្នាំ និងការបង្កើតនូវលទ្ធផលសិក្សានៅក្នុងវិស័យផ្សេងគ្នា។

កម្មវិធីអប់រំនិងបណ្តុះបណ្តាលដែលផ្តល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងឲ្យស្របទៅនឹងបរិបទប្រទេសកម្ពុជា ប្រវត្តិ បទពិសោធ និងតម្រូវការសិក្សារបស់និស្សិត។ កម្មវិធីអប់រំនិងបណ្តុះបណ្តាលទាំងនោះ ត្រូវរាប់បញ្ចូលទាំងចំណេះដឹងនៃបទប្បញ្ញត្តិនិងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលជាការពាក់ព័ន្ធទៅនឹងកម្មវិធីបណ្តុះបណ្តាលនិងសមត្ថភាពប្រើប្រាស់គំនិតទ្រឹស្តី ដើម្បីដោះស្រាយបញ្ហា។ កម្មវិធីអប់រំនិងបណ្តុះបណ្តាលជាច្រើនមានភាពទន់ភ្លន់គ្រប់គ្រាន់ ដើម្បីតម្រូវតាមការរំពឹងទុករបស់កម្មវិធីអប់រំទាំងចំណេះដឹងនៃបទប្បញ្ញត្តិនិងការអនុវត្ត ប៉ុន្តែក្នុងករណីខ្លះចាំបាច់ត្រូវមានការសិក្សាបន្ថែមឬជំនួសដើម្បីបំពេញបានតាមសំណុំនៃតម្រូវការទាំងពីរ។

## ៩.៩ ការផ្ទៀងផ្ទាត់ស្តង់ដា

ក្របខ័ណ្ឌគុណវុឌ្ឍិផ្តល់ការណែនាំសម្រាប់បុគ្គលិកសិក្សា និស្សិត និយោជក និងមន្ត្រីវាយតម្លៃគុណភាពអប់រំ អំពីស្តង់ដាដែលទាក់ទងនឹងវិសាលភាពនៃចំណេះដឹង កម្រិតជំនាញ និងសមត្ថភាព។ ស្តង់ដាទាំងនោះត្រូវបានរៀបចំជាវាក្យសព្ទទូទៅនិងទាមទារការបកស្រាយដោយអ្នកដែលមានបទពិសោធលើជំនាញដែលពាក់ព័ន្ធគ្នានិងចំណេះដឹងលើស្តង់ដាសមិទ្ធផលក្នុងគ្រឹះស្ថានឧត្តមសិក្សាឬគ្រឹះស្ថានបច្ចេកទេសអន្តរជាតិ។ នេះជាផ្នែកមួយនៃការទទួលខុសត្រូវលើការធានាគុណភាពអប់រំផ្ទៃក្នុងរបស់គ្រឹះស្ថានទាំងអស់ ដែលផ្តល់កម្មវិធីអប់រំនិងបណ្តុះបណ្តាលកម្រិតក្រោយមធ្យមសិក្សាក្នុងការទទួលបានការផ្ទៀងផ្ទាត់ដោយឯករាជ្យ ថាស្តង់ដាដែលបានដាក់ចេញនៅក្នុងក្របខ័ណ្ឌគុណវុឌ្ឍិជាតិកំពុងសម្រេចបានប្រកបដោយសង្គតិភាព។ យុទ្ធសាស្ត្រសម្រាប់ទទួលបានការផ្ទៀងផ្ទាត់នេះនឹងក្លាយទៅជាលក្ខខណ្ឌចាំបាច់សម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានទាំងមូលនិងលើកម្មវិធីអប់រំនិងបណ្តុះបណ្តាលនីមួយៗ។

យុទ្ធសាស្ត្រទូទៅដែលត្រូវបានប្រើប្រាស់ដោយគ្រឹះស្ថានសិក្សា ដើម្បីផ្ទៀងផ្ទាត់ស្តង់ដា រួមមានការពិនិត្យ ការផ្តល់ពិន្ទុទៅលើអត្ថបទឬកិច្ចការរបស់និស្សិត ការផ្ទៀងផ្ទាត់ឯករាជ្យលើស្តង់ដានៃការវាយតម្លៃកិច្ចការនិស្សិត ការពិនិត្យលើដេប៉ាតឺម៉ង់ និងកម្មវិធីអប់រំពីខាងក្រៅ ការវាយតម្លៃកម្មវិធីអប់រំដោយនិស្សិតដែលកំពុងសិក្សានិងនិស្សិតដែលបានបញ្ចប់ការសិក្សា និងរបាយការណ៍របស់និយោជកស្តីពីជំនាញរបស់និស្សិតដែលបានបញ្ចប់ការសិក្សា។

ការផ្ទៀងផ្ទាត់ស្តង់ដា ភាគច្រើនអាចធ្វើឡើងដោយការរៀបចំពិសេសជាមួយគ្រឹះស្ថានជាដៃគូឬក្នុងករណីដំណើរការផ្ទៀងផ្ទាត់ស្តង់ដាធ្វើឡើងត្រឹមកម្រិតមហាវិទ្យាល័យនិងវិទ្យាស្ថាន គ្រឹះស្ថានសិក្សាអាចប្រើប្រព័ន្ធធានាគុណភាពផ្ទៃក្នុងដែលមានស្រាប់ ប៉ុន្តែត្រូវផ្អែកលើការរៀបចំលម្អិតនិងប្រសិទ្ធភាពនៃការអនុវត្តដំណើរការ។ ការរៀបចំជាមួយគ្រឹះស្ថានដៃគូឬប្រព័ន្ធមហាវិទ្យាល័យ ដើម្បីផ្ទៀងផ្ទាត់ស្តង់ដាមិនប៉ះពាល់ដល់ការទទួលខុសត្រូវរបស់គ្រឹះស្ថានមូលដ្ឋានដែលកំពុងបង្រៀនកម្មវិធីអប់រំឡើយ។

ការពិនិត្យគុណភាពអប់រំពីខាងក្រៅលើគ្រឹះស្ថានសិក្សានិងការទទួលស្គាល់គុណភាពអប់រំលើកម្មវិធីអប់រំនឹងផ្តល់នូវការយកចិត្តទុកដាក់ពិសេសទៅលើភាពគ្រប់គ្រាន់នៃយន្តការសម្រាប់ការផ្ទៀងផ្ទាត់ស្តង់ដា។ បើយន្តការទាំងនោះមិនមានលក្ខណៈគ្រប់គ្រាន់ នោះការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឬលើកម្មវិធីអប់រំនឹងមិនត្រូវបានផ្តល់ជូនឡើយ។

៥.១០ ការផ្ទៀងផ្ទាត់សង្គតិភាពជាមួយក្របខ័ណ្ឌគុណវុឌ្ឍិ

តម្រូវការមួយសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើកម្មវិធីអប់រំ គឺការមានសង្គតិភាពជាមួយក្របខ័ណ្ឌគុណវុឌ្ឍិ។ តម្រូវការពិសេស រួមមាន៖

- ការប្រើឈ្មោះគុណវុឌ្ឍិ កម្រិតគុណវុឌ្ឍិ និងជំនាញសិក្សាឬឯកទេស
- ចំនួនក្រេឌីតអប្បបរមាដែលតម្រូវសម្រាប់គុណវុឌ្ឍិនីមួយៗ
- លទ្ធផលសិក្សានៅក្នុងវិស័យជាក់លាក់ផ្សេងគ្នានៃការសិក្សា
- ស្តង់ដាដែលតម្រូវឲ្យសម្រេចបាននៅក្នុងវិស័យនៃកម្រិតគុណវុឌ្ឍិនីមួយៗ។

ការសម្គាល់ខាងក្រោមរៀបរាប់ពីអ្វីដែលត្រូវធ្វើ ដើម្បីបំពេញបាននូវតម្រូវការនៃការទទួលស្គាល់គុណភាពអប់រំ។

*តម្រូវការ១៖ ឈ្មោះគុណវុឌ្ឍិត្រូវគោរពតាមក្របខ័ណ្ឌ*

ការផ្តល់ឈ្មោះគុណវុឌ្ឍិត្រូវធ្វើឡើងឲ្យត្រឹមត្រូវស្របតាមកម្រិតគុណវុឌ្ឍិ។ ឧទាហរណ៍ កម្មវិធីអប់រំនៅក្នុងការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្រិត៤ឬកម្រិត៥ ត្រូវតែបញ្ចូលពាក្យបច្ចេកទេសឬបច្ចេកវិទ្យា ហើយឈ្មោះជំនាញត្រូវតែរៀបរាប់ឲ្យបានត្រឹមត្រូវតាមវិស័យដែលបានសិក្សា។

*តម្រូវការ២៖ ចំនួនក្រេឌីតដែលតម្រូវសម្រាប់គុណវុឌ្ឍិត្រូវតែគោរពតាមការបញ្ជាក់នៅក្នុងក្របខ័ណ្ឌ*

- ចំនួនក្រេឌីតនៅក្នុងកម្មវិធីអប់រំត្រូវតែជាការបូកបន្ថែមទៅលើការសិក្សាមូលដ្ឋានឬថ្នាក់ត្រៀម
- ចំនួនក្រេឌីតអតិបរមា២១ក្រេឌីតក្នុងរយៈពេលមួយឆមាសនៃការសិក្សាពេញម៉ោង។

រូបមន្តក្រេឌីត អាស្រ័យទៅតាមប្រព័ន្ធចំនួន នៅក្នុងការសិក្សាពេញម៉ោងរបស់និស្សិត គឺពី១២ទៅ២១ក្រេឌីតក្នុងមួយឆមាសនិងចំនួនក្រេឌីតអប្បបរមា១២០ក្រេឌីតក្នុងកម្រិតគុណវុឌ្ឍិសិក្សារយៈពេល៤ឆ្នាំ។

រូបមន្តក្រេឌីតត្រូវបានប្រើជាមុខងារសម្រាប់វាយតម្លៃចំនួននៃការសិក្សាដែលសម្រេចបាន។ ប្រសិនបើកម្មវិធីអប់រំមានចំនួនម៉ោងសិក្សាច្រើនអាចធ្វើឲ្យចំនួនក្រេឌីតខ្ពស់ តែមិនប្រាកដជាភស្តុតាងបង្ហាញថាលទ្ធផលការសិក្សាដែលបានរំពឹងទុកអាចទទួលបានទាំងស្រុងនោះទេ។

*តម្រូវការ៣៖ គោលបំណងកម្មវិធីអប់រំគួរអភិវឌ្ឍលទ្ធផលសិក្សាទៅតាមវិស័យសិក្សា*

- គោលបំណងសិក្សាជាក់លាក់ សម្រាប់កម្មវិធីអប់រំនិងបណ្តុះបណ្តាលគួរមានបញ្ចូលលទ្ធផលសិក្សាទៅក្នុងគ្រប់វិស័យ
- កិច្ចការដើម្បីសម្រេចបានលទ្ធផលសិក្សាទាំងនោះ គួរបែងចែកឲ្យបានត្រឹមត្រូវតាមមុខវិជ្ជានៅក្នុងកម្មវិធីអប់រំនិងគួរបញ្ចូលទៅក្នុងគោលបំណងនៃមុខវិជ្ជាសិក្សានីមួយៗ
- ភាពជាក់លាក់នៃកម្មវិធីអប់រំនិងមុខវិជ្ជាសិក្សា គួរបញ្ចូលវិធីសាស្ត្រនៃការបង្រៀននិងសកម្មភាពនិស្សិតច្បាស់លាស់សម្រាប់លទ្ធផលសិក្សានៅក្នុងវិស័យនីមួយៗ
- តេស្ត ការប្រឡង និងកិច្ចការវាយតម្លៃសមត្ថភាពដែលតម្រូវផ្សេងទៀត ត្រូវបញ្ចូលតម្រូវការនៃការវាយតម្លៃការសិក្សាឲ្យបានត្រឹមត្រូវទៅតាមវិស័យនីមួយៗ

- ការវាយតម្លៃកម្មវិធីអប់រំគប់បញ្ចូលទាំងនិស្សិត និស្សិតដែលបានបញ្ចប់ការសិក្សា ឬនិយោជក និង/ឬយន្តការដទៃទៀត គួរផ្តោតការយកចិត្តទុកដាក់ទៅលើលទ្ធផលសិក្សានៅក្នុងវិស័យនីមួយៗ។

*តម្រូវការ៤៖ ការវាយតម្លៃស្តង់ដាដែលសម្រេចបាន*

ស្តង់ដាដែលសម្រេចបាននៅក្នុងវិស័យនីមួយៗ ត្រូវតែមានសង្គតិភាពជាមួយនឹងការពិពណ៌នាពីលក្ខណសម្បត្តិនៃនិស្សិត ដែលបញ្ចប់ការសិក្សានិងការពិពណ៌នាពីលទ្ធផលសិក្សាសម្រាប់កម្រិតគុណវុឌ្ឍិនីមួយៗ។

លទ្ធផលសិក្សាមួយចំនួនអាចវាយតម្លៃបាននៅក្នុងតេស្តនិងការប្រឡងឬកិច្ចការវាយតម្លៃដទៃទៀតនៅក្នុងកម្មវិធីអប់រំ។ ទោះជាយ៉ាងនេះក្តី លទ្ធផលសិក្សាផ្សេងទៀតដែលទាក់ទងទៅនឹងលក្ខណសម្បត្តិរបស់និស្សិតបញ្ចប់ការសិក្សាឬការបញ្ជាក់វាក្យសព្ទទូទៅនៅក្នុងស្តង់ដាចាំបាច់ត្រូវការកម្រិតវិនិច្ឆ័យពីស្តង់ដាដែលសម្រេចបាននោះ។ ដូច្នេះហើយ ភស្តុតាងជាច្រើននៃការវាយតម្លៃទៅលើសង្គតិភាពរបស់ស្តង់ដាដែលសម្រេចបាន គឺផ្អែកលើវិធានប្រយោលនិងការវិនិច្ឆ័យវិជ្ជាជីវៈ។ ដើម្បីបំពេញតម្រូវការសម្រាប់ការទទួលស្គាល់គុណភាពអប់រំ ប្រភពនៃភស្តុតាងខាងក្រោមគួរបញ្ចូលទៅក្នុងការវាយតម្លៃកម្មវិធីអប់រំនិងបណ្តុះបណ្តាល៖

- ការវាយតម្លៃកម្មវិធីអប់រំនិងបណ្តុះបណ្តាលនិងស្វ័យវាយតម្លៃរបស់និស្សិតដែលបញ្ចប់ការសិក្សាពីកម្មវិធីអប់រំនិងបណ្តុះបណ្តាល
- ការផ្តល់យោបល់ឯករាជ្យដោយសហសេវិកវិជ្ជាជីវៈមកពីគ្រឹះស្ថានដទៃឬដោយអ្នកវាយតម្លៃដែលមានការតម្រង់ទិសទៅលើកម្រិតសិក្សាពិបាកនៅក្នុងតេស្ត កិច្ចការស្រាវជ្រាវ និងស្តង់ដាដែលសម្រេចបានដោយនិស្សិត
- ការស្ទាបស្ទង់មតិពីនិយោជករបស់និស្សិតដែលបានបញ្ចប់ការសិក្សាឬសមាគមវិជ្ជាជីវៈជាន់ខ្ពស់នៃអ្នកដែលបានបញ្ចប់ការសិក្សា។

# ឧបសម្ព័ន្ធ

## ១. តារាងពិពណ៌នាសមត្ថភាពទូទៅសង្ខេបសម្រាប់គុណវុឌ្ឍិនីមួយៗ

### ការពិពណ៌នាពីសមត្ថភាពទូទៅក្នុងកម្រិតគុណវុឌ្ឍិនីមួយៗនៃ ក.គ.វ.ក

| គុណវុឌ្ឍិនៃ ក.គ.វ.ក | វិញ្ញាបនបត្រវិជ្ជាជីវៈ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ |
|---|---|---|
| កម្រិត | កម្រិត១ | កម្រិត២ |
| គោលបំណង | វិញ្ញាបនបត្រវិជ្ជាជីវៈ គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលមានចំណេះដឹងនិងជំនាញកម្រិតមូលដ្ឋានសម្រាប់ប្រតិបត្តិការងារនិងបន្តការសិក្សាបន្ថែមទៀត។ | សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលសម្រាប់អនុវត្តសកម្មភាពការងារផ្សេងៗតាមការប្រមើលទុកនិងធម្មតាៗនិងទុកជាច្រកសម្រាប់បន្តការសិក្សាបន្ថែមទៀត។ |
| ចំណេះដឹង | • មានចំណេះដឹងដែលទាក់ទងទៅនឹងបរិបទការងារមុខរបរដូចជាការអនុវត្តនីតិវិធី បទប្បញ្ញត្តិ និងគោលគំនិតកម្រិតមូលដ្ឋាន។ | • មានចំណេះដឹងកម្រិតមូលដ្ឋានទាក់ទងនឹងកិច្ចការអាជីពដែលកំណត់ក្នុងបរិបទការងាររួមមានការអនុវត្តនីតិវិធី បទប្បញ្ញត្តិមូលដ្ឋាន និងគោលគំនិតខ្លះៗដែលទទួលបានពីការណែនាំនិងការសិក្សា។ |
| ជំនាញក្នុងគិត | • ប្រើចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាលនិងបទពិសោធការងារតាមលំដាប់លំដោយ<br>• ចំណេះដឹងទាំងនេះទាក់ទងទៅនឹងសេរីភាពក្នុងការសម្រេចចិត្តរបស់សិស្ស ប៉ុន្តែត្រូវមានសមត្ថភាពអនុវត្តតាមការណែនាំផ្ទាល់របស់អ្នកគ្រប់គ្រង។ | • ប្រើចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាលនិងបទពិសោធការងារក្នុងកិច្ចការដែលមានចេនាសម្ព័ន្ធនិងលំដាប់លំដោយ<br>• ចំណេះដឹងទាំងនេះទាក់ទងទៅនឹងសេរីភាពក្នុងការសម្រេចចិត្តរបស់បេក្ខជន ប៉ុន្តែត្រូវមានសមត្ថភាពឆ្លើយតបតាមការណែនាំផ្ទាល់របស់អ្នកគ្រប់គ្រង។ |
| ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ | • បំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវស្របតាមការណែនាំឬស្របតាមស្តង់ដានីតិវិធីក្នុងបរិបទការងារដែលបានកំណត់<br>• មានការទទួលខុសត្រូវចំពោះបរិមាណនិងគុណភាពនៃទិន្នផលរបស់ខ្លួនមួយចំនួន ប៉ុន្តែមិនមែនជាការទទួលខុសត្រូវលើទិន្នផលរបស់អ្នកដទៃឡើយ។ | • បំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវក្រោមការណែនាំឬស្របតាមស្តង់ដានីតិវិធីក្នុងបរិបទការងារដែលបានកំណត់<br>• មានការទទួលខុសត្រូវចំពោះបរិមាណនិងគុណភាពនៃលទ្ធផលរបស់ខ្លួន ប៉ុន្តែមិនមែនជាការទទួលខុសត្រូវលើលទ្ធផលរបស់អ្នកដទៃឡើយ។ |
| ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង | • យល់និងឆ្លើយតបទៅនឹងការណែនាំដែលទាក់ទងនឹងកិច្ចការអាជីព | • យល់និងឆ្លើយតបទៅនឹងការណែនាំស្តីពីកិច្ចការមុខរបរ |

| | | |
|---|---|---|
| | • ធ្វើការទាក់ទងតាមរយៈផ្ទាល់មាត់និងសំណេរធម្មតាក្នុងកម្រិតមូលដ្ឋានដូចជាការសរសេររបាយការណ៍លើការងារនិងកិច្ចការដែលខ្លួនបានបំពេញដែលជាទម្រង់របាយការណ៍ងាយៗ។ | • ទាក់ទងតាមរយៈផ្ទាល់មាត់និងសំណេរធម្មតាដែលរួមមានការសរសេររបាយការណ៍ធម្មតាលើកិច្ចការដែលបេក្ខជនបានបំពេញដូចជាការបំពេញទម្រង់របាយការណ៍ធម្មតា។ |
| **ជំនាញចិត្តចលនា** | • មានជំនាញមូលដ្ឋានក្នុងការប្រើប្រាស់ឧបករណ៍ស្តង់ដាក្នុងកិច្ចការអាជីព ហើយអាចប្រើជំនាញទាំងនោះក្នុងការអនុវត្តនីតិវិធីតាមស្តង់ដា។ | • មានជំនាញខ្ពស់ជាងកម្រិត១ ក្នុងការប្រើប្រាស់ឧបករណ៍ស្តង់ដាក្នុងកិច្ចការអាជីព ហើយអាចប្រើជំនាញទាំងនោះក្នុងការអនុវត្តនីតិវិធីតាមស្តង់ដាសមស្រប។ |
| **ការអនុវត្ត** | • អនុវត្តនីតិវិធី បទប្បញ្ញត្តិ និងប្រើជំនាញរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ<br>• សមត្ថភាពក្នុងការអនុវត្តនីតិវិធីងាយៗ<br>• ចូលរួមសហការនិងបំពេញសកម្មភាពការងារដែលកំណត់នៅក្នុងសកម្មភាពមុខងារវិជ្ជាជីវៈ<br>• ទទួលនិងអនុវត្តតាមការណែនាំរបស់អ្នកគ្រប់គ្រងជាប្រចាំ | • ប្រើចំណេះដឹងតាមនីតិវិធីនិងបទប្បញ្ញត្តិព្រមទាំងជំនាញហត្ថកម្មប្រកបដោយលក្ខណៈទទួលខុសត្រូវជាក់លាក់<br>• ចូលរួមសហការនិងបំពេញសកម្មភាពការងារដែលកំណត់ក្នុងកិច្ចការមុខរបរ<br>• ទទួលនិងអនុវត្តតាមការណែនាំរបស់អ្នកគ្រប់គ្រងក្នុងករណីចាំបាច់<br>• សមត្ថភាពអនុវត្តកិច្ចការប្រចាំថ្ងៃតាមនីតិវិធីស្តង់ដាឬក្រោមការណែនាំផ្ទាល់<br>• ប្រតិបត្តិកិច្ចការទៅតាមលំដាប់លំដោយនៃការងារទៅតាមទិសដៅដែលបានកំណត់<br>• សមត្ថភាពអនុវត្តកិច្ចការប្រកបដោយចរិតទទួលខុសត្រូវ<br>• ចេះទទួលនិងនាំសារឬព័ត៌មាន |
| **ចំណុះនៃការសិក្សា** | សិក្សារយៈពេលពី៤-៦ខែបូករួមទាំងវគ្គស្ពានចម្លងនិងសន្សំឯកតាសមត្ថភាព | សិក្សារយៈពេល១ឆ្នាំ |



## ការពិពណ៌នាពីសមត្ថភាពនៅក្នុងកម្រិតគុណវុឌ្ឍិនីមួយៗនៃ ក.គ.ជ.ក

| គុណវុឌ្ឍិនៃ ក.គ.ជ.ក | សញ្ញាបត្រប្រច្ចេកទេសនិងវិជ្ជាជីវៈ២ | សញ្ញាបត្រប្រច្ចេកទេសនិងវិជ្ជាជីវៈ៣ |
|---|---|---|
| កម្រិត | កម្រិត៣ | កម្រិត៤ |
| គោលបំណង | សញ្ញាបត្រប្រច្ចេកទេសនិងវិជ្ជាជីវៈ២ គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តនូវចំណេះដឹងនិងជំនាញក្នុងបរិបទទូលំទូលាយ និងជាក់លាក់ដើម្បីប្រតិបត្តិការងារជំនាញផ្សេងៗ ដោយមានជម្រើសច្បាស់លាស់និងទុកជាច្រក សម្រាប់ការសិក្សាបន្ថែមទៀត។ | សញ្ញាបត្រប្រច្ចេកទេសនិងវិជ្ជាជីវៈ៣ គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តនូវចំណេះដឹងនិងជំនាញជាឯកទេសក្នុងបរិបទទូលំទូលាយដើម្បីប្រតិបត្តិការងារជំនាញផ្សេងៗនិងទុកជាច្រកសម្រាប់ការសិក្សាបន្ថែមទៀត។ |
| ចំណេះដឹង | • មានចំណេះដឹងលើកិច្ចការមុខរបរការអនុវត្តស្តង់ដានិងនីតិវិធីរួមមានការយល់ដឹងមូលដ្ឋាននៃទ្រឹស្តីសំខាន់ៗ។ | • មានចំណេះដឹងទូលំទូលាយលើកិច្ចការមុខរបរនិងដំណើរការនិងអាចប្រើចំណេះដឹងអនុវត្តការងារប្រចាំថ្ងៃនិងការងារថ្មីដែលមិនធ្លាប់ជួបប្រទះ<br>• ចំណេះដឹងនេះមានដូចជាគោលគំនិតមូលដ្ឋាននិងទ្រឹស្តីក្នុងការអនុវត្តការងារទាំងអស់នេះ។ |
| ជំនាញក្នុងការគិត | • យល់ពីបញ្ហានិងបរិបទក្នុងការរកដំណោះស្រាយបញ្ហា<br>• ជំនាញនេះទាក់ទិននឹងការយល់និងសមត្ថភាពក្នុងការពិចារណាដើម្បីរកនីតិវិធីដែលឆ្លើយតបទៅនឹងកិច្ចការឬបញ្ហា ប៉ុន្តែមិនចាំបាច់អភិវឌ្ឍគំនិតឬដំណោះស្រាយថ្មីឡើយ។ | • រកដំណោះស្រាយចំពោះបញ្ហាផ្សេងៗក្នុងស្ថានភាពដែលធ្លាប់ជួបប្រទះនិងមិនដែលជួបប្រទះ<br>• អាចសំយោគជំនាញ បច្ចេកទេស សម្ភារនិងឧបករណ៍ដើម្បីអនុវត្តកិច្ចការជួបប្រទះរាល់ថ្ងៃនិងមិនដែលជួបប្រទះមួយចំនួន<br>• មានការយល់ដឹងពីគំនិត គោលការណ៍និងទ្រឹស្តីទូទៅលើមុខវិជ្ជាដែលសិក្សានិងមានសមត្ថភាពអនុវត្តការយល់ដឹងទាំងនោះក្នុងការវិភាគស្ថានភាពនិងបញ្ហាថ្មីៗដែលមានក្នុងការសិក្សានិងក្នុងជីវភាពប្រចាំថ្ងៃ<br>• មានការយល់ដឹងពីបញ្ហាទាក់ទងនឹងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចនិងមានលទ្ធភាពអាចអនុវត្តចំណេះដឹងដែលទទួលបានពីការសិក្សាក្នុងការវិភាគបញ្ហាទាំងនោះ។ |
| ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ | • បំពេញកិច្ចការប្រកបដោយការទទួលខុសត្រូវក្រោមការណែនាំបន្តិចបន្តួចនិងទទួលខុសត្រូវខ្លួនឯងចំពោះទិន្នផល | • ទទួលខុសត្រូវចំពោះភារកិច្ចក្នុងកន្លែងការងារ ដឹកនាំខ្លួនឯងក្នុងការអនុវត្តការងារប្រកបដោយការយកចិត្តទុកដាក់និងគ្រប់ |

| | | |
|---|---|---|
| | • ធ្វើការសហការជាមួយអ្នកដទៃនិងចែករំលែកការទទួលខុសត្រូវចំពោះការជឿទុកចិត្ត គុណភាព និងបរិមាណនៃទិន្នផល។ | តាមការកំណត់ក្នុងភារកិច្ច<br>• ទទួលខុសត្រូវចំពោះគុណភាពនិងបរិមាណការងាររបស់ខ្លួន ផ្តល់ភាពជាអ្នកដឹកនាំនិងការសម្រេចចិត្ត និងទទួលខុសត្រូវចំពោះលទ្ធផលរបស់អ្នកដទៃ<br>• មានការទទួលខុសត្រូវនិងផ្តើមគំនិតដើម្បីបង្កើនជំនាញមុខរបររបស់ខ្លួន<br>• បំពេញកិច្ចការប្រកបដោយប្រសិទ្ធភាពសំដៅសម្រេចគោលដៅទូទៅក្នុងស្ថានភាពការងារជាក្រុម<br>• ជឿទុកចិត្តបានថាអាចបំពេញកិច្ចការផ្សេងៗដែលដាក់ឲ្យធ្វើដោយមានការត្រួតពិនិត្យនិងណែនាំតិចតួច<br>• មានការទទួលខុសត្រូវលើអត្តចរិតនិងការសិក្សារបស់ខ្លួនហើយអាចមានលទ្ធភាពចូលរួមធ្វើកិច្ចការនិងផ្តួចផ្តើមគំនិតតាមរយៈការណែនាំក្នុងការសិក្សានិងទម្រង់ឬកពាផ្សេងៗក្នុងការអភិវឌ្ឍខ្លួន។ |
| ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង | • បកស្រាយ ពន្យល់ និងផ្ទេរព័ត៌មាន ដែលទាក់ទងទៅនឹងកិច្ចការមុខរបរដូចជាសេចក្តីណែនាំដើម្បីកែប្រែនីតិវិធីស្របតាមស្តង់ដា<br>• ផ្សព្វផ្សាយព័ត៌មានដែលទាក់ទងទៅនឹងកិច្ចការច្បាស់លាស់<br>• វិភាគទិន្នន័យដោយប្រើគណិតវិទ្យានិងស្ថិតិសាមញ្ញៗ ព្រមទាំងអាចបកស្រាយទិន្នន័យ។ | • ស្វែងយល់បកស្រាយព័ត៌មានពាក់ព័ន្ធនិងប្រើព័ត៌មាននេះក្នុងដំណើរការងារ ដើម្បីបង្កើនប្រសិទ្ធផលនិងសុវត្ថិភាព។ ព័ត៌មាននេះមានដូចជា ក្រាភិច លេខ និងសំណេរ<br>• ប្រមូលព័ត៌មាននិងធ្វើបទបង្ហាញយ៉ាងច្បាស់លាស់តាមរយៈ ក្រាភិច សំណេរ និងផ្ទាល់មាត់<br>• ប្រើវិធីស្ថិតិនិងលេខក្នុងការរៀបចំវាយតម្លៃនិងរបាយការណ៍លើសកម្មភាពការងារព្រមទាំងរិះរកដំណើរការថ្មីដែលស្របទៅនឹងស្ថានភាពការងារ<br>• ប្រើព័ត៌មានមូលដ្ឋានបច្ចេកវិទ្យាកុំព្យូទ័រ និងជំនាញលេខនព្វន្តក្នុងការដោះស្រាយបញ្ហានានាក្នុងបរិបទអប់រំនិងជីវភាពប្រចាំថ្ងៃប្រកបដោយប្រសិទ្ធភាព<br>• អាចប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពទាំងតាមរយៈការនិយាយផ្ទាល់មាត់ ការសរសេរ និងតាមរយៈការប្រើបច្ចេកវិទ្យាព័ត៌មាន។ |
| ជំនាញចិត្តចលនា | • ប្រើប្រាស់ឧបករណ៍ស្តង់ដាសម្ភារនិងនីតិវិធី | • បញ្ជាដំណើរការឧបករណ៍ដែលមានលក្ខណៈ |

៦០៤

| | | |
|---|---|---|
| | ប្រកបដោយសុវត្ថិភាព<br>• ប្រើប្រាស់ឧបករណ៍តាមវិធីដែលបានមកពីការបណ្តុះបណ្តាលនិងបទពិសោធការងារ។ | បច្ចេកទេសស្មុគស្មាញនិងប្រតិបត្តិកិច្ចការជួបប្រទះប្រចាំថ្ងៃនិងមិនដែលជួបប្រទះមួយចំនួន<br>• ជំនាញនេះមានដូចជាសមត្ថភាពក្នុងការជ្រើសរើស ប្រើប្រាស់ និងតម្រូវឧបករណ៍ បរិក្ខារ និងសម្ភាររួមទាំងដំណើរការស្រប តាមកិច្ចការផ្សេងៗគ្នា។ |
| ការអនុវត្ត | • អនុវត្តចំណេះដឹងនិងជំនាញប្រកបដោយការទទួលខុសត្រូវជាក់លាក់តាមរយៈនីតិវិធីស្របតាមស្តង់ដាក្នុងការដោះស្រាយបញ្ហាដែលអាចដឹងមុន<br>• បង្ហាញពីការអភិវឌ្ឍនៃការយល់ដឹងលើគោលការណ៍និងគំនិតទាក់ទងទៅនឹងកិច្ចការមុខរបរនិងធ្វើការផ្លាស់ប្តូរតាមនីតិវិធីក្នុងស្ថានភាពប្រែប្រួល<br>• ធ្វើការជាមួយអ្នកដទៃនិងទទួលខុសត្រូវចំពោះគុណភាពនិងបរិមាណការងារជាឯកត្តបុគ្គលនិងក្រុមការងារ<br>• ទទួលខុសត្រូវនិងអនុវត្តការងារប្រកប ដោយប្រសិទ្ធភាពនិងសុវត្ថិភាព<br>• សមត្ថភាពទទួលខុសត្រូវខ្លួនឯងឬជាមួយអ្នកដទៃចំពោះគុណភាពនិងបរិមាណនៃទិន្នផល<br>• រកដំណោះស្រាយបញ្ហាដែលអាចដឹងមុនមួយចំនួន<br>• ប្រតិបត្តិកិច្ចការក្នុងស្ថានភាពមួយដែលមានជម្រើសនិងមានដែនកំណត់<br>• វាយតម្លៃនិងប្រមូលព័ត៌មានពីប្រភពផ្សេងៗ<br>• ទទួលខុសត្រូវចំពោះទិន្នផលការងារនិងសិក្សារបស់ខ្លួន<br>• ការអនុវត្តដូចជាការទទួលខុសត្រូវមួយចំនួនចំពោះអ្នកដទៃ<br>• ការធ្វើការជាក្រុមឬដឹកនាំសម្របសម្រួលក្នុងក្រុម | • អនុវត្តចំណេះដឹងនិងជំនាញក្នុងការជ្រើសរើសយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហាក្នុងការងារដើម្បីបង្កើនសុវត្ថិភាពទិន្នផលនិងគុណភាព<br>• អនុវត្តជំនាញយ៉ាងទូលំទូលាយទាក់ទងនឹងសកម្មភាពដូចជាការងារប្រចាំថ្ងៃវិធីសាស្ត្រនិងនីតិវិធីដែលតម្រូវឲ្យមានការជ្រើសរើសឧបករណ៍ សេវាកម្ម ឬវិធានការក្នុងពេលវេលាមួយកំណត់<br>• ស្វ័យអភិវឌ្ឍសមត្ថភាពក្នុងការដឹកនាំខ្លួនឯងឲ្យឆ្លើយតបទៅនឹងកិច្ចការខុសៗគ្នាប្រកបដោយការទទួលខុសត្រូវខ្លួនឯងយ៉ាងពេញលេញនិងទទួលខុសត្រូវចំពោះទិន្នផលរបស់អ្នកដទៃ<br>• សមត្ថភាពធ្វើការជាក្រុម រួមចំណែកទទួលខុសត្រូវចំពោះគុណភាពនិងបរិមាណនៃទិន្នផលរបស់ក្រុម និងជួយគាំទ្រដើម្បីបង្កើនប្រសិទ្ធភាព<br>• មានសមត្ថភាពរកដំណោះស្រាយបញ្ហានិងការទទួលខុសត្រូវចំពោះអ្នកដទៃ<br>• អនុវត្តនីតិវិធីដោយប្រើជំនាញដែលបានអភិវឌ្ឍនិងតាមសមត្ថភាពផ្ទាល់ខ្លួន<br>• បកស្រាយព័ត៌មានដោយប្រើសមត្ថភាពផ្ទាល់ខ្លួន |
| ចំណុះនៃការសិក្សា | សិក្សារយៈពេល១ឆ្នាំ | សិក្សារយៈពេល១ឆ្នាំ |

## ការពិពណ៌នាពីសមត្ថភាពនៅក្នុងកម្រិតគុណវុឌ្ឍិនីមួយៗនៃ ក.គ.ជ.ក

| គុណវុឌ្ឍិនៃ ក.គ.ជ.ក | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស បរិញ្ញាបត្ររង | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស បរិញ្ញាបត្រ |
|---|---|---|
| | កម្រិត៥ | កម្រិត៦ |
| គោលបំណង | សញ្ញាបត្រជាន់ខ្ពស់ /បរិញ្ញាបត្ររង បច្ចេកទេស /ឯកទេស គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តដោយ រួមបញ្ចូលទាំងបច្ចេកទេស ទ្រឹស្តី និងទស្សនៈក្នុងបរិបទទូលំទូលាយដើម្បីប្រតិបត្តិការងារ ជំនាញផ្សេងៗកម្រិតខ្ពស់ឬជាជំនួយការអ្នក វិជ្ជាជីវៈអាជីពនិងទុកជាច្រកសម្រាប់ការសិក្សា បន្ថែមទៀត<br><br>ចំពោះបរិញ្ញាបត្ររង គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តនូវបច្ចេកទេសបន្ថែម និងចំណេះដឹងជាទ្រឹស្តីក្នុងបរិបទទូលំទូលាយ ដើម្បីប្រតិបត្តិការងារជំនាញជាជំនួយការអ្នក វិជ្ជាជីវៈអាជីពនិងទុកជាច្រកសម្រាប់បន្តការសិក្សាបន្ថែមទៀត។ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តនូវបណ្តុំនៃចំណេះដឹងក្នុងបរិបទទូលំទូលាយ ដើម្បីប្រតិបត្តិវិជ្ជាជីវៈ/ការងារជំនាញកម្រិតខ្ពស់ និងទុកជាច្រកសម្រាប់បន្តការសិក្សាបន្ថែមទៀត<br><br>ចំពោះបរិញ្ញាបត្រ គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តនូវបណ្តុំនៃចំណេះដឹងជាទ្រឹស្តីក្នុងបរិបទទូទៅ ដើម្បីប្រតិបត្តិជំនាញវិជ្ជាជីវៈនិងទុកជាច្រកសម្រាប់បន្តការសិក្សាបន្ថែមទៀត។ |
| ចំណេះដឹង | • មានចំណេះដឹងទូលំទូលាយក្នុងលក្ខខណ្ឌបច្ចេកទេសនិងដំណើរការឧស្សាហកម្មមានដូចជាចំណេះដឹងអាចប្រែប្រួលទៅតាមបច្ចេកវិទ្យាថ្មីៗ<br>• យល់ដឹងច្បាស់លាស់ពីនីតិវិធីនិងយល់ដឹងពីគោលការណ៍និងទ្រឹស្តីពាក់ព័ន្ធនឹងឧស្សាហកម្ម<br>• យល់ដឹងទូទៅលើវិស័យដែលខ្លួនសិក្សាហើយមានចំណេះដឹងច្បាស់លាស់និងស៊ីជម្រៅលើចំណុចសំខាន់ៗមួយចំនួនដោយរាប់ទាំងទ្រឹស្តី គំនិត និងគោលការណ៍សំខាន់ៗ<br>• យល់ដឹងពីសារៈសំខាន់នៃការសិក្សាស្រាវជ្រាវ និងបញ្ហាដែលកើតមានឡើងនាពេលថ្មីៗ។ | • មានចំណេះដឹងស៊ីជម្រៅផ្នែកឧស្សាហកម្ម និងជំនាញមុខរបរគួបផ្សំដោយចំណេះដឹងទូទៅ ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ស្រូបយកចំណេះដឹងថ្មី។ ចំណេះដឹងនេះ រួមមានចំណេះដឹងផ្នែកទ្រឹស្តីដែលពាក់ព័ន្ធបច្ចេក-ទេសថ្មី<br>• មានចំណេះស៊ីជម្រៅផ្នែកទ្រឹស្តីនិងដំណើរការទាក់ទងនឹងការរៀននិងការបង្រៀន<br>• មានចំណេះដឹងទូលំទូលាយជាប្រព័ន្ធនិងប្រទាក់ក្រឡាក្នុងវិស័យដែលខ្លួនសិក្សា ព្រមទាំងទ្រឹស្តីនិងគោលការណ៍សំខាន់ៗដែលពាក់ព័ន្ធ<br>• យល់ដឹងពីចំណេះដឹងនិងទ្រឹស្តីដែលទាក់ទងនឹងការអប់រំផ្សេងៗឬវិស័យវិជ្ជាជីវៈផ្សេងៗចំពោះកម្មវិធីអប់រំវិជ្ជាជីវៈ<br>• យល់ដឹងពីការអភិវឌ្ឍចុងក្រោយសំខាន់ៗនៃជំនាញឯកទេសក្នុងវិស័យដែលខ្លួន |

| | | |
|---|---|---|
| | | សិក្សាដោយរួមបញ្ចូលចំណេះដឹងវិភាគនៃការស្រាវជ្រាវនាពេលបច្ចុប្បន្នទាក់ទងនឹងដំណោះស្រាយបញ្ហាទាំងឡាយដែលកើតមានឡើងនិងការពង្រីកចំណេះដឹង។ |
| ជំនាញក្នុងការគិត | • អនុវត្តចំណេះដឹងក្នុងស្ថានភាពស្មុគស្មាញ និងវិភាគព័ត៌មានពីប្រភពផ្សេងៗដើម្បីធ្វើផែនការនិងអនុវត្តដំណោះស្រាយផែនការប្រកបដោយគំនិតច្នៃប្រឌិត<br>• ផ្ទេរនិងសម្របសម្រួលចំណេះដឹងតាមបរិបទការងារ<br>• វិភាគនិងបកស្រាយព័ត៌មានបច្ចេកទេសនិងស្រាវជ្រាវ ហើយអាចប្រើប្រាស់ព័ត៌មានទាំងនោះដើម្បីដោះស្រាយបញ្ហានានាជាមួយនឹងតម្រូវការនៃការណែនាំខ្លះៗ<br>• ពិនិត្យពិច័យលើបញ្ហាសំខាន់ឬបញ្ហាដែលកើតឡើងជាប្រក្រតីដោះស្រាយបញ្ហាទាំងនោះនិងលើកជាវិធីសាស្ត្រថ្មីៗដោយប្រើចំណេះដឹងអនុវត្តនិងទ្រឹស្តីដែលពាក់ព័ន្ធ<br>• យល់ដឹងនិងញែកទស្សនៈនិងទ្រឹស្តីនៃមុខវិជ្ជាដែលសិក្សាហើយប្រើទស្សនៈនិងទ្រឹស្តីទាំងនោះនៅក្នុងបរិបទការងារនិងការសិក្សា<br>• យល់ដឹងពីចរិតលក្ខណៈចំណេះដឹងនៅក្នុងវិស័យដែលខ្លួនសិក្សាហើយអាចយកចំណេះដឹងទាំងនោះទៅវិភាគនិងដោះស្រាយបញ្ហានានា។ | • ស្រាវជ្រាវនិងវិភាគស៊ីជម្រៅបញ្ហាស្មុគស្មាញទាក់ទងនឹងការរៀននិងការបង្រៀននិងផែនការយុទ្ធសាស្ត្រសម្រាប់ការអនុវត្តក្នុងបរិបទផ្សេងៗ<br>• អង្កេត យល់ និងវាយតម្លៃនូវព័ត៌មាន គំនិតនិងភស្តុតាងថ្មីៗពីប្រភពផ្សេងៗនិងធ្វើការសន្និដ្ឋានទៅលើព្រឹត្តិការណ៍និងបញ្ហាដែលកើតមានឡើងជាមួយនឹងតម្រូវការនៃការណែនាំតិចតួច<br>• អង្កេតបញ្ហាស្មុគស្មាញទាំងឡាយ ផ្តល់យោបល់និងបង្កើតដំណោះស្រាយថ្មីៗតាមរយៈការប្រើប្រាស់នូវចំណេះដឹងនិងបទពិសោធក្នុងជំនាញរបស់ខ្លួន<br>• អាចយកជំនាញនិងចំណេះដឹងទាំងនោះទៅអនុវត្តក្នុងវិជ្ជាជីវៈនិងក្នុងការអប់រំទូទៅដែលទាក់ទងនឹងការសិក្សាក្នុងជំនាញរបស់ខ្លួន<br>• ចំពោះផ្នែកអប់រំវិជ្ជាជីវៈនិស្សិតអាចយកនីតិវិធីសមស្របទូទៅមកប្រើប្រាស់ ប៉ុន្តែត្រូវកំណត់ឲ្យបានច្បាស់លាស់ពីស្ថានភាពដែលតម្រូវមានការបង្កើតនូវដំណោះស្រាយថ្មីៗហើយការឆ្លើយតបទាំងអស់នេះត្រូវបង្កើតឡើងតាមរយៈទ្រឹស្តីនិងការអនុវត្ត។ |
| ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ | • ដឹកនាំនិងណែនាំសកម្មភាពការងារជាក្រុម<br>• ទទួលខុសត្រូវចំពោះទិន្នផលការងារខ្លួនឯងនិងអ្នកដទៃក្នុងការងារ<br>• ផ្តើមគំនិតពង្រីកចំណេះដឹងបច្ចេកទេសនិងជំនាញអ្នកដទៃទៀតព្រមទាំងអាចគាំទ្រការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកនិងអ្នករួមការងារដទៃទៀត<br>• គិតពិចារណានិងធ្វើសកម្មភាពដោយឯករាជ្យ ប៉ុន្តែក៏ចេះធ្វើអន្តរកម្មក្នុងក្រុមឬការងារជាក្រុម | • វិភាគនិងសម្របសម្រួលដោះស្រាយបញ្ហាជាក្រុមក្នុងនាមជាអ្នកដឹកនាំឬសមាជិកនៃក្រុម<br>• ដឹកនាំក្រុមក្នុងស្ថានភាពមិនជាក់លាក់តម្រូវឲ្យមានដំណោះស្រាយដោយប្រើគំនិតថ្មី<br>• ផ្តើមគំនិតក្នុងការរាវរកបញ្ហាដែលតម្រូវឲ្យដោះស្រាយជាបុគ្គលឬជាក្រុម<br>• ទទួលខុសត្រូវចំពោះការសិក្សាផ្ទាល់ខ្លួន និងចេះរាវរក [illegible] |

| | | |
|---|---|---|
| | ប្រកបដោយន័យស្ថាបនា ដើម្បីសម្រេចបានគោលដៅរួមគ្នា<br>• ប្រើភាពជាអ្នកដឹកនាំក្នុងក្រុមការងារតូចៗដែលខ្លួនទទួលខុសត្រូវ<br>• កំណត់ពីចំណុចខ្សោយនៃចំណេះដឹងនិងជំនាញរបស់ខ្លួន ហើយធ្វើផែនការអនុវត្តន៍ដើម្បីសិក្សាស្វែងយល់បន្តទៀត<br>• មានការទទួលខុសត្រូវលើសកម្មភាពផ្ទាល់ខ្លួននិងសកម្មភាពជាក្រុម<br>• យល់ដឹងនិងគោរពយ៉ាងម៉ឺងម៉ាត់នូវបទប្បញ្ញត្តិនិងក្រមសីលធម៌ ហើយចេះស្វែងរកការប្រឹក្សាផ្តល់យោបល់តាមការចាំបាច់<br>• យល់ដឹងពីផលប៉ះពាល់លើសកម្មភាពរបស់អ្នកដទៃ ហើយចេះប្រមាណពីភាពសមស្របនៃសកម្មភាពទាំងនោះដោយគិតពីវិបាកដែលអាចកើតមាន<br>• ក្នុងស្ថានភាពដែលមានការខ្វែងគំនិតគ្នាលើតម្លៃឬសារៈសំខាន់នៃអ្វីមួយអាចលើកយកបញ្ហានៃការខ្វែងគំនិតគ្នានេះមកលាតត្រដាងនិងធ្វើការកាត់ក្តីតាមហេតុផលជាក់ស្តែង។ | ស្រាវជ្រាវរកព័ត៌មានថ្មីឬរបៀបក្នុងការវិភាគទិន្នន័យនៃកិច្ចការ<br>• ដោះស្រាយបញ្ហាវិជ្ជាជីវៈនិងក្រមសីលធម៌ទាក់ទងនឹងតម្លៃនិងក្រមវិជ្ជាជីវៈ<br>• រួមចំណែកជាមួយក្រុមការងាររបស់ខ្លួននិងស្វែងរកដំណោះស្រាយលើបញ្ហាទាំងឡាយដែលកើតមានទោះក្នុងមុខនាទីជាថ្នាក់ដឹកនាំក្តីឬជាសមាជិកក្រុមក្តី<br>• អនុវត្តការងារក្នុងភាពជាអ្នកដឹកនាំនៅក្នុងស្ថានភាពពុំជាក់លាក់ដែលតម្រូវឲ្យមានដំណោះស្រាយថ្មី<br>• ទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន ហើយមានលទ្ធភាពស្វែងរកនិងប្រើមធ្យោបាយស្វែងរកព័ត៌មានថ្មីៗឬបច្ចេកទេសក្នុងការវិភាគដើម្បីបំពេញតម្រូវការក្នុងការសិក្សារបស់ខ្លួន<br>• មានលទ្ធភាពស្វ័យសិក្សាដោយខ្លួនឯងដើម្បីបន្តការសិក្សាទៅកម្រិតខាងមុខ<br>• អនុវត្តជំនាញការងារជាក្រុមនិងទំនាក់ទំនងអន្តរបុគ្គលដែលសមស្របទៅនឹងការងាររបស់ខ្លួន<br>• ដោះស្រាយបញ្ហាអភិសមាចារនិងវិជ្ជាជីវៈទាក់ទងនឹងការវិនិច្ឆ័យលើគុណតម្លៃនិងសីលធម៌ដែលងាយប៉ះពាល់ដល់អ្នកដទៃស្របតាមគុណតម្លៃជាមូលដ្ឋានសំខាន់ៗនិងក្រមសីលធម៌វិជ្ជាជីវៈ។ |
| **ជំនាញលេខនព្វន្តព័ត៌មានវិទ្យានិងទំនាក់ទំនង** | • ប្រើវិធីស្ថិតិនិងលេខក្នុងការរៀបចំវាយតម្លៃនិងរបាយការណ៍លើសកម្មភាពការងារព្រមទាំងរិះរកដំណើរការថ្មីដែលស្របទៅនឹងស្ថានភាពការងារ<br>• សំយោគព័ត៌មានជាក្រាភិច លេខ សំណេរផ្ទាល់មាត់ និងធ្វើបទបង្ហាញការសន្និដ្ឋានដោយត្រឹមត្រូវនិងច្បាស់លាស់.<br>• ប្រើវិធីគណិតវិទ្យានិងស្ថិតិទូទៅក្នុងការពិនិត្យពិច័យ និងលើកដំណោះស្រាយចំពោះបញ្ហានានា<br>• ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពទាំងក្នុងការនិយាយ ការសរសេរ ការរៃកញែក | • ប្រើព័ត៌មានជាស្ថិតិ លេខ និងសំណេរស្មុគស្មាញនិងចេះវិភាគបរិបទអប់រំនិងការងារ<br>• ទំនាក់ទំនងដោយប្រសិទ្ធភាពដោយសំណេរផ្ទាល់មាត់ និងធ្វើបទបង្ហាញស្របតាមបញ្ហានិងតម្រូវការទស្សនិកជន<br>• អភិវឌ្ឍនិងធ្វើបទបង្ហាញត្រឹមត្រូវច្បាស់លាស់ដើម្បីដឹកនាំនិងការរៀនសូត្រពីអ្នក ដទៃ<br>• ប្រើប្រាស់បានយ៉ាងប្រសើរនូវបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងក្នុងការប្រមូល បកស្រាយនិងផ្សព្វផ្សាយព័ត៌មាននិងគំនិតផ្សេងៗ<br>• ជ្រើសរើសវិធីសាស្ត្រគណិតវិទ្យាឬស្ថិតិដើម្បីប្រើប្រាស់ក្នុងការបកស្រាយទិន្នន័យ |

| | | |
|---|---|---|
| | រកហេតុផល ការវិភាគ និងការធ្វើសេចក្តីសន្និដ្ឋានត្រឹមត្រូវនិងច្បាស់លាស់<br>• ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងក្នុងការវិភាគបញ្ហា និងភស្តុតាងនានាដែលទទួលបាននិងក្នុងការធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាព។ | ព័ត៌មាននិងលើកជាដំណោះស្រាយនៅពេលធ្វើការពិនិត្យអង្កេតលើបញ្ហានានា<br>• ទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាពទាំងការនិយាយក៏ដូចជាសរសេរជ្រើសរើសនិងប្រើប្រាស់ទម្រង់បទបង្ហាញសមស្របទៅតាមព្រឹត្តិការណ៍និងអ្នកចូលរួមផ្សេងៗ។ |
| ជំនាញចិត្តចលនា | • មានជំនាញក្នុងការប្រើប្រាស់ឧបករណ៍បច្ចេកទេសទំនើបពាក់ព័ន្ធនឹងឧស្សាហកម្ម និងធ្វើការវិនិច្ឆ័យត្រឹមត្រូវតាមលក្ខខណ្ឌការងារផ្សេងគ្នា<br>• ប្រើជំនាញនេះស្របតាមបច្ចេកវិទ្យានិងការប្រើប្រាស់ថ្មី។ | • លទ្ធផលការសិក្សាក្នុងគុណវុឌ្ឍិនេះមានកម្រិតខ្ពស់ជាងគុណវុឌ្ឍិសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈដោយបន្ថែមនូវជំនាញដែលតម្រូវឲ្យមានការអនុវត្តកម្មវិធីបណ្តុះបណ្តាលដោយប្រសិទ្ធភាព។ មានន័យថាបេក្ខជនមិនគ្រាន់តែមានជំនាញប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសមត្ថភាពអាចធ្វើបទបង្ហាញដល់អ្នកដទៃ ហើយមានការយល់ដឹងពីរបៀបអភិវឌ្ឍនិងកែលម្អជំនាញនេះទៀតផង។ |
| ការអនុវត្ត | • ប្រើចំណេះដឹងដ៏ទូលំទូលាយក្នុងមុខរបររបស់ខ្លួនដូចជាគោលការណ៍ ទ្រឹស្តីពាក់ព័ន្ធនឹងដំណើរការ និងទិន្នផល។ ចំណេះដឹងនេះរួមមានការអនុវត្តនិងការប្រែប្រួលនៃជំនាញស្របទៅតាមបច្ចេកវិទ្យាថ្មីនិងកែតម្រូវដំណើរការការងារ<br>• ប្រើចំណេះដឹងនិងជំនាញដូចជាលេខនិងស្ថិតិដើម្បីវិភាគដំណោះស្រាយដោយប្រើគំនិតថ្មីនិងផ្ទេរចំណេះដឹងក្នុងស្ថានភាពការងារថ្មីៗ<br>• ការអនុវត្តដូចជាការវិនិច្ឆ័យលើផែនការគម្រោងការ បច្ចេកទេស ឬភាពជាអ្នកដឹកនាំពាក់ព័ន្ធនឹងផលិតផល សេវាកម្ម ការប្រតិបត្តិ គោលការណ៍ ឬនីតិវិធី<br>• បង្ហាញពីភាពជាអ្នកដឹកនាំក្នុងការដឹកនាំក្រុមការងារដោយមានប្រសិទ្ធភាពដោយការទទួលខុសត្រូវខ្ពស់ចំពោះគុណភាពសង្គតិភាពនៃដំណើរការការងារនិងទិន្នផល<br>• សមត្ថភាពអនុវត្តចំណេះដឹងក្នុងបរិបទផ្សេងៗ ចេះផ្ទេរនិងប្រើចំណេះដឹងក្នុងការដោះស្រាយបញ្ហា<br>• អនុវត្តគោលការណ៍និងបច្ចេកទេស | • សមត្ថភាពក្នុងការប្រើចំណេះដឹងក្នុងការដោះស្រាយបញ្ហាស្មុគស្មាញក្នុងវិស័យឧស្សាហកម្មនិងស្ថានភាពបង្រៀន និងរៀនក្នុងបរិបទផ្សេងៗគ្នា<br>• មានការគោរពខ្ពស់ពីនិស្សិតរួមថ្នាក់ និយោជិក និងតំណាងឧស្សាហកម្ម។<br>• យល់ច្បាស់ពីជំនាញរបស់ខ្លួននិងចេះពិចារណាដោយចេះស្រាវស្រាវរកដំណោះស្រាយបញ្ហាក្នុងវិជ្ជាជីវៈ និងការសិក្សា។<br>• មានការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍចំណេះដឹងនិងរៀនសូត្ររបស់អ្នកដទៃនិងខ្លួនឯងតាមរយៈសកម្មភាពសិក្សានិងអនុវត្តផ្ទាល់<br>• ផ្តើមគំនិតកែតម្រូវចំណេះដឹងនិងជំនាញរបស់ខ្លួនស្របតាមបរិបទខុសៗគ្នា តម្រូវតាមសេចក្តីត្រូវការរបស់អ្នកសិក្សា ជួយគាំទ្រនិងលើកទឹកចិត្តអ្នកដទៃឲ្យខិតខំរៀនសូត្រ<br>• ប្រមូលព័ត៌មានស្មុគស្មាញតាមរបៀបផ្សេងៗ និងអាចធ្វើបទបង្ហាញព័ត៌មាននោះតាមរបៀបត្រឹមត្រូវច្បាស់លាស់ដល់ទស្សនិកជនខុសៗគ្នា<br>• ភាពជាអ្នកដឹកនាំដែលមានប្រសិទ្ធភាពនិងការទទួលខុសត្រូវខ្ពស់ចំពោះ [illegible] |

| | | |
|---|---|---|
| | សំខាន់ៗក្នុងបរិបទដែលប្រែប្រួលមិនអាចទស្សទាយទុកមុន។ ចូលរួមចំណែកក្នុងការអភិវឌ្ឍផែនការថវិកាឬយុទ្ធសាស្ត្រពាក់ព័ន្ធនឹងគណនេយ្យភាព ការទទួលខុសត្រូវលើខ្លួនឯងនិងអ្នកដទៃក្នុងការសម្រេចលទ្ធផល<br>• ផ្ទេរព័ត៌មានដ៏ស្មុគស្មាញបានត្រឹមត្រូវច្បាស់លាស់ និងទាន់ពេលវេលា<br>• ប្រើប្រាស់ឧបករណ៍បច្ចេកទេសមានលក្ខណៈស្មុគស្មាញប្រកបដោយការប៉ិនប្រសប់ខ្ពស់ត្រឹមត្រូវតាមស្តង់ដាសុវត្ថិភាព ព្រមទាំងផ្តល់ការណែនាំដោយមានប្រសិទ្ធភាពចំពោះអ្នករួមការងារក្នុងកិច្ចការស្រដៀងគ្នា<br>• យល់ពីជំនាញច្បាស់លាស់ ចេះវិភាគ វិនិច្ឆ័យ រៀបចំ និងប្រតិបត្តិកិច្ចការពាក់ព័ន្ធនឹងមុខងារគ្រប់គ្រងនិងបច្ចេកទេស<br>• បង្កើតគំនិតតាមរយៈការវិភាគព័ត៌មាននិងគោលគំនិតប្រកបដោយអរូបិយ<br>• ការផ្តោតលើចំណេះដឹងស៊ីជម្រៅនិងជំនាញខុសគ្នារវាងគុណវុឌ្ឍិក្នុងកម្រិតនេះ | ខ្លួននិងជាក្រុម។<br>• អភិវឌ្ឍជំនាញទូទៅដែលទាក់ទងនឹងបរិបទការងារនិងសមត្ថភាពដឹកនាំខ្លួនឯងនិងរៀនពេញមួយជីវិត<br>• មានគំនិតផ្តួចផ្តើមក្នុងការរកនិងដោះស្រាយបញ្ហាផ្សេងៗដែលកើតមានចំពោះបុគ្គលផ្ទាល់ខ្លួននិងក្រុមដោយការប្រតិបត្តិក្នុងភាពជាអ្នកដឹកនាំក្នុងការស្វែងរកដំណោះស្រាយថ្មីៗជាក់ស្តែង<br>• ប្រើប្រាស់ចំណេះដឹងនិងវិធីសាស្ត្រផ្អែកទ្រឹស្តីទទួលបានក្នុងវិស័យដែលខ្លួនសិក្សាក្នុងការពិនិត្យថ្លឹងថ្លែងលើបញ្ហានានាក្នុងបរិបទផ្សេងៗ<br>• ចូលរួមក្នុងសកម្មភាពនានាដើម្បីរក្សាខ្លួនឲ្យដើរទាន់ការលូតលាស់នៅក្នុងវិស័យដែលខ្លួនសិក្សានិងដើម្បីពង្រីកចំណេះដឹងនិងការយល់ដឹងរបស់ខ្លួន<br>• ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួននូវតិរិយាបថអភិសមាចារ និងទទួលខុសត្រូវខ្ពស់នៅក្នុងបរិបទសិក្សាវិជ្ជាជីវៈនិងសហគមន៍នានា |
| ចំណុះនៃការសិក្សា | សិក្សារយៈពេល២ឆ្នាំ | សិក្សារយៈពេលពី៤-៦ឆ្នាំ |



## ការពិពណ៌នាពីសមត្ថភាពទូទៅក្នុងកម្រិតគុណវុឌ្ឍិនីមួយៗនៃ ក.គ.ជ.ក

| សញ្ញាបត្រ ក.គ.ជ.ក | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស<br>បរិញ្ញាបត្រជាន់ខ្ពស់ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស/<br>បណ្ឌិត |
|---|---|---|
| កម្រិត | កម្រិត៧ | កម្រិត៨ |
| គោលបំណង | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសឬបរិញ្ញាបត្រតាមរយៈកិច្ចការសិក្សា គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តនូវបណ្តុំនៃចំណេះដឹងជាន់ខ្ពស់ក្នុងបរិបទទូទៅ ដើម្បីប្រតិបត្តិជំនាញវិជ្ជាជីវៈអាជីពឬក៏ភាពជាអ្នកមានវិជ្ជាជីវៈជ្រៅជ្រះនិងទុកជាប្រកសម្រាប់បន្តការសិក្សាបន្ថែមទៀត បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេសឬបរិញ្ញាបត្រតាមរយៈការស្រាវជ្រាវ គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តនូវបណ្តុំនៃចំណេះដឹងជាន់ខ្ពស់ក្នុងបរិបទនៃការសិក្សាស្រាវជ្រាវទូទៅនិងស៊ីជម្រៅនៃជំនាញវិជ្ជាជីវៈ និងទុកជាប្រកសម្រាប់បន្តការសិក្សាបន្ថែមទៀត។ | សញ្ញាបត្របណ្ឌិត គឺដើម្បីកំណត់នូវគុណវុឌ្ឍិរបស់បុគ្គលដែលអនុវត្តចំណេះដឹងជាន់ខ្ពស់ជាឯកទេស ដើម្បីស្រាវជ្រាវនិងអភិវឌ្ឍនូវចំណេះដឹងថ្មីៗនៅក្នុងវិស័យមួយឬច្រើន ប្រកបដោយភាពស៊ីជម្រៅ ការពិនិត្យអង្កេតឬជាអ្នកអនុវត្តជំនាញវិជ្ជាជីវៈអាជីព។ |
| ចំណេះដឹង | • មានចំណេះដឹង ការយល់ដឹងច្បាស់លាស់លើចំណុចសំខាន់នៃមុខវិជ្ជានិងការអប់រំដែលរួមមានទស្សនាទាន គោលការណ៍ ទ្រឹស្តី និងការប្រតិបត្តិថ្មីៗដែលទាក់ទងដំណើរការនៃការសិក្សានិងការអនុវត្តក្នុងជំនាញវិជ្ជាជីវៈ<br>• មានការយល់ដឹងល្អិតល្អន់លើផ្នែកមួយឬច្រើនដែលស្មុគស្មាញក្នុងជំនាញឯកទេសរបស់ខ្លួនពាក់ព័ន្ធនឹងទ្រឹស្តី ការស្រាវជ្រាវនិងការអនុវត្តជាក់ស្តែង<br>• យល់ពីរបៀបដែលចំណេះដឹងថ្មីៗត្រូវបានអភិវឌ្ឍនិងដាក់ឲ្យប្រើប្រាស់និងផលប៉ះពាល់នៃការស្រាវជ្រាវថ្មីៗទៅលើចំណេះដឹងក្នុងជំនាញរបស់ខ្លួនក៏ដូចជាលើការប្រតិបត្តិជំនាញវិជ្ជាជីវៈ<br>• យល់ដឹងពីវិធានថ្មីៗនៅក្នុងតំបន់និងអន្តរជាតិ | • មានការយល់ដឹងច្បាស់លាស់ពីចំណុចសំខាន់ៗនៃចំណេះដឹងក្នុងការអប់រំឬជំនាញវិជ្ជាជីវៈដោយរួមបញ្ចូលទាំងព័ត៌មានជាក់លាក់ ទ្រឹស្តី គោលការណ៍ និងទស្សនាទានជាមូលដ្ឋាននានា<br>• យល់ដឹងពីការអភិវឌ្ឍចុងក្រោយនៅក្នុងជំនាញវិជ្ជាជីវៈរបស់ខ្លួនដោយរួមទាំងបញ្ហាដែលកើតមានឡើងនិងបច្ចេកទេសក្នុងការស្រាវជ្រាវនិងបញ្ហាប្រឈមជាចម្បងក្នុងការអភិវឌ្ឍ ការសន្និដ្ឋានដែលអាចទទួលយកបានជាទូទៅ<br>• សម្រាប់ការ ក្សាកម្រិតបណ្ឌិតជំនាញវិជ្ជាជីវៈ និស្សិតត្រូវទទួលបានចំណេះដឹងច្បាស់លាស់និងទូលំទូលាយស្តីពីការផ្លាស់ប្តូរក្នុងការអនុវត្តជាក់ស្តែងទាំងក្នុងគ្រប់វិស័យ |

| | | |
|---|---|---|
| | ដែលអាចមានឥទ្ធិពលលើជំនាញវិជ្ជាជីវៈ ដែលទាក់ទងនឹងហេតុផលស្តីពីការផ្លាស់ប្តូរក្នុងការអនុវត្តវិធានទាំងនេះនាពេលអនាគត។ | តំបន់និងអន្តរជាតិ<br>• មានចំណេះដឹងច្បាស់លាស់ពីការអភិវឌ្ឍនៅក្នុងជំនាញពាក់ព័ន្ធដែលមានឥទ្ធិពលទៅលើការអនុវត្តវិជ្ជាជីវៈ។ |
| ជំនាញក្នុងការគិត | • យកចំណេះដឹងទាំងទ្រឹស្តីនិងការអនុវត្តទៅដោះស្រាយបញ្ហាថ្មីប្លែកនិងមិនអាចព្រាងទុកនៅក្នុងការសិក្សានិងជំនាញវិជ្ជាជីវៈនិងចេះបង្កើតដំណោះស្រាយចំពោះបញ្ហានិងព្រឹត្តការណ៍ផ្សេងៗប្រកបដោយគំនិតច្នៃប្រឌិត<br>• មានលទ្ធភាពធ្វើការវិនិច្ឆ័យសមហេតុផលច្បាស់លាស់និងអាចទុកចិត្តបានក្នុងស្ថានភាពដែលព័ត៌មានពុំមានភាពគ្រប់-គ្រាន់និងច្បាស់លាស់<br>• ធ្វើសំយោគនិងប្រើប្រាស់ឯកសារសិក្សាដែលបោះពុម្ពផ្សព្វផ្សាយឬរបាយការណ៍វិជ្ជាជីវៈផ្សេងៗ ហើយបង្កើតនូវគំនិតថ្មីៗដ៏មានសារៈសំខាន់និងបូកបញ្ចូលគំនិតទាំងនោះបង្កើតជាចំណេះដឹងថ្មីៗបន្ថែមទៀត<br>• ប្រើបច្ចេកទេសស្រាវជ្រាវទូទៅនិងបច្ចេក-ទេសស្រាវជ្រាវជំនាញឯកទេសក្នុងការវិភាគប្រកបដោយប្រឌិតញាណលើបញ្ហាស្មុគស្មាញទាំងឡាយហើយអាចទាញយកនូវសេចក្តីសន្និដ្ឋាននិងលើកជាសំណើទាក់ទងនឹងវិស័យការអប់រំនិងវិជ្ជាជីវៈរបស់ខ្លួន<br>• រៀបចំគម្រោងនិងអនុវត្តគម្រោងខ្នាតធំឬការស្រាវជ្រាវដែលជាផ្នែកមួយនៃការសិក្សាដោយឯករាជ្យតាមរយៈការយកចំណេះដឹងទាំងទ្រឹស្តី ការអនុវត្ត និងបច្ចេកទេសស្រាវជ្រាវមកប្រើប្រាស់ដើម្បីបង្កើតនូវសេចក្តីសន្និដ្ឋានសំខាន់ៗបន្ថែមលើចំណេះដឹងនិងការអនុវត្តវិជ្ជាជីវៈដែលមានហើយ។ | • ប្រើប្រាស់ការយល់ដឹងខាងទ្រឹស្តីនិងបច្ចេកទេសនៃការអង្កេតដើម្បីយកមកវិភាគប្រកបដោយគំនិតច្នៃប្រឌិតលើព្រឹត្តិការណ៍និងបញ្ហាសំខាន់ៗព្រមទាំងអាចបង្កើតបាននូវដំណោះស្រាយថ្មីៗចំពោះបញ្ហាទាំងនោះ<br>• សំយោគការស្រាវជ្រាវនិងការសរសេរទ្រឹស្តីហើយអាចអភិវឌ្ឍនូវការយល់ដឹងថ្មីៗប្រកបដោយការច្នៃប្រឌិតដោយផ្អែកលើការធ្វើសមាហរណកម្មរវាងគំនិតទាំងក្នុងនិងក្រៅជំនាញសិក្សាជាន់ខ្ពស់របស់ខ្លួន<br>• រៀបចំនិងដឹកនាំការស្រាវជ្រាវឬគម្រោងអភិវឌ្ឍន៍សំខាន់ៗ ដើម្បីដោះស្រាយបញ្ហាស្មុគស្មាញនានាដែលទាក់ទងនឹងការអភិវឌ្ឍចំណេះដឹងថ្មីឬការធ្វើឲ្យកាន់តែប្រសើរឡើងក្នុងការងារប្រតិបត្តិវិជ្ជាជីវៈសំខាន់ៗ។ |
| ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ | • ផ្តួចផ្តើមគំនិតក្នុងការស្វែងរកនិងដោះស្រាយប្រកបដោយគំនិតច្នៃប្រឌិតនូវបញ្ហានិងស្ថានភាពស្មុគស្មាញកើតមានក្នុងបរិបទនៃ | • ប្រព្រឹត្តិយ៉ាងសមស្របជាមួយនឹងស្វ័យភាពនិងការផ្តើមគំនិតកម្រិតខ្ពស់ក្នុងសកម្មភាពវិជ្ជាជីវៈឬវិជ្ជាការជាន់ខ្ពស់ |

| | | |
|---|---|---|
| | ការសិក្សានិងវិជ្ជាជីវៈរបស់ខ្លួន។ នៅពេលដែលមានតម្រូវការព័ត៌មាននិងជំនាញបន្ថែមនិស្សិតមានលទ្ធភាពចាត់វិធានការស្វែងរកព័ត៌មាននិងអនុវត្តនូវជំនាញបន្ថែមដោយឯករាជ្យ<br>• ទទួលខុសត្រូវយ៉ាងពេញទំហឹងចំពោះការងាររបស់ខ្លួននិងសហប្រតិបត្តិការជាមួយសមាជិកដទៃទៀតដើម្បីដោះស្រាយគ្រប់ស្ថានការណ៍និងបញ្ហាទាំងឡាយ ប្រតិបត្តិនូវជំនាញភាពជាអ្នកដឹកនាំរបស់ខ្លួនទាំងជាផ្លូវការនិងមិនផ្លូវការតាមការចាំបាច់<br>• ចំពោះការងារជាក្រុមអាចបញ្ចេញនូវសកម្មភាពទាំងឡាយក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ក្រុមទាំងមូល។ | • ទទួលខុសត្រូវខ្ពស់ចំពោះសកម្មភាពរបស់ខ្លួន វាយតម្លៃ និងបង្កើនប្រសិទ្ធភាពការងាររបស់ខ្លួនតាមរយៈការទទួលយកបតិយោបល់ពិតនិងការធ្វើផែនការកែលម្អឲ្យកាន់តែប្រសើរឡើង<br>• សម្របសម្រួលនិងលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងសកម្មភាពការងារជាក្រុមនិងអនុវត្តយ៉ាងមានប្រសិទ្ធភាពក្នុងភាពជាអ្នកដឹកនាំក្នុងបរិស្ថានសង្គមនិងវិជ្ជាជីវៈដ៏ស្មុគស្មាញ<br>• ដោះស្រាយបានយ៉ាងហ្មត់ចត់និងឆាប់រហ័សនូវបញ្ហាសីលធម៌ដ៏ស្មុគស្មាញ ធ្វើការវិនិច្ឆ័យដោយការស៊ើបអង្កេតប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌ និងធ្វើឬបង្ហាញសេចក្តីសន្និដ្ឋានឲ្យបានគ្រប់ជ្រុងជ្រោយទៅលើបញ្ហាឬកង្វល់ដែលប៉ះពាល់ទាំងនោះ<br>• ផ្តួចផ្តើមគំនិតក្នុងការលើកឡើងពីភាពមិនគ្រប់គ្រាន់ឬគ្មានប្រសិទ្ធភាពនៃក្រមសីលធម៌វិជ្ជាជីវៈដែលមានស្រាប់ដើម្បីពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មឲ្យបានសមស្របនិងត្រឹមត្រូវ។ |
| **ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង** | • ប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពនិងសមរម្យជាមួយក្រុមអ្នកពាក់ព័ន្ធនានានៅក្នុងជំនាញវិជ្ជាជីវៈរបស់ខ្លួនក៏ដូចជាក្នុងសហគមន៍ទាំងមូលតាមរយៈរបាយការណ៍និងបទបង្ហាញទាំងជាផ្លូវការនិងមិនផ្លូវការនិងតាមរយៈការបោះពុម្ពផ្សាយដែលមានលក្ខណៈអប់រំនិងវិជ្ជាជីវៈ ដូចជានិក្ខេបបទឬរបាយការណ៍នៃគម្រោងស្រាវជ្រាវ<br>• គណនា ស្រង់ស្ថិតិទិន្នន័យ និងប្រើប្រាស់បានយ៉ាងទូលំទូលាយនូវបច្ចេកវិទ្យាព័ត៌មានវិទ្យានិងទំនាក់ទំនង ដើម្បីអង្កេតបញ្ហាទាំងឡាយដែលកើតមានឡើង អាចបង្ហាញនូវសេចក្តីសន្និដ្ឋាននិងសំណូមពររបស់ខ្លួនជូនអ្នកដែលពាក់ព័ន្ធ។ | • ប្រាស្រ័យទាក់ទងយ៉ាងមានប្រសិទ្ធភាពនិងសមរម្យជាមួយអ្នកពាក់ព័ន្ធនៅក្នុងការសិក្សាទូទៅនិងវិជ្ជាជីវៈក៏ដូចជាក្នុងសហគមន៍ទាំងមូលតាមរយៈរបាយការណ៍និងបទបង្ហាញផ្លូវការនិងមិនផ្លូវការ និងតាមរយៈការបោះពុម្ពផ្សាយក្នុងការអប់រំទូទៅនិងវិជ្ជាជីវៈដូចជានិក្ខេបបទជំនាញឬរបាយការណ៍គម្រោងស្តីពីបញ្ហាសំខាន់និងស្មុគស្មាញណាមួយ<br>• គណនានិងប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវទិន្នន័យគណិតវិទ្យានិងស្ថិតិនិងប្រើប្រាស់បានយ៉ាងទូលំទូលាយនូវបច្ចេកវិទ្យាព័ត៌មានវិទ្យានិងទំនាក់ទំនងក្នុងការអង្កេតបញ្ហានិងការបង្ហាញសេចក្តីសន្និដ្ឋាននិងអនុសាសន៍។ |

| | | |
|---|---|---|
| ការអនុវត្ត | • អនុវត្តការងារក្នុងកម្រិតនេះ គឺអនុលោមទៅនឹងការធ្វើផែនការការងារទូទៅ ផែនការថវិកាឬយុទ្ធសាស្ត្រ ហើយទទួលខុសត្រូវយ៉ាងសំខាន់ចំពោះចេនាសម្ព័ន្ធការងារទូទៅការងារគ្រប់គ្រងរួមទាំងមុខងារនិងលទ្ធផលការងាររបស់អ្នកដទៃដែលពាក់ព័ន្ធ<br>• មានការវិនិច្ឆ័យប្រកបដោយសុក្រឹតភាពនិងកម្រិតខ្ពស់លើផែនការ ការរៀបចំគម្រោងប្លង់ ដំណើរការការងារបច្ចេកទេសឬការងារគ្រប់គ្រង<br>• ឆ្លើយតបយ៉ាងទៀងទាត់ទៅនឹងភាពស្មុគ-ស្មាញក្នុងការសិក្សានិងបញ្ហាដែលទាក់ទងជំនាញ ដោយផ្តល់នូវដំណោះស្រាយបញ្ហាប្រកបដោយគំនិតច្នៃប្រឌិតការវិនិច្ឆ័យត្រឹមត្រូវហើយប្រើប្រាស់នូវជំនាញទាំងនេះតាមការចាំបាច់ក្នុងការដោះស្រាយបញ្ហាក្នុងករណីពុំមានទិន្នន័យឬព័ត៌មានគ្រប់គ្រាន់<br>• សម្រេចចិត្តដោយមានភាពឯករាជ្យក្នុងការប្រឈមមុខនិងដោះស្រាយបញ្ហាដែលអាចដឹងមុននិងបញ្ហាកើតឡើងដោយចៃដន្យហើយសហការជាមួយអ្នកដទៃនិងផ្តល់ភាពជាអ្នកដឹកនាំតាមការចាំបាច់<br>• ប្រតិបត្តិតាមនិងជួយជំរុញអ្នកដទៃឲ្យយកសីលធម៌និងសុភនិច្ឆ័យទៅដោះស្រាយបញ្ហាជម្លោះដែលលំបាកនិងស្មុគស្មាញ<br>• មានការទទួលខុសត្រូវខ្ពស់ ដោយមានភាពម្ចាស់ការលើការសិក្សានិងភាពជាអ្នកដឹកនាំដែលជាឱកាសដើម្បីជួយជំរុញការអភិវឌ្ឍផ្នែកវិជ្ជាជីវៈដល់អ្នកដទៃផ្សេងៗទៀត | • ការអនុវត្តពាក់ព័ន្ធទៅនឹងការទទួលខុស-ត្រូវនិងចាត់ចែងរួមនូវរាល់ទិដ្ឋភាពទាំងអស់ចំពោះអ្នកដទៃទាំងការងារនិងតួនាទី ហើយរួមទាំងការរៀបចំផែនការការងារផែនការថវិកានិងផែនការយុទ្ធសាស្ត្រនានាដែលត្រូវការ<br>• ប្រើប្រាស់បានយ៉ាងត្រឹមត្រូវនូវចំណេះដឹងនិង/ឬការយល់ដឹងជ្រៅជ្រះខាងវិជ្ជាជីវៈរបស់ខ្លួនទៅលើការអភិវឌ្ឍបន្ថែមផ្នែកចំណេះដឹងនិងការអនុវត្តក្នុងជំនាញរបស់ខ្លួនដែលជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍការយល់ដឹងនិងយុទ្ធសាស្ត្រថ្មីៗ<br>• ផ្តល់នូវភាពជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើងក្នុងជំនាញរបស់ខ្លួននិងមានសមត្ថភាពក្នុងការផ្ទេរគំនិតនិងការសន្និដ្ឋានរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាពដល់អ្នកពាក់ព័ន្ធនានាទោះជាអ្នកមានជំនាញឬគ្មានជំនាញក្តី<br>• អាចដោះស្រាយយ៉ាងជាប់លាប់និងហ្មត់ចត់នូវបញ្ហាស្មុគស្មាញដែលទាក់ទងនឹងអភិសមាចារនៅក្នុងរង្វង់ការអប់រំនិងវិជ្ជាជីវៈរបស់ខ្លួននិងផ្តួចផ្តើមបង្កើតបាននូវដំណោះ-ស្រាយដ៏សមរម្យចំពោះបញ្ហាដែលជះឥទ្ធិពលដល់សហគមន៍ទាំងមូល |
| | -គុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់តាមរយៈកិច្ចការសិក្សាមានរយៈពេលសិក្សាចន្លោះពី៣-៤ឆមាស<br>-គុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់តាមរយៈការស្រាវជ្រាវមានរយៈពេលសិក្សា២ឆ្នាំ<br>-គុណវុឌ្ឍិបរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យានិងវិជ្ជាជីវៈតាមរយៈកិច្ចការសិក្សាមានរយៈពេលសិក្សា២ឆ្នាំ | សិក្សារយៈពេលពី៣-៦ឆ្នាំ |

## ២. សទ្ទានុក្រម

**ការទទួលស្គាល់គុណភាពអប់រំ (Accreditation)**

ជាដំណើរការតាមរយៈសមាគមឬភ្នាក់ងារទទួលខុសត្រូវស្របច្បាប់ ដើម្បីផ្តល់ការទទួលស្គាល់ជាសាធារណៈទៅលើសាលា វិទ្យាស្ថាន មហាវិទ្យាល័យ សាកលវិទ្យាល័យឬកម្មវិធីអប់រំ ដែលបំពេញបាននូវស្តង់ដាអប់រំអប្បបរមា។

តាមនិយមន័យរបស់គ.ទ.ក.ការទទួលស្គាល់គុណភាពអប់រំ គឺជាការអនុម័តផ្លូវការរបស់គ.ទ.ក.តាមនីតិវិធីដែលបានកំណត់ដោយប្រកាសថាគ្រឹះស្ថានឧត្តមសិក្សាបានបំពេញសមស្របតាមលក្ខខណ្ឌឬលក្ខណៈវិនិច្ឆ័យ ឬស្តង់ដាគុណភាពអប្បបរមារបស់គ.ទ.ក. និងទទួលបានសិទ្ធិចេញវិញ្ញាបនបត្រឬសញ្ញាបត្រគ្រប់កម្រិតក្នុងរយៈពេលមួយកំណត់។

**ការវាយតម្លៃ (Assessment)**

ជាដំណើរការនៃការប្រមូលភស្តុតាង ដើម្បីបញ្ជាក់ថាតើអ្នកសិក្សាទទួលបានតាមស្តង់ដាដែលតម្រូវឬទេ។ ការវាយតម្លៃក៏ត្រូវបានប្រើជាផ្នែកនៃដំណើរការសិក្សា ដើម្បីជួយដល់អ្នកសិក្សាក្នុងការធ្វើឲ្យមានការរីកចម្រើន(វឌ្ឍនកម្មផ្នែកចំណេះដឹង ជំនាញ និងសមត្ថភាព)។ តាមនិយមន័យរបស់គ.ទ.ក. ការវាយតម្លៃ គឺជាយន្តការមួយនៃដំណើរការទទួលស្គាល់គុណភាពអប់រំដែលត្រូវធ្វើការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សាដោយក្រុមមន្ត្រីវាយតម្លៃផ្អែកលើនីតិវិធី សេចក្តីណែនាំ លក្ខខណ្ឌឬលក្ខណវិនិច្ឆ័យ ឬស្តង់ដាគុណភាពអប្បបរមារបស់គ.ទ.ក និងរបាយការណ៍ស្វ័យវាយតម្លៃរបស់គ្រឹះស្ថានដែលបានផ្ញើជូនទៅគ.ទ.ក ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំនិងធ្វើឱ្យប្រសើរឡើងនូវគុណភាពអប់រំឧត្តមសិក្សា។ យន្តការនេះត្រូវបានអនុវត្តចំពោះគ្រឹះស្ថានដែលមិនទាន់មានការទទួលស្គាល់គុណភាពអប់រំ។

**ក្រេឌីត (Credit)**

ជាឯកតាឬតម្លៃដែលយកជាខ្នាតសម្រាប់វាស់វែងពីលទ្ធផលសិក្សាសម្រេចបាននៅក្នុងសញ្ញាណម៉ោងនៃកម្រិតគុណវុឌ្ឍិដែលបានផ្តល់។ ជាតម្លៃដែលផ្តល់សម្រាប់ការសិក្សាដែលសម្រេចបាននិងត្រូវបានផ្ទៀងផ្ទាត់តាមរយៈការវាយតម្លៃត្រឹមត្រូវនិងជឿទុកចិត្តបាន។

**ការផ្ទេរក្រេឌីត (Credit Transfer)**

ជាដំណើរការតាមក្រេឌីតដែលទទួលបាននៅក្នុងគ្រឹះស្ថានឬប្រព័ន្ធមួយ អាចនឹងត្រូវបានទទួលស្គាល់ដោយគ្រឹះស្ថានឬប្រព័ន្ធមួយទៀត។

**កម្មវិធីសិក្សា**
(Curriculum)

ជាសំណុំនៃការងារទៅតាមពេលនៃការអភិវឌ្ឍកម្មវិធីសិក្សា រួមមានការកំណត់គោលដៅ ខ្លឹមសារ វិធីសាស្ត្រ(រួមទាំងការវាយតម្លៃ)និងសម្ភារនៃការបណ្តុះបណ្តាល។ តាមនិយមន័យរបស់គ.ទ.ក. កម្មវិធីសិក្សាសំដៅដល់សំណុំមុខវិជ្ជាដែលត្រូវបានរៀបចំឲ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ចំណេះធ្វើ សីលធម៌ និងសមត្ថភាពបន្តការសិក្សាពេញមួយជីវិត។

**លទ្ធផលសិក្សា**
(Learning Outcomes)

ជាសេចក្តីថ្លែងនូវអ្វីដែលអ្នកសិក្សាចេះ យល់និងអាចធ្វើក្រោយបញ្ចប់ការសិក្សាតាមរយៈលក្ខណវិនិច្ឆ័យស្នាដៃការងារផ្អែកលើចំណេះដឹង ជំនាញ អាកប្បកិរិយា និងសមត្ថភាព។

**កម្មវិធីអប់រំ**
(Learning Programme)

ជាកម្មវិធីនៃការសិក្សាឬការបណ្តុះបណ្តាល កំណត់ដោយកម្មវិធីបណ្តុះ-បណ្តាលមួយដែលមានម៉ូឌុល មេរៀន កម្មវត្ថុ ឬមុខវិជ្ជាឬបន្សំនៃធាតុទាំងនេះ។

**កម្រិត**
(Level)

សំដៅលើទីតាំងដែលគុណវុឌ្ឍិមួយស្ថិតនៅក្នុងក្របខ័ណ្ឌគុណវុឌ្ឍិទៅតាមឈ្មោះកម្រិតគុណវុឌ្ឍិ។

**ការពណ៌នាកម្រិតគុណវុឌ្ឍិ**
(Level Descriptor)

សំដៅលើនិយមន័យនៃចរិកលក្ខណៈរបស់គុណវុឌ្ឍិដែលអាចនឹងផ្តល់ជាឈ្មោះឬការពិពណ៌នាទៅលើកម្រិតគុណវុឌ្ឍិពិសេស។

**ម៉ូឌុលនីយកម្ម**
(Modularisation)

សំដៅទៅលើប្រព័ន្ធនៅក្នុងគុណវុឌ្ឍិដែលមានចំនួនម៉ូឌុល ហើយម៉ូឌុលនីមួយៗ អាចត្រូវបានធ្វើវិញ្ញាបនកម្ម(ការបញ្ជាក់)ដាច់ដោយឡែកពីគ្នា។ ពេលខ្លះត្រូវបានគេស្គាល់ថា«ខ្នាតនីយកម្ម»និង«ម៉ូឌុលនីយកម្ម» ត្រូវបានប្រើ ដើម្បីសំដៅលើប្រព័ន្ធមួយនៅក្នុងកម្មវិធីអប់រំដែលមានចំនួនសមាសភាគ។

**ម៉ូឌុល**
(Module)

ជាសមាសភាគរបស់គុណវុឌ្ឍិដែលមានវិសាលភាពធំ ដែលត្រូវបានធ្វើវិញ្ញាបនកម្មដាច់ដោយឡែកឬឯករាជ្យពីគ្នា។ (ជួនកាលវាមានន័យជាសមាសភាគនៃការបង្រៀននិងរៀននៅក្នុងកម្មវិធីអប់រំដែលមិនត្រូវបានធ្វើវិញ្ញាបនកម្មដាច់ដោយឡែកពីគ្នាទេ)។

**ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ**
(National Qualifications

ជាលិខិតូបករណ៍សម្រាប់ធ្វើការអភិវឌ្ឍនិងចំណាត់ថ្នាក់គុណវុឌ្ឍិដោយអាស្រ័យទៅនឹងកម្រងលក្ខណវិនិច្ឆ័យនៃការសិក្សាដែលសម្រេច

| | |
|---|---|
| Framework) | បានតាមកម្រិតនីមួយៗ ដោយកម្រងលក្ខណវិនិច្ឆ័យនោះបានបញ្ជាក់ជាលក្ខណៈទូទៅនៅក្នុងការពណ៌នាគុណវុឌ្ឍិក្នុងកម្រិតនីមួយៗនៃក្របខ័ណ្ឌគុណវុឌ្ឍិ។ |
| គុណវុឌ្ឍិ (Qualification) | ១. ជាបណ្តុំសមត្ថភាពដែលឆ្លើយតបទៅនឹងតួនាទីការងារ និងផ្នែក សំខាន់នៅកន្លែងធ្វើការ។<br>២. ជាវិញ្ញាបនបត្រ សញ្ញាបត្រ ឬកម្រិត ដែលផ្តល់ឲ្យដោយគ្រឹះស្ថាន ផ្តល់ការអប់រំឬក្រុម ដែលមានសិទ្ធិផ្តល់គុណវុឌ្ឍិ និងបញ្ជាក់ពីការ ទទួលបានលទ្ធផលសិក្សា។<br>៣. ជាការបញ្ជាក់ផ្លូវការ ដែលចេញដោយអង្គភាពពាក់ព័ន្ធ ក្នុងការទទួលស្គាល់ថាបុគ្គលម្នាក់សម្រេចបានលទ្ធផលសិក្សាឬសមត្ថភាពដែលទាក់ទងទៅនឹងតម្រូវការរបស់បុគ្គល អាជីព ក្រុមហ៊ុន ឬ សហគមន៍។ |
| ក្របខ័ណ្ឌគុណវុឌ្ឍិ (Qualifications Framework) | ជាឧបករណ៍សម្រាប់ការធ្វើចំណាត់ថ្នាក់នៃគុណវុឌ្ឍិដែលផ្អែកទៅលើសំណុំលក្ខណវិនិច្ឆ័យដែលបានបង្កើតសម្រាប់កម្រិតគុណវុឌ្ឍិសម្រេចបានជាក់លាក់ ដែលធ្វើឲ្យប្រសើរឡើងនូវតម្លាភាព ប្រកចូលវឌ្ឍនភាព ការប្រៀបធៀប និងគុណភាពនៃគុណវុឌ្ឍិ។ |
| ការធានាគុណភាព (Quality Assurance) | សំដៅដល់ពាក្យទូទៅសម្រាប់គ្រប់សកម្មភាពដែលផ្តល់ការធានាថាសេវានៃការអប់រំនិងការបណ្តុះបណ្តាលរបស់គ្រឹះស្ថានឬអង្គភាព ត្រូវបានផ្តល់ប្រកបដោយប្រសិទ្ធភាពជាប់ជានិច្ច ទៅតាមតម្រូវការស្តង់ដានិងស្របតាមគោលដៅ និងគោលបំណងដែលបានផ្សព្វផ្សាយ។ |
| កម្រិតគុណវុឌ្ឍិ (Qualification Level) | ជាកម្រិតផ្តល់ឲ្យមានដែលរៀបរាប់ពីប្រភេទលទ្ធផលឬការពិពណ៌នាគុណវុឌ្ឍិដែលចង្អុលពីចរិតលក្ខណៈគុណវុឌ្ឍិតាមប្រភេទ។ |
| ការទទួលស្គាល់ការសិក្សាដែលមានពីមុន (Recognition of Prior Learning (RPL) | សំដៅដល់ការទទួលស្គាល់និងផ្តល់សុពលភាពលើសមត្ថភាពសម្រាប់គោលបំណងនៃការធ្វើវិញ្ញាបនកម្ម(ការបញ្ជាក់)ដែលបានពីក្រៅប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលផ្លូវការ។ |
| ការចុះបញ្ជី (Registration) | ជាដំណើរនៃការផ្តល់ឲ្យគ្រឹះស្ថានមួយនូវឱកាសដើម្បីបង្កើតទំនាក់ទំនងដែលមានការទទួលស្គាល់ជាផ្លូវការ និងជាសាធារណៈជាមួយស្ថាប័នជាតិពាក់ព័ន្ធ (អាជ្ញាធរមានសមត្ថកិច្ច)។ |

| | |
|---|---|
| ជំនាញ<br>(Skills) | ជាសមត្ថភាពប្រើប្រាស់ចំណេះដឹងដើម្បីបំពេញការងារនិងដោះស្រាយបញ្ហា។ ជំនាញត្រូវបានពិពណ៌នាជាចំណេះដឹងវិភាគ (ការប្រើគំនិតប្រកបដោយភាពត្រឹមត្រូវ អព្ភន្តរញ្ញាណ និងការច្នៃប្រឌិត) និងការអនុវត្ត (ទាក់ទងនឹងទេពកោសល្យហត្ថកម្មឬជំនាញប្រើដោយដៃ និងការប្រើវិធីសាស្ត្រ សម្ភារ ឧបករណ៍ និងគ្រឿងប្រដាប់ផ្សេងៗ)។ |
| សមត្ថភាព<br>(Competency) | គឺជាចំណេះដឹង ជំនាញ និងឥរិយាបថជាក់លាក់ដែលត្រូវការក្នុងកន្លែងការងារ ហើយអនុវត្តនូវចំណេះដឹងនិងជំនាញទាំងនោះ ប្រតិបត្តិសកម្មភាពការងារឲ្យឆ្លើយតបទៅនឹងស្តង់ដាប្រតិបត្តិដែលបានកំណត់ ។ |
| ការវាយតម្លៃសមត្ថភាព<br>(Competency Assessment) | ជាដំណើរការនៃការប្រមូលភស្តុតាងនិងធ្វើការវាយតម្លៃនៅក្នុងការវិនិច្ឆ័យលើផ្នែកសមត្ថភាពដែលទទួលបានជោគជ័យ។ |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំណុះក្រសួងមហាផ្ទៃ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១ ៖** ត្រូវបានបង្កើត **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** ចំណុះក្រសួងមហាផ្ទៃ ។

**មាត្រា២៖** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មានតួនាទីធ្វើជាសេនាធិការជូន ក្រសួងមហាផ្ទៃ ក្នុងការដឹកនាំគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន៍ ជនបរទេសអន្តោប្រវេសន៍ និង ជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន តាមលក្ខខណ្ឌនៃច្បាប់កំណត់ និង ការងារជនភៀសខ្លួន ។

**មាត្រា ៣ ៖** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដឹកនាំដោយ អគ្គនាយក ០១រូប និងមាន អគ្គនាយករង មួយចំនួនជាជំនួយតាមការចាំបាច់ ។

**មាត្រា ៤ ៖** ត្រូវបានផ្ទេរ នាយកដ្ឋានអន្តោប្រវេសន៍ ចេញពីអគ្គស្នងការដ្ឋាននគរបាលជាតិ មកចំណុះ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ។

**មាត្រា ៥៖** អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មានរចនាសម្ព័ន្ធ ដូចតទៅ:

១- នាយកដ្ឋានរដ្ឋបាលសរុប

២- នាយកដ្ឋានគ្រប់គ្រងជនបរទេសមិនមែនអន្តោប្រវេសន៍

៣- នាយកដ្ឋានគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍

៤- នាយកដ្ឋានគ្រប់គ្រងជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន

៥- នាយកដ្ឋានច្រកទ្វារអន្តរជាតិ

**មាត្រា ៦៖** តួនាទីភារកិច្ចរបស់ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និង តួនាទីភារកិច្ចរបស់ នាយកដ្ឋាន ចំណុះត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

**មាត្រា ៧៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៨ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម**

**ចំណុះក្រសួងមហាផ្ទៃ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១៖** ត្រូវបានបង្កើត **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** ចំណុះក្រសួងមហាផ្ទៃ ។

**មាត្រា២៖** អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានតួនាទីធ្វើជាសេនាធិការជូន ក្រសួងមហាផ្ទៃ ក្នុងការដឹកនាំគ្រប់គ្រង ការងារស្ថិតិប្រជាពលរដ្ឋ ការងារផ្តល់លិខិតអត្រានុកូលដ្ឋាន ការងារផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ការងារផ្តល់លិខិតឆ្លងដែន និងការងារផ្តល់សញ្ជាតិខ្មែរតាមលក្ខខណ្ឌនៃច្បាប់កំណត់។

**មាត្រា ៣៖** អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដឹកនាំដោយ អគ្គនាយក ០១រូប និងមាន អគ្គនាយករង មួយចំនួនជាជំនួយតាមការចាំបាច់ ។

**មាត្រា ៤៖** ត្រូវបានផ្ទេរ នាយកដ្ឋាននគរបាលស្ថិតិនិងលិខិតឆ្លងដែន ចេញពីអគ្គស្នងការដ្ឋាននគរបាលជាតិ និងផ្ទេរការងារអត្រានុកូលដ្ឋាន ការងារសញ្ជាតិ ពីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មកចំណុះ អគ្គនាយក-ដ្ឋានអត្តសញ្ញាណកម្ម ។

**មាត្រា ៥៖** អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានរចនាសម្ព័ន្ធ ដូចតទៅ

១- នាយកដ្ឋានរដ្ឋបាលសរុប

២- នាយកដ្ឋានអគ្រានុកូលដ្ឋាន

៣- នាយកដ្ឋានអត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរ

៤- នាយកដ្ឋានលិខិតឆ្លងដែន

៥- នាយកដ្ឋានសញ្ជាតិ

**មាត្រា ៦៖** តួនាទីភារកិច្ចរបស់ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និង តួនាទីភារកិច្ចរបស់ នាយកដ្ឋាន ចំណុះត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

**មាត្រា ៧** ៖បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៥៩. អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលរៀបចំឡើងវិញរចនាសម្ព័ន្ធ ក្របខ័ណ្ឌចាត់តាំង បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី២១ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅនៃកងរាជអាវុធហត្ថ
- បានឃើញអនុក្រឹត្យលេខ ១៣៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ស្តីពីការបង្កើតស្នងការដ្ឋាន ដាក់ចំណុះបញ្ជាការដ្ឋានកងរាជអាវុធហត្ថ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

